**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et de Sciences Economiques

Royal University of Law and Economics


**សារណាបញ្ចប់ការសិក្សា**

# នីតិវិធីនៃការលែងលះដោយការព្រមព្រៀង

ស្រាវជ្រាវ ចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ឈឹម ចាន់ធូ**

កញ្ញា **តារា ចន្ទ្រពេជ្រ**

ណែនាំដោយ

លោក **ឡោ សហី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំ **តារា ចន្ទ្រពេជ្រ** និងនាងខ្ញុំ **ឈឹម ចាន់ធូ** ជានិស្សិត ថ្នាក់បរិញ្ញាបត្រ ជំនាញ នីតិសាស្ត្រ ជំនាន់ទី២៣ ឆ្នាំសិក្សា ២០១៩-២០២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ យើងខ្ញុំ សូមគោរពប្រតិបត្តិ និង សម្តែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះអ្នកមានគុណទាំងទ្វេរ របស់យើងខ្ញុំ យ៉ាងក្រៃលែង និង លើសលប់ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សាយ៉ាងកក់ក្តៅ ប្រកបទៅដោយព្រហ្មវិហារធម៌ ព្រមទាំងទូន្មានប្រៀនប្រដៅ និង ទំនុកបំរុងគ្រប់បែបយ៉ាង តាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ។ កម្លាំងញើសឈាមធំក្រៃលែងដែល អ្នកមានគុណ លះបង់សម្រាប់កូនក្នុងការផ្គត់ផ្គង់ ទំនុកបម្រុង ទាំងផ្នែកស្មារតី និង សម្ភារៈនានា ក៏ព្រោះតែចង់ឃើញកូនធំដឹងក្តី និង មានចំណេះដឹងដែលជាស្ពានចម្លងផុតទុក្ខនាថ្ងៃអនាគត។

យើងខ្ញុំ ក៏សូមសម្តែងការគោរពដឹងគុណយ៉ាងជ្រាវជ្រៅផងដែរ ជូនចំពោះ **ឯកឧត្តម សាកលវិទ្យាធិការ លុយ ចណ្ណា** និង សាស្ត្រាចារ្យ ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយសម្រួលការងារគ្រប់បែបយ៉ាង និង បង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ និង អស់ពីកម្លាំងកាយចិត្តដល់ពួកយើងខ្ញុំ រយៈពេល ៤ ឆ្នាំ កន្លងមកនេះ។

ជាពិសេសយើងខ្ញុំ សូមថ្លែងអំណរគុណ និង ដឹងគុណយ៉ាងក្រៃលែងជូនចំពោះ **លោក ឡោ សហី** ដែលបានចំណាយពេលផ្ទាល់ខ្លួនដ៏មានតម្លៃក្នុងការជួយណែនាំ និង កែតម្រូវរាល់កំហុសឆ្គងផ្សេងៗដែលកើតមានឡើង ព្រមទាំងបានផ្តល់នូវអនុសាសន៍ដែលជាគំនិតថ្មីៗ ក្នុងការបំពេញបន្ថែមនូវចំណុចខ្វះខាតនានា ចាប់តាំងពីថ្ងៃផ្តើម រហូតដល់ទទួលបានសមិទ្ធផលជាស្ថាពរនូវសារណានេះ។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីមង្គលដល់លោក អ្នកមានគុណទាំងពីរ និង លោកគ្រូ អ្នកគ្រូដែលបានបង្ហាត់បង្រៀន តាំងពីថ្នាក់មតេយ្យរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ ឲ្យជួបតែពុទ្ធពរ ទាំងបួន ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងសម្រេចបាននូវគោលបំណង និង ទទួលបាននូវ សេចក្តីសុខ ចម្រុងចម្រើន មានជោគជ័យគ្រប់បែបយ៉ាងក្នុងការបំពេញកាតព្វកិច្ចការងារ កុំបីឈ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

តាមរយៈការសិក្សារយៈពេលបួនឆ្នាំ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។ នៅក្នុងការសិក្សាកន្លងមក យើងខ្ញុំបានសិក្សាទៅលើមុខវិជ្ជាសំខាន់ៗជាច្រើនដែលផ្តល់ឲ្យយើងខ្ញុំនូវចំណេះដឹងផ្នែកច្បាប់យ៉ាងទូលំទូលាយក្នុងនោះរួមមានច្បាប់ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជា និងប្រព័ន្ធច្បាប់នៅតាមបណ្តាប្រទេសធំៗនៅលើពិភពលោក។ នៅក្នុងចំណោមមុខវិជ្ជាទាំងអស់ដែលយើងខ្ញុំបានសិក្សា យើងខ្ញុំមានការចាប់អារម្មណ៍ខ្លាំងចំពោះមុខវិជ្ជានីតិរដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដែលនៅក្នុងនោះចំណុចដែលគួរឲ្យចាប់អារម្មណ៍ជាងគេ គឺពាក់ព័ន្ធទៅនឹង បញ្ហានៃការលែងលះដោយមានបុគ្គលខ្លះព្រមព្រៀងលែងលះ និងបុគ្គលខ្លះទៀតមិនយល់ព្រមលែងលះដែលបង្កើតទៅជាបញ្ហាស្មុគស្មាញនៅក្នុងសង្គម។ ចំពោះស្នាដៃនៃការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំមានចំណាប់អារម្មណ៍ក្នុងការចងក្រងជាឯកសារថ្មីមួយ ដោយសារបញ្ហាលែងលះតែងតែកើតមានឡើងជាញឹកញ៉ាប់ យើងខ្ញុំចង់ឲ្យស្នាដៃថ្មីមួយនេះ ជាឯកសារជំនួយដល់អ្នកដែលកំពុងសិក្សាជំនាញនីតិសាស្ត្រ ព្រមទាំងអ្នកដែលចូលចិត្តស្រាវជ្រាវអាចទទួលបាននូវគំនិតថ្មីៗដែលយើងខ្ញុំបានចងក្រងឡើងនៅក្នុងសៀវភៅនេះ។

ចំពោះការលែងលះនេះមានការចែកចេញជាពីរគឺ ការលែងលះដោយការព្រមព្រៀង និងការលែងលះដោយមិនព្រមព្រៀង។ កាលពីមុនគឺមានការលែងលះដោយគ្មានការព្រមព្រៀងច្រើន តែនាពេលបច្ចុប្បន្ននេះ យើងខ្ញុំឃើញថា មានការលែងលះដោយមានការព្រមព្រៀងគ្នាសឹងតែប្រហាក់ប្រហែលនឹងការលែងលះដោយគ្មានការព្រមព្រៀងដែរ។ ការលែងលះដោយការមិនព្រមព្រៀងគឺមានការកើតឡើងជាច្រើន ប៉ុន្តែយើងខ្ញុំចង់ផ្តោតទៅលើការលែងលះដោយការព្រមព្រៀងតែប៉ុណ្ណោះមកធ្វើជាសារណា ក្នុងការបិទបញ្ចប់ថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំទាំងពីរនាក់។ យើងខ្ញុំអាចធ្វើការចងក្រងជាស្នាដៃស្រាវជ្រាវប្រធានបទ **"នីតិវិធីនៃការលែងលះដោយការព្រមព្រៀង"** នេះឡើងបានយ៉ាងរលូនក្រោមការជួយជ្រោមជ្រែងយ៉ាងខ្លាំងពី **លោក ឡោ សហី**។

ក្នុងស្នាដៃសារណានេះផងដែរ ត្រូវបានធ្វើការបែងចែកជា ៤ជំពូក ដែលទាក់ទងនឹងនីតិវិធីលែងលះដោយការព្រមព្រៀង។ ការស្រាវជ្រាវនៅលើប្រធានបទ នីតិវិធីនៃការលែងលះដោយការព្រមព្រៀង នេះផងដែរ មានគោលបំណងក្នុងការបង្ហាញអំពីដំណើរការនៅក្នុងនីតិវិធីនៃការលែងលះឲ្យបានលំអិតពីមួយដំណាក់កាលទៅមួយដំណាក់កាល និងចូលរួមលើកស្ទួយការអនុវត្តនៅក្នុងប្រព័ន្ធយុត្តិធម៌ឲ្យកាន់តែមានប្រសិទ្ធិភាព។

ដោយហេតុថា យើងខ្ញុំបានមើលឃើញពីសារៈសំខាន់នៃនីតិវិធីនៃការលែងលះដោយការព្រមព្រៀងនេះ យើងខ្ញុំចង់ឲ្យស្នាដៃមួយនេះមានតម្លៃជាគតិក្នុងការសិក្សាស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗទៀត និងអ្នកច្បាប់មួយចំនួនក្នុងការស្វែងយល់ពីនីតិវិធីបែបនេះ។ ចំពោះការស្រាវជ្រាវពីប្រធានបទនេះ យើងខ្ញុំបានខិតខំ

ព្យាយាមស្វែងរកនូវចំណុចសំខាន់ៗដែលកើតមានឡើងក្នុងពេលបច្ចុប្បន្នមកដាក់បញ្ចូលដើម្បីធ្វើឲ្យប្រធានបទមួយនេះកាន់តែទូលំទូលាយ និងងាយស្រួលសម្រាប់មិត្តអ្នកអាន។

ប៉ុន្តែទោះជាយ៉ាងណានៅក្នុងឯកសារមួយនេះ អាចនឹងមិនទាន់មានភាពល្អឥតខ្ចោះនោះទេ យើងខ្ញុំសូមធ្វើការសូមទោស នូវរាល់កំហុសឆ្គងទាំងឡាយដែលបានកើតមានឡើងក្នុងស្នាដៃមួយនេះ ដោយអចេតនាក្នុងកិច្ចអធិប្បាយ និង អក្ខរាវិរុទ្ធ ហើយក៏សូមទទួលយកនូវការរិះគន់នានាពីសំណាក់មិត្តអ្នកអាន លោកសាស្ត្រាចារ្យ និងនិស្សិតក្នុងន័យស្ថាបនាផងដែរ ។ ជាចុងក្រោយ យើងខ្ញុំ សូមអរគុណយ៉ាងក្រៃលែងចំពោះអ្នកដែលបានចូលរួមអាន និងចូលចិត្តស្នាដៃមួយនេះ យើងខ្ញុំសូមគោរពជូនពរដល់អ្នកទាំងអស់គ្នាឲ្យមានសុខភាពល្អ និងទទួលបានភាពជោគជ័យគ្រប់ភារកិច្ច។

# មាតិកា


**សេចក្តីផ្តើម** ........ ១

## ជំពូកទី១៖ សញ្ញាណទូទៅនៃការលែងលះ

**១.១ សញ្ញាណទូទៅ** ........ ៣

**១.២ និយមន័យនៃការលែងលះ** ........ ៤

**១.៣.មូលហេតុនៃការលែងលះ** ........ ៥

១.៣.១ មូលហេតុនៃការលែងលះនៅក្នុងសង្គមខ្មែរ ........ ៥

១.៣.១.១ ការទទួលរងអំពើហិង្សាទាំងផ្លូវកាយនិងផ្លូវចិត្ត ........ ៥

១.៣.១.២ ការមិនមានភាពស្មោះត្រង់រវាងសហព័ទ្ធ ........ ៥

១.៣.១.៣ ការរៀបការនៅវ័យក្មេងពេក ........ ៦

១.៣.១.៤ ការប្រច័ណ្ឌហួងហែងពេក ........ ៧

១.៣.១.៥ កង្វះការយោគយល់អធ្យាស្រ័យ ........ ៧

១.៣.១.៦ បញ្ហាលុយកាក់ ........ ៨

ក. ផលប្រយោជន៍ ........ ៨

ខ. ការផ្គត់ផ្គង់គ្រួសារ ........ ៨

១.៣.២ មូលហេតុដែលមានចែងក្នុងច្បាប់ ........ ៩

១.៣.២.១ អំពើផិតលើសហព័ទ្ធ ........ ៩

១.៣.២.២ អំពើស្មន់ ........ ៩

១.៣.២.៣ ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុ ........ ១០

១.៣.២.៤ ការបាត់ខ្លួនរបស់សហព័ទ្ធដោយមិនដឹងថាស្លាប់ឬរស់ ........ ១០

១.៣.២.៥ សហព័ទ្ធរស់នៅបែកគ្នាជាបន្តបន្ទាប់ជាង១ឆ្នាំ ........ ១០

១.៣.២.៦ ករណីផ្សេងៗដែលមិនអាចធ្វើបដិទានបាន ........ ១១

១.៣.២.៧ ការប្រើអំពើហិង្សា ........ ១១

១.៣.៣ មូលហេតុនៃការលែងលះដោយការព្រមព្រៀង ........ ១២

១.៣.៣.១ សហព័ទ្ធអស់មនោសញ្ចេតនា ........ ១២

១.៣.៣.២ ការរស់នៅមិនចុះសម្រុងនឹងគ្នា ........ ១២

១.៣.៣.៣ បញ្ហាសាច់ញាតិបងប្អូនខាងប្តី រឺប្រពន្ធ ........ ១៣

**១.៤ កម្មវត្ថុនៃការលែងលះ** ........ ១៤

**១.៥ ការកំណត់និង បែងចែកទ្រព្យសម្បត្តិ** ........ ១៤

១.៥.១ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ........ ១៤

១.៥.២ ប្រព័ន្ធទ្រព្យសម្បត្តិកំណត់ដោយច្បាប់ ........ ១៥

១.៥.២.១ ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ........ ១៥

១.៥.២.២ ប្រព័ន្ធទ្រព្យសម្បត្តិរួម ........ ១៦

១.៥.៣ ការព្រមព្រៀងអំពីអំណាចមេបាលើកូន ........ ១៧

**ជំពូកទី២៖ នីតិវិធីនៃការលែងលះដោយការព្រមព្រៀង**

**២.១ ការដាក់ពាក្យសុំលែងលះដោយការព្រមព្រៀង** ........ ១៨

២.១.១ ការដាក់ពាក្យសុំដោយលាយលក្ខណ៍អក្សរ ........ ១៨

២.១.២ ការដាក់ពាក្យសុំដោយផ្ទាល់មាត់ ........ ១៨

២.១.៣ ឯកសារភ្ជាប់សម្រាប់ការដាក់ពាក្យសុំ ........ ១៩

២.១.៣.១ កិច្ចសន្យាព្រមព្រៀង ........ ១៩

២.១.៣.២ សំបុត្រអាពាហ៍ពិពាហ៍ ........ ១៩

២.១.៣.៣ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ១៩

២.១.៣.៤ ការស្រាវជ្រាវពិនិត្យភស្តុតាងផ្សេងៗ ........ ២០

២.១.៤ ការបង់ពន្ធដាក់ពាក្យសុំ ........ ២០

២.១.៥ សោហ៊ុយនីតិវិធី ........ ២១

២.១.៦ ការទាញហេតុផលដោយផ្ទាល់មាត់ ........ ២១

២.១.៧ ការកោះហៅ ........ ២២

**២.២ ការចេញសេចក្តីសម្រេចដោយតុលាការ** ........ ២២

២.២.១ ដីកាសម្រេច ........ ២២

២.២.២ បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេច ........ ២៣

**ជំពូកទី៣៖ សិទ្ធិនិង ភាតព្វកិច្ចក្រោយការលែងលះ**

**៣.១ ទំនាក់ទំនងចំពោះភាគី** ........ ២៥

៣.១.១ ទំនាក់ទំនងរវាងកូននិងឪពុកម្តាយ ........ ២៥

៣.១.២ ករណីយកិច្ចអ្នកមានអំណាចមេបាលើកូន ........ ២៥

៣.១.៣ ករណីយកិច្ចរបស់អ្នកគ្មានអំណាចមេបា........................................................................................ ២៥
៣.១.៤ ការផ្លាស់ប្តូរអ្នកមានអំណាចមេបា................................................................................................ ២៦
៣.១.៤.១ វិបល្លាសស្មារតី ................................................................................................ ២៧
៣.១.៤.២ ករណីមានជំងឺ ................................................................................................ ២៧
៣.១.៤.៣ ការប្រើអំពើហិង្សា................................................................................................ ២៨
៣.១.៤.៤ បញ្ហាសេដ្ឋកិច្ច ................................................................................................ ២៨
៣.១.៥ សិទ្ធិក្នុងការប្រើប្រាស់នាមត្រកូលសហព័ទ្ធក្នុងច្បាប់ ................................................................ ២៩
៣.១.៦ សិទ្ធិក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មី................................................................................ ២៩
៣.១.៧ អានុភាពចំពោះទ្រព្យសម្បត្តិ................................................................................................ ២៩
៣.១.៧.១ ទ្រព្យសម្បត្តិរួម ................................................................................................ ៣០
៣.១.៧.២ ទ្រព្យសម្បត្តិដោយឡែក................................................................................................ ៣០
៣.១.៧.៣ ទ្រព្យសម្បត្តិតាមកិច្ចសន្យា................................................................................................ ៣០
៣.១.៧.៤ ទ្រព្យសម្បត្តិតាមការព្រមព្រៀង................................................................................................ ៣១
៣.១.៨ ទ្រព្យសម្បត្តិរបស់កូន ................................................................................................ ៣១
**៣.២ ភាតព្វកិច្ចក្រោយការលែងលះ** ................................................................................................ ៣២
៣.២.១ ការបង់សោហ៊ុយចាំបាច់ដើម្បីថែទាំកូន ................................................................................................ ៣២
៣.២.១.១ អាហារកិច្ចចំពោះកូន ................................................................................................ ៣៣
៣.២.១.២ អាហារកាតព្វកិច្ច ................................................................................................ ៣៣
ក.ចំពោះឪពុកម្តាយ ................................................................................................ ៣៤
ខ.ចំពោះសាច់ញាតិ ................................................................................................ ៣៤
៣.២.២ ការបញ្ចប់ករណីយកិច្ចសហព័ទ្ធ ................................................................................................ ៣៤
៣.២.៣ កាតព្វកិច្ចចំពោះតតិយជន ................................................................................................ ៣៥
៣.២.៣.១ កាតព្វកិច្ចរួមគ្នា ................................................................................................ ៣៥
៣.២.៣.២ កាតព្វកិច្ចដោយឡែក ................................................................................................ ៣៥
**សេចក្តីសន្និដ្ឋាន** ................................................................................................ ៣៧
**អនុសាសន៍** ................................................................................................ ៣៨
**ឯកសារយោង**
**ឧបសម្ព័ន**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ជាប្រទេសមួយដែលបានប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ពោលគឺ អំណាចរបស់រដ្ឋត្រូវបែងចែកជា បី រួមមាន៖ អំណាចនីតិប្រតិបត្តិ អំណាចនីតិប្បញ្ញត្តិ និង អំណាច តុលាការ។ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងនៅក្នុងការ បង្កើតច្បាប់ សម្រាប់ជាការការពារផលប្រយោជន៍ សាធារណៈ រក្សាសន្តិសុខសង្គម តាមរយៈការបង្កើតឲ្យមាន ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងគោលបំណង ដើម្បីថែរក្សា ស្ថេរភាព របស់សង្គមឲ្យមាន ភាពសុខសន្តិភាព នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។ ដូច្នេះ ហើយដើម្បីចូលរួមបង្ការ ទប់ស្កាត់ នូវការលែងលះដែលកើតមាន ទើបរាជរដ្ឋាភិបាល ក្រើនរំលឹកដល់មន្ត្រី អនុវត្តច្បាប់ត្រូវរឹតបន្តឹងក្នុងការអនុវត្តច្បាប់ឲ្យបានម៉ឺងម៉ាត់ និង ម៉ត់ចត់បំផុត។

បន្ទាប់ពីការសិក្សាស្រាវជ្រាវ រយៈពេលកន្លងមកនេះ យើងខ្ញុំបានកំណត់នូវចំណុចសំខាន់ ក៏ដូចជានីតិវិធីទាក់ទងទៅនឹង **នីតិវិធីនៃការលែងលះដោយការព្រមព្រៀង** របស់គូរភាគីនិងតុលាការ ដែលទាំងនោះគឺសុទ្ធសឹងតែជាចំណុចសំខាន់ដែលមាននៅក្នុងប្រធានបទនេះ ។ បុព្វហេតុ ដែលនាំឲ្យក្រុមយើងខ្ញុំជ្រើសរើសយកនូវប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ គឺដើម្បីទទួលបាននូវចំណេះដឹងបន្ថែមទៀតតាមរយៈការពិនិត្យទៅលើច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងទទួលបានបទពិសោធន៍ពី លោកគ្រូសាស្ត្រាចារ្យ ដែលមានជំនាញផ្នែករដ្ឋប្បវេណី និងការយល់ដឹងពីនីតិវិធីនៃការលែងលះដោយការព្រមព្រៀង បញ្ហាប្រឈមមួយចំនួននៅក្នុងការអនុវត្តជាក់ស្តែងរបស់តំណាងអយ្យការនាពេលកន្លងមកនេះ ។

នៅក្នុងការស្រាវជ្រាវនេះផងដែរ គឺយើងខ្ញុំមានគោលបំណងដើម្បីយកទៅអនុវត្តការងារជាក់ស្តែង និង ការពង្រឹងនូវចំណេះដឹងក្នុងសកលវិទ្យាល័យ ធ្វើការផ្សារភ្ជាប់ជាមួយនឹងការអនុវត្តជាក់ស្តែង ព្រមទាំងចូលរួមចែករំលែក និង ការកែលម្អទៅលើចំណុចមួយចំនួនដែលនៅមានការខ្វះខាត ដើម្បីសម្រេចបាននូវប្រសិទ្ធិភាពនៃការស្រាវជ្រាវ និងប្រកបដោយចីរភាព ។

នៅក្នុងគោលបំណងនៃការស្រាវជ្រាវទៅលើប្រធានបទ នីតិវិធីនៃការលែងលះដោយការព្រមព្រៀង មានចំណុចសំខាន់មួយចំនួនដូចជា៖

- ស្វែងយល់ពីដំណើរការនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
- យល់ដឹងពីនីតិវិធីនៃការលែងលះដោយការព្រមព្រៀង
- បញ្ហាប្រឈមនៅក្នុងគ្រួសារ និងសង្គមកម្ពុជា

- ស្វែងយល់ពីដំណើរការនៃនីតិវិធីរបស់តុលាការ

យោងទៅតាមបញ្ហាគតិយុត្ត ដែលបានលើកឡើងខាងលើ និង ឆ្លងតាមរយៈការស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទរយៈពេលកន្លងមកនេះ យើងខ្ញុំបានបែងចែកចេញជា ៣ (បី) ជំពូក រួមមាន៖

ជំពូកទី១៖ សញ្ញាណទូទៅនៃការលែងលះ

ជំពូកទី២៖ នីតិវិធីនៃការលែងលះដោយការព្រមព្រៀង

ជំពូកទី៣៖ សិទ្ធិ និងកាតព្វកិច្ចក្រោយការលែងលះ។

# ជំពូកទី១៖ សញ្ញាណទូទៅនៃការលែងលះ

# ជំពូកទី១៖ សញ្ញាណទូទៅនៃការលែងលះ

## ១.១ សញ្ញាណទូទៅ

ការរៀបអាពាហ៍ពិពាហ៍ត្រូវបានកំណត់ថាជា កិច្ចសន្យាដែលធ្វើឡើងដោយបុរសនិងនារីដែលសម្រេចចិត្តច្បាស់ថាបង្កើតចំណងគតិយុត្តរួមគ្នាក្នុងនាមជាសហព័ទ្ធហើយព្រមរួមរស់នៅជាមួយគ្នាដោយគ្មានការបង្ខិតបង្ខំ។[1] អាពាហ៍ពិពាហ៍នេះនឹងមានអានុភាព ហើយត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់នៅពេលដែលអ្នកទាំងពីរបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។[2]

ការចុះសំបុត្រអាពាហ៍ពិពាហ៍ត្រូវធ្វើឡើង ដោយគោរពទៅតាម នីតិវិធីនៃការចុះសំបុត្រអាពាហ៍ពិពាហ៍រួមមានលក្ខខណ្ឌសំខាន់ៗហើយភាគី ត្រូវធ្វើតាមលំដាប់លំដោយ អនាគត កូនកម្លោះ ត្រូវដាក់ពាក្យសុំទៅឃុំ-សង្កាត់ ដែលខ្លួនរស់នៅ ដើម្បីឲ្យមេឃុំ-ចៅសង្កាត់ ចេញសេចក្តីបញ្ជាក់ថា ខ្លួនពិតជាមិនមានជាប់ ចំណងអាពាហ៍ពិពាហ៍ចាស់ណាមួយមែន (នៅលីវ ឬពោះម៉ាយ) ប្រសិនបើជាពោះម៉ាយដោយការលែងលះ ត្រូវមានដីកាតុលាការ អំពីការលែងលះ។ ប្រសិនបើជាពោះម៉ាយ ដោយប្រពន្ធស្លាប់ ត្រូវមាន លិខិតមរណភាពរបស់សពប្រពន្ធ។ ក្រោយពីបានលិខិតបញ្ជាក់ ពីមេឃុំ-ចៅសង្កាត់រួចហើយ ភាគីខាងប្រុស ត្រូវយកលិខិតនេះ ព្រមទាំងសំណុំបែបបទមួយទៀត បំពេញដោយភាគី ខាងស្រី ដាក់ជូនទៅសាលាឃុំ-សង្កាត់ខាងស្រី។ មន្ត្រីអត្រានុកូលដ្ឋាន នៅឃុំ-សង្កាត់ខាងស្រី ជាអ្នកចេញសេចក្តីប្រកាសជូនដំណឹងអាពាហ៍ពិពាហ៍ ដើម្បីយកទៅបិទ នៅផ្ទះខាងស្រី ហើយសេចក្តីចម្លងមួយច្បាប់ទៀតយកទៅបិទនៅផ្ទះខាងប្រុស។ ក្នុងរយៈពេល ១០ថ្ងៃ ប្រសិនបើមិនមានការតវ៉ាជំទាស់ណាមួយទេ ការ ធ្វើពិធីអាពាហ៍ពិពាហ៍តាមទំនៀមទម្លាប់ប្រពៃណីអាចរៀបចំធ្វើទៅបាន។ ក្រោយ ពិធីអាពាហ៍ពិពាហ៍នេះ (យ៉ាងយូរ ១ខែ) គូរស្វាមី ភរិយាថ្មីថ្មោង នេះ ត្រូវត្រឡប់ទៅសាលាឃុំ-សង្កាត់ ខាងស្រីវិញ ដើម្បីផ្តិតមេដៃក្នុង សៀវភៅអត្រានុកូលដ្ឋាន ហើយមេឃុំ-ចៅសង្កាត់ ចេញសំបុត្រអាពាហ៍ ពិពាហ៍ជាផ្លូវការជូន។ នៅក្នុងការចុះសំបុត្រអាពាហ៍ ភាគីទាំងពីរត្រូវមានសាក្សី យ៉ាងតិចពីររូប (ម្នាក់សម្រាប់ខាងស្រី និង ម្នាក់សម្រាប់ខាងប្រុស) សាក្សីនេះនេះអាចជាឪពុកម្តាយ ឬជាសាច់ញាតិ ឬជាមិត្តភក្តិណាម្នាក់ (មានវ័យគ្រប់ការ)។ អាពាហ៍ពិពាហ៍ដែលត្រូវបានទទួលស្គាល់ដោយច្បាប់គឺជាចំណងគតិយុត្ត សហព័ទ្ធមិនអាចបញ្ចប់ទំនាក់ទំនងនេះតាមទំនើងចិត្តនោះទេ គឺទាមទារអោយភាគីដែលមានឆន្ទៈចង់បញ្ចប់ទំនាក់ទំនងគតិយុត្តនឹងគ្នាត្រូវធ្វើការលែងលះតាមផ្លូវតុលាការទើបមានអានុភាព។

[1] មាត្រា៣ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩

[2] មាត្រា៩៥៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្រោយពេលដែលកើតមានចំណងអាពាហ៍ពិពាហ៍ភាគីសហព័ទ្ធបានបង្កើតនូវចំណងរវាងគ្នានឹងគ្នាជាច្រើនដូចជា ការប្រើនាមត្រកូល មានកូន ទ្រព្យសម្បត្តិរួម កាតព្វកិច្ច និង សិទ្ធិ ដូចនេះនៅពេលដែលភាគីលែងលះគ្នា ចំណងទាំងអស់នឹងត្រូវធ្វើការបែងចែកទៅតាមសិទ្ធិដែលខ្លួនត្រូវទទួលបាន។

## ១.២ និយមន័យនៃការលែងលះ

ការផ្តាច់ ឬ រំលាយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់រវាងប្តី ប្រពន្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានគឺជា ការលែងលះគ្នា។ ដូចដែលបានដឹងមកហើយថាបុរសនារី បើគ្រាន់តែរៀបចំពិធីសែនព្រេនតាមទំនៀមទំលាប់ប្រពៃណីឬពិធីសាសនាណាមួយដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវទេនោះ គេមិនបានចាត់ទុកថាមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់នោះទេការរួមរស់នៅជាមួយគ្នាបែបនេះ ត្រូវបានហៅថា អនីតិសង្វាស ហើយការរស់នៅបែបអនីតិសង្វាសបែបនេះប្រសិនបើបុរសនារីអស់មនោសញ្ចេតនារួមរស់នៅជាមួយគ្នាហើយគ្រាន់តែសម្រេចចិត្តដើរចេញពីគ្នា ឬរស់នៅបែកគ្នាជាការស្រេច។ ចំពោះបុរសនារីដែរមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់នៅពេលដែលសម្រេចចិត្តថាលែងលះគ្នាឬរំលាយចំណងអាពាហ៍ពិពាហ៍គឺត្រូវធ្វើឡើងតាមផ្លូវតុលាការ។ ម្យ៉ាងទៀតក៏មិនខុសពីការរៀបអាពាហ៍ពិពាហ៍ដែរ ការលែងលះនឹងធ្វើអោយមានការផ្លាស់ប្តូរឋានៈរបស់បុគ្គលពាក់ព័ន្ធនៅក្នុងសង្គម។

នៅក្នុងការលែងលះចំពោះចំណងអាពាហ៍ពិពាហ៍ស្របច្បាប់មាន០២ប្រភេទគឺ ការលែងលះដោយការព្រមព្រៀង និងការលែងលះដោយមានមូលហេតុ។[3] ចំពោះការលែងលះដោយការព្រមព្រៀង ប្រសិនបើគូរភាគី (ប្តីប្រពន្ធ) ព្រមព្រៀងគ្នាថាពួកគេមិនអាចរួមរស់នៅជាមួយគ្នាទៀត បានអនុញ្ញាតអោយភាគីអាចដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបាន ហើយបើតុលាការរកឃើញថា ភាគីមានឆន្ទៈព្រមព្រៀងគ្នាពិតប្រាកដក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍តុលាការត្រូវតែសម្រេចអោយភាគីលែងលះគ្នាតាមរយៈការចេញដីកាសម្រេច។[4] ចំណែកឯការលែងលះដោយមានមូលហេតុ សំដៅទៅដល់ភាគីមិនមានឆន្ទៈនៅក្នុងការលែងលះទេ ពោលគឺភាគីម្ខាង ប្តីឬប្រពន្ធ សម្រេចចិត្តថាមិនអាចរស់នៅជួបជុំគ្នាបានដោយមូលហេតុផ្សេងៗ ប៉ុន្តែជាការសម្រេចចិត្តរបស់ភាគីតែម្ខាង ។

[3] មាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[4] មាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ១.៣.មូលហេតុនៃការលែងលះ

### ១.៣.១ មូលហេតុនៃការលែងលះនៅក្នុងសង្គមខ្មែរ

#### ១.៣.១.១ ការទទួលរងអំពើហិង្សាទាំងផ្លូវកាយនិងផ្លូវចិត្ត

ជាការពិតណាស់ ប្រសិនបើចំណងអាពាហ៍ពិពាហ៍ដែលបានបង្កើតឡើងពោរពេញទៅដោយក្តីស្រលាញ់និងការយល់ព្រម មិនមានការបង្ខិតបង្ខំនោះ នឹងធ្វើអោយគ្រួសារមានតែសុភមង្គល ។ គ្រាន់តែការរស់នៅមិនចុះសម្រុងគ្នាជារឿងមួយដែលពិបាកស្រាប់ទៅហើយ ប៉ុន្តែបើសហព័ទ្ធមិនចេះទប់អារម្មណ៍បញ្ចេញកំហឹងដាក់គ្រួសារ នោះនឹងបង្កើតទៅជាការប្រើអំពើហិង្សា វាយដំ ទាត់ធាក់ ជេរប្រមាថ ចោទប្រកាន់ដែលបង្កឡើងពីមូលហេតុផ្សេងៗ ដែលនាំអោយមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផ្លូវកាយនិង ផ្លូវចិត្ត ។ នៅក្នុងសង្គមបច្ចុប្បន្ននេះអំពើហិង្សាក្នុងគ្រួសារកើតមានគ្រប់ស្រទាប់វណ្ណៈមិនថា អ្នកមានលុយ អ្នកធ្វើការតូចធំ អ្នកក្រខ្សត់មិនសូវមានចំណេះដឹង ភាគច្រើនមិនចេះទប់កំហឹងឡើយ ពេលគឺពេលមានរឿងពីខាងក្រៅផ្ទះតែមកជះកំហឹងដាក់អ្នកផ្ទះ។ មួយចំនួនទៀតកើតចេញពីការផឹកស្រវឹងបាត់បង់អស់ស្មារតី មកដល់ផ្ទះប្រពន្ធសួរនាំតិចតួចរករឿង វាយធ្វើបាប ពេលខ្លះក៏ជ្រុលដៃ ជ្រុលជើងកើតទៅជារបួសស្នាម ដល់ថ្នាក់សហព័ទ្ធម្ខាងទៀតទ្រាំមិនបានក៏ឈានដល់ការលែងលះគ្នា។

ឧទាហរណ៍៖ ណារី បានរៀបការជាមួយ សុខា អ្នកទាំងពីររស់នៅជាមួយគ្នាដោយមានជីវភាពមធ្យម។ មិនបាន១ឆ្នាំផង សុខា ចេះតែដើរផឹកស៊ីជាមួយមិត្តភក្តិស្ទើររាល់យប់ ដែលធ្វើឲ្យណារីមិនសប្បាយចិត្តសោះ។ រាល់ពេលត្រឡប់មកពីក្រៅវិញ មកដល់ផ្ទះស្រវឹងជោគជាំ តែងតែលើកយករឿងនេះនោះមកនិយាយធ្វើឲ្យមានរឿង ពេលខឹងបោកចាន បោកឆ្នាំង ផ្អើលអស់អ្នកជិតខាង ពេលខ្លះក៏វាយណារីជាំមុខ បែកក្បាលក៏មាន។ ណារីរស់នៅក្រោមភាពភ័យខ្លាច ថែមទាំងអារម្មណ៍មិននៅនឹងខ្លួនភ័យៗ ខ្លាចៗ ដោយណារីមិនអាចទ្រាំទៀតបាន នាងក៏បានសុំលែងលះជាមួយសុខា ដើម្បីសេរីភាព និង ចាកចេញពីប្តីដ៏ឃោរឃៅម្នាក់នេះ។

#### ១.៣.១.២ ការមិនមានភាពស្មោះត្រង់រវាងសហព័ទ្ធ

ភាពស្មោះត្រង់ជាចំណុចសំខាន់មួយផងដែរនៅក្នុងការសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍របស់បុរសនិងនារី ប្រសិនបើភាគីមិនមានភាពស្មោះត្រង់ទេ នឹងធ្វើអោយចំណងអាពាហ៍ពិពាហ៍បែកបាក់ដោយសារមិនសូវមានទំនាក់ទំនងល្អនឹងគ្នាដែលបញ្ហាទាំងនោះបណ្តាលមកពីមូលហេតុជាច្រើនដូចជា ការមិនទុកចិត្តគ្នា មិនឲ្យតម្លៃគ្នា កុហកបោកប្រាស់ជាច្រើនលើកច្រើនសារ ការក្បត់ចិត្តម្តងហើយម្តងទៀត ព្រមទាំងការមិនចេះទទួលស្គាល់កំហុស រហូតដល់បាត់បង់ទំនុកចិត្តទាំងស្រុង ។

ឧទាហរណ៍៖ គង់ និង ចិន្តា បានសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដោយសង្ឃឹមថាអាចកសាងគ្រួសារដ៏ល្អមួយព្រមទាំងរស់នៅប្រកបដោយសេចក្តីសុខ។ ប៉ុន្មានឆ្នាំកន្លងផុតទៅ ការបង្កើតគ្រួសាររបស់អ្នកទាំងពីរមិនបានជោគជ័យដូចការគ្រោងទុកទេ អ្នកទាំងពីរចេញពីផ្ទះទៅធ្វើការរៀងៗខ្លួន ថ្ងៃមួយចិន្តាបានឃើញ គង់ ជិះរថយន្តឌុបនារីម្នាក់ ។ ពេលមកដល់ផ្ទះចិន្តាបានសួរនាំ គង់ អំពីរឿងដែលនាងបានឃើញ ព្រោះនាងមិនមានទំនុកចិត្តលើ គង់ ទេព្រោះ គង់ ធ្លាប់បានកុហកនាងជាច្រើនដង ហើយលើកនេះគង់ ក៏បានប្រាប់ថានារីនោះជាមិត្តរួមការងាររបស់ខ្លួនទេ ប៉ុន្តែចិន្តាមិនជឿទៀតឡើយ នាងគិតថាគង់ និយាយកុហកនាងដដែលៗ ។ ចិន្តា និង គង់ យល់ព្រមលែងលះគ្នាដោយចិន្តា មិនមានទំនុកចិត្ត ចំណែក គង់ គិតថាចិន្តា មិនឲ្យតម្លៃលើខ្លួន។

**១.៣.១.៣ ការរៀបការនៅវ័យក្មេងពេក**

ការមិនទទួលបានការសិក្សាអប់រំនិងការរស់នៅក្នុងភាពក្រីក្រគឺជាកត្តាហានិភ័យខ្ពស់ក្រោយពេលដែលសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ ជាពិសេសគឺចំពោះនារីៗខ្លះទៀតក៏ទទួលបានការយល់ព្រមពីឪពុកម្តាយដែលពួកគេទើបតែមានវ័យ១៥ឆ្នាំប៉ុណ្ណោះ។ ការរៀបការនៅវ័យក្មេងជាការរួមចំណែកដល់ការប្រើអំពើហិង្សាក្នុងគ្រួសារ ពេលខ្លះក៏ជឿតាមពាក្យសំដីគេនិយាយថាប្តីវាយប្រពន្ធព្រោះគេមានហេតុផលរបស់គេ បន្ថែមពីនេះទៀតនារីដែលរៀបការវ័យក្មេងគឺមានផលលំបាកចំពោះសុខភាពក្នុងពេលមានផ្ទៃពោះ ព្រមទាំងពិបាកក្នុងការថែទាំកូនទៀតផង។ បុរសនិងនារីដែលឈានដល់ការសម្រេចចិត្តថា នឹងរៀបការគួរតែបានត្រៀមខ្លួនរួចជាស្រេចទៅលើចំណុចជាច្រើនដែលត្រូវទទួលរងក្រោយពេលបង្កើតគ្រួសារ មិនត្រូវរៀបការនៅវ័យក្មេងពេកទេ បើរៀបការនៅវ័យក្មេងពេកមិនអាចគ្រប់គ្រងគ្រួសារបានល្អនោះទេដែលអាចនឹងបង្កអោយមានការសម្រេចចិត្តខុស អត្រានៃការបែកបាក់គ្នាក៏ឆាប់រហ័សផងដែរ ។

ឧទាហរណ៍៖ លី និង ឡា បានស្រលាញ់គ្នានៅពេលរៀនថ្នាក់ទី១០ជាមួយគ្នា ។ អ្នកទាំងពីរនៅក្មេងណាស់អាយុទើបតែ ១៩ឆ្នាំប៉ុណ្ណោះ ដោយសារក្តីស្រលាញ់អ្នកទាំងពីរមិនបានគិតច្រើនទេ ណាមួយគ្រួសារក្រីក្ររៀនសូត្រក៏មិនបានច្រើនផងធ្វើឲ្យគំនិតខ្លី ក៏បានរៀបការជាមួយគ្នាហើយឈប់រៀនដោយមិនបានគិតវែងឆ្ងាយពីអនាគតនោះទេ។ លី ធ្វើជាងប៉ះកង់ ចំណែក ឡា នៅមើលកូន មិនបានប៉ុន្មានឆ្នាំផង លី ចេះផឹកស្រាហើយវាយធ្វើបាប ឡា ព្រោះខឹង ឡា មិនជួយធ្វើការរកស៊ីគិតតែដេកមើលកូន ។ តែ ឡា ក៏មិនបាននៅស្ងៀមដែរបានស្រែក ជេរគ្នា ផ្តើលអស់គេឯង យូៗទៅនាងទ្រាំមិនបានក៏ធ្វើការលែងលះគ្នា ហើយក្លាយជាមេម៉ាយទាំងវ័យក្មេង។

### ១.៣.១.៤ ការប្រច័ណ្ឌហួងហែងពេក

ការប្រច័ណ្ឌកើតឡើងដោយសារអារម្មណ៍ខឹងឬអារម្មណ៍ដែលគ្មានសុវត្ថិភាព បារម្ភហួងហែងចំពោះការបាត់បង់ ឬគ្រាន់តែជាការយល់ច្រឡំទៅកាន់ភាគីប្តីឬប្រពន្ធដោយគ្មានមូលហេតុត្រឹមត្រូវដែលបង្កអោយមានផលប៉ះពាល់ដល់បុគ្គលខ្លួនឯង ដៃគូរប្តីប្រពន្ធព្រមទាំងគ្រួសារផងដែរ។ កាលណាប្តី ឬប្រពន្ធមិនទុកចិត្តដៃគូម្ខាងទៀត ហើយមានភាពប្រច័ណ្ឌហួងហែង ដើរទៅនេះទៅនោះមិនបាន ជួបជុំអ្នកស្គាល់គ្នាក៏មិនបាន ជាលទ្ធផលភាគីម្ខាងទៀតនឹងមិនអាចទ្រាំជាមួយអារម្មណ៍ដែលដេកតែពិបាកចិត្ត ភ័យព្រួយជាមួយនឹងរឿងដដែលបានទេ ពួកគេនឹងរកវិធីដើម្បីនិយាយគ្នារកដំណោះស្រាយល្អៗ តែប្រសិនបើមិនមានដំណោះស្រាយទេនោះ ការលែងលះអាចជាវិធីដែលល្អបំផុតព្រោះមិនអាចបន្តចំណងអាពាហ៍ពិពាហ៍នេះបាន។

ឧទាហរណ៍៖ លោក ញ៉ា និងលោកស្រី ភី ពិតជាស្រឡាញ់គ្នាខ្លាំងណាស់ទាំងមុន ទាំងក្រោយពេលរៀបការ។ ដោយសារតែលោក ញ៉ាមានចិត្តស្រឡាញ់ប្រពន្ធខ្លាំងពេក គាត់មិនចង់ឲ្យលោកស្រី ភី ទៅធ្វើការនៅភោជនីយដ្ឋានទៀតឡើយ។ គាត់ចង់ឲ្យលោកស្រី ភី នៅតែផ្ទះប៉ុណ្ណោះ ព្រោះតែគាត់ប្រច័ណ្ឌប្រពន្ធគាត់ជាមួយភ្ញៀវ និងបុគ្គលិកដែលស្និតស្នាលនឹងគាត់។ ទោះបីជាលោកស្រី ភី ខំពន្យល់ប្តីគាត់យ៉ាងណា ក៏ប្តីមិនព្រមស្តាប់ដែរ ហើយបង្កឲ្យមានការឈ្លោះទាស់ទែងគ្នាយ៉ាងខ្លាំង។ លោកស្រី ភី មិនអាចទ្រាំទ្រនឹងទង្វើរបស់ប្តីរបស់ខ្លួនតទៅទៀត ដូច្នេះគាត់ក៏បានសម្រេចចិត្តថានឹងលែងលះគ្នា។

### ១.៣.១.៥ កង្វះការយោគយល់អធ្យាស្រ័យ

នៅក្នុងទំនាក់ទំនងប្តីប្រពន្ធអាចកើតមានបញ្ហាបន្តិចបន្តួចជារឿងធម្មតា ប៉ុន្តែប្រសិនបើខ្វះការយោគយល់អធ្យាស្រ័យអោយគ្នា ប្រកែកយកតែឈ្នះរៀងៗខ្លួន មានជម្លោះស្ទើរតែរាល់ថ្ងៃ ពេលខ្លះក៏អាចឈានដល់ការប្រើពាក្យសំដីគ្រោតគ្រាត រឿងតូចក្លាយជារឿងធំ។ ដូច្នេះវានឹងបង្កអោយភាគីទាំងសងខាងមានការធុញទ្រាន់នឹងចំណងអាពាហ៍ពិពាហ៍របស់ខ្លួនរហូតដល់ទ្រាំលែងបានមិនដឹង ថានឹងត្រូវរស់នៅជាមួយគ្នាបែបណាទៀតបើមានតែរឿងប្រកែកគ្នា មិនដែលលើកលែងអធ្យាស្រ័យសូម្បីតែរឿងតូចមួយ។ ដដែលៗរាល់ថ្ងៃមិនមានការយោគយល់គ្នាសោះ ភាគីក៏ចាប់ផ្តើមមានគំនិតថានឹងលែងលះគ្នាតែម្តងដើម្បីបញ្ចប់ចំណងអាពាហ៍ពិពាហ៍ជូរចត់មួយនេះ។

ឧទាហរណ៍៖ មុនពេលរៀបការ មករា និងកញ្ញា មានភាពស្និតរមួតជាមួយគ្នាណាស់ ដោយពួកគេតែងតែនិយាយពាក្យផ្អែមល្ហែម ហើយធ្វើអ្វីក៏មិនដែលខុសឡើយ ពោលគឺមិនដែលឈ្លោះគ្នានោះទេ។ បន្ទាប់ពីបានរៀបការបាន១ឆ្នាំមក ពួកគេក៏ចាប់ផ្តើមឈ្លោះគ្នាដោយសារតែរឿងតូចតាចមួយចំនួនដូចជា និយាយពាក្យគំរោះ

គំរើយ ធ្វើម្ហូបមិនឆ្ងាញ់ មិនស្តាប់ហេតុផលភាគីម្ខាង និងយល់តែចិត្តខ្លួនឯង។ មូលហេតុទាំងនេះហើយដែលធ្វើឲ្យភាគីទាំងសងខាងមិនសប្បាយចិត្ត ហើយសម្រេចចិត្តថាមិនចង់រួមរស់ជាមួយគ្នាទៀតឡើយ។

### ១.៣.១.៦ បញ្ហាលុយកាក់

បញ្ហាលុយកាក់នេះនឹងកើតមានឡើងនៅពេលដែលដៃគូររបស់ខ្លួនគ្មានសមត្ថភាពរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ ឬផ្តល់អោយខ្លួនបាន។ ជាការពិតណាស់ សហព័ទ្ធទាំងសងខាងត្រូវមានតួនាទីជាអ្នករកប្រាក់ចំណូលទៅតាមសមត្ថភាពរបស់ខ្លួនសម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ តែបើមានភាគីតែម្ខាងខំរកតែម្ខាងទៀតមិនខំរក ច្បាស់ជាសហព័ទ្ធម្ខាងទៀតមានការមិនពេញចិត្តជាពុំខាន។ កត្តានេះជាចំណុចដែលនាំឲ្យមានជីវភាពលំបាក ខ្វះមុខខ្វះក្រោយ និងធ្វើឲ្យសម្ព័ន្ធភាពរវាងសហព័ទ្ធឈានដល់ការបែកបាក់គ្នា។

### ក.ផលប្រយោជន៍

មនុស្សពីរនាក់នៅពេលដែលសម្រេចចិត្តថារៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវឈរលើគោលការណ៍ស្មោះត្រង់និងមានភក្តីភាព ស្រឡាញ់ពេញចិត្តដោយខ្លួនឯងផ្ទាល់ គ្មានការបង្ខំឬស្តាប់តាមការញុះញង់ទើបរស់នៅជាមួយគ្នាប្រកបដោយសុភមង្គល។ ប៉ុន្តែពេលខ្លះភាគីដែលរៀបអាពាហ៍ពិពាហ៍មិនបានធ្វើឡើងតាមការសម្រេចចិត្តរបស់ខ្លួនទេ ដោយសារការសំលឹងមើលឃើញផលប្រយោជន៍ពីភាគីម្ខាងទៀតដូចជាការលួងលោមបង្ខំអោយភាគីម្ខាងទៀតដាក់ឈ្មោះរបស់ខ្លួនជាអ្នកកាន់កាប់លើចលនទ្រព្យផ្សេងៗ ឬ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ ភាគីម្ខាងៗទាមទារកាន់កាប់លុយទាំងអស់ដែលរកបានដើម្បីងាយស្រួលក្នុងការប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួន។ បញ្ហាទាំងនេះកើតឡើងជាញឹកញាប់នៅក្នុងសង្គមបច្ចុប្បន្នដែលនាំអោយមានវិវាទក្នុងគ្រួសារហើយនាំអោយមានទំនាស់ផលប្រយោជន៍ព្រោះសហព័ទ្ធមានភាពលោភលន់។

### ខ.ការផ្គត់ផ្គង់គ្រួសារ

ទោះបីជាបានរៀបអាពាហ៍ពិពាហ៍និងចាកចេញមករស់នៅឆ្ងាយបែកផ្ទះពីក្រុមគ្រួសារឪពុកម្តាយបងប្អូនសាច់ញាតិហើយក្តីប៉ុន្តែក្តីស្រលាញ់នៅតែមានការនឹករលឹកនឹងជួយជ្រោមជ្រែងគ្រួសារដូចមុន។ពេលគ្រួសារមានទុក្ខលំបាកក៏ត្រូវជួយ ជាធនធានមួយចំនួនដែលការជួយនេះអាចធ្វើអោយភាគីដែលជាសហព័ន្ធមានការអន់ចិត្ត ឬ លើកយកមកនិយាយនាំអោយក្លាយជាបញ្ហាតូចធំក្នុងគ្រួសារព្រោះការជួយទៅគ្រួសារម្ខាងៗមិនស្មើភាពគ្នា ជួយខាងប្រពន្ធតិចតែជួយខាងគ្រួសារខ្លួនឯងច្រើនជាដើម។ ចំណុចនេះមិនសូវជាកើតមានច្រើនទេ តែក៏នៅតែជាបញ្ហាប្រឈមមួយអាចចាត់ចូលជាមូលហេតុដែលឈានដល់ការសម្រេចចិត្តលែងលះគ្នាព្រោះតែរស់នៅមិនចុះសម្រុងគ្នា និងមានភាពរកាំរកូសក្នុងគ្រួសារគ្មានដំណោះស្រាយ។

### ១.៣.២ មូលហេតុដែលមានចែងក្នុងច្បាប់

#### ១.៣.២.១ អំពើផិតលើសហាព័ន្ធ

ជាការពិតណាស់ កាលណាបើប្តី ឬប្រពន្ធទៅរួមសេវនកិច្ចជាមួយបុគ្គលផ្សេង ក្រៅពីសាច់ញាតិរបស់ខ្លួននោះជាអំពើផិត។ បើបានប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ៖ យុត្តិសាស្ត្រប្រទេសជប៉ុនបានឲ្យនិយមន័យ "អំពើផិតក្បត់" គឺជាការមានចំណងផ្លូវភេទនឹងបុគ្គលផ្សេងក្រៅពីសហព័ទ្ធ។ និយមន័យនៃយុត្តិសាស្ត្រប្រទេសជប៉ុននេះក៏មានន័យដូចនិយមន័យនៃមាត្រា៧ នៃច្បាប់ស្តីពីឯកពន្ធភាព នៅប្រទេសកម្ពុជាដែរ "អំពើផិតក្បត់" គឺជាការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន។[5] កាលណាប្តី ឬប្រពន្ធបានប្រព្រឹត្តនូវអំពើផិតនេះ ពិតណាស់ភាគីប្តី ឬប្រពន្ធពិតជាមិនអាចទ្រាំមើលភាគីម្ខាងទៀតធ្វើទង្វើបែបនេះមកដាក់ខ្លួននោះទេ សហព័ទ្ធនឹងគិតទៅដល់ការចែកផ្លូវគ្នាដើម្បីផ្តល់សេរីភាព នឹង ភាគីផ្ទាល់មិនទទួលរងនូវការឈឺចាប់នេះតទៅទៀត។

#### ១.៣.២.២ អំពើស្មន់

ថ្វីត្បិតតែការក្បត់ចិត្តភាគីម្ខាងទៀតគឺសំដៅទៅដល់ការមានអ្នកថ្មីម្នាក់ទៀតហើយបានរួមមេត្រីជាមួយគ្នាក្រៅពីភាគីប្តី ប្រពន្ធរបស់ខ្លួនពិតមែន ប៉ុន្តែប្រសិនបើការរួមសេវនកិច្ចជាមួយនឹងសាច់ញាតិផ្ទាល់ ញាតិពន្ធ (សាច់ថ្លៃ) ឬញាតិពន្ធខ្សែផ្ទាល់(ញាតិរបស់សាច់ថ្លៃ) នោះហើយគឺជា ការស្មន់។ តាមច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ ២០០៦ដែលបានបញ្ញត្ត ដើម្បីធានាការពារសេចក្តីថ្លៃថ្នូរ និងពង្រឹងសុខដុមរមនាក្នុងគ្រួសារ ឲ្យមានការគោរពសិទ្ធិគ្នាទៅវិញទៅមករវាងប្តី និងប្រពន្ធគឺត្រូវឲ្យស្របតាមរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ពោលគឺត្រូវចាត់ទុកថា ជាអំពើស្មន់ ចំពោះបុរស និងស្ត្រីណាដែលជាប់ចំណងជាញាតិលោហិតដែលមានឈាមជ័រជាមួយគ្នា(ឪពុក ម្តាយ កូន) ឬញាតិពន្ធដែលជាសាច់ថ្លៃ(ឪពុកម្តាយក្មេក និងកូនប្រសា បងថ្លៃ ប្អូនថ្លៃ) ពួកគេបានរួមសេវនកិច្ចជាមួយគ្នា។[6] មួយវិញទៀត ទង្វើដែលត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទស្មន់នេះគឺមានដូចតទៅ៖

- បុរស និងស្ត្រីដែលជាប់ចំណងជាញាតិលោហិត ឬញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះចំណងនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ឬជាសាច់ចិញ្ចឹមក្តី បានរួមសេវនកិច្ចជាមួយគ្នា ។

---

[5] មាត្រា៧ នៃច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦

[6] មាត្រា៥ នៃច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦

➢ បុរស និងស្ត្រីដែលជាប់ចំណងសាខាញាតិនឹងគ្នា ទោះសាខាញាតិនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ចិញ្ចឹមក្តី រួមម្តាយក្តី រួមឪពុកក្តី រួមម្តាយឪពុកក្តី ជាញាតិលោហិតក្តី ឬជាញាតិពន្ធក្តី រហូតដល់ថ្នាក់ទី៣ រាប់ទាំងថ្នាក់នេះផង បានរួមសេវនកិច្ចជាមួយគ្នា។[7]

### ១.៣.២.៣ ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុ

ការបោះបង់ សំដៅទៅដល់ការមិនយកចិត្តទុកដាក់ មិននឹកនា ការលះបង់ចោល។[8] ការបោះបង់ ឬការចុះចោលផ្ទះនេះ មានន័យថា ភាគីប្តី ឬប្រពន្ធបានចាកចេញពីលំនៅឋានដោយមិនដឹងទៅទីណា ហើយមិនបានផ្គត់ផ្គង់ ឬទំនុកបម្រុងដល់គ្រួសារ។

ដូច្នេះ ការលះបង់ចោលដោយសហពទ្ធ័ម្ខាងមិនបានបំពេញករណីយកិច្ចដែលមានក្រោយពេលរៀបអាពាហ៍ពិពាហ៍ នឹងត្រូវចាត់ទុកថាជាការរំលោភបំពានដល់សហព័ទ្ធម្ខាងទៀត ព្រមទាំងមិនគោរពតាមគោលការណ៍ច្បាប់ដែលមានចែង អាស្រ័យហេតុនេះទើបត្រូវចាត់ទុកថាជាមូលហេតុនៃការលែងលះ។

### ១.៣.២.៤ ការបាត់ខ្លួនរបស់សហព័ទ្ធដោយមិនដឹងថាស្លាប់ឬរស់

ក្នុងករណីភាគីប្តី ឬប្រពន្ធបានបាត់ខ្លួនអស់រយៈពេលជាងមួយឆ្នាំ ដោយពុំមានដំណឹងសោះថាស្លាប់ ឬរស់ នោះភាគីដែលនៅរស់អាចស្នើសុំទៅតុលាការឲ្យរំលាយចំណងអាពាហ៍ពិពាហ៍ចាស់ចោលបាន។ បើទោះបីជាសហព័ទ្ធដែលបាត់ខ្លួនអស់រយៈពេលជាងមួយឆ្នាំនោះពុំបានប្រព្រឹត្តកំហុសក៏ដោយ ក៏ច្បាប់អនុញ្ញាតឲ្យការបាត់ខ្លួននេះក្លាយទៅជាមូលហេតុមួយនៃការលែងលះផងដែរ។[9]

### ១.៣.២.៥ សហព័ទ្ធរស់នៅបែកគ្នាជាបន្តបន្ទាប់ជាង១ឆ្នាំ

សព្វថ្ងៃមានប្តីប្រពន្ធជាច្រើនត្រូវរស់នៅឆ្ងាយពីគ្នា ក្នុងករណីភាគីជាប់បំពេញកាតព្វកិច្ចការងារ ដូចនេះសហព័ទ្ធក៏មិនមានឆន្ទៈនៅក្នុងការកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍ទេ ពោលគឺគ្រាន់តែឃ្លាត ដោយសារកាលៈទេសៈប៉ុណ្ណោះ។ ប៉ុន្តែ ប្រសិនបើសហព័ទ្ធរស់នៅបែកបាក់គ្នាអស់រយៈពេលជាង១ឆ្នាំ ដោយសារតែការរស់នៅមិនចុះសម្រុង ហើយមិនអាចបន្តនៅផ្ទះជាមួយគ្នាបាន ប្រៀបដូចជាកាត់ផ្តាច់សម្ព័ន្ធភាពនឹងគ្នា ដែលស្ថានភាពបែបនេះ តុលាការនឹងធ្វើការពិចារណាទៅលើមូលហេតុទាមទារលែងលះដែលស្របទៅតាមឆន្ទៈរបស់ភាគី គឺអស់ចិត្តអាណិតស្រឡាញ់រវាងគ្នានឹងគ្នា សង្កត់ធ្ងន់ទៅលើភាគីមិនចង់បន្តចំណងអាពាហ៍ពិពាហ៍ជាមួយគ្នាទៀត។

---

[7] មាត្រា៣ នៃច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦

[8] វចនានុក្រម ព្រះសង្ឃរាជជួនណាត

[9] មាត្រា៣ នៃច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦ និងមាត្រា៩៨៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ១.៣.២.៦ ករណីផ្សេងៗដែលមិនអាចធ្វើបដិទានបាន

ចំណងអាពាហ៍ពិពាហ៍ប្រេះឆា ក៏អាចបណ្តាលមកពីមូលហេតុផ្សេងៗជាច្រើនទៀតដែលមិនអាចធ្វើបដិទានបាន (ស្តារ ឬធ្វើឲ្យដូចដើម)។ នៅក្នុងបញ្ញត្តិនេះបានផ្តល់នូវអត្ថិភាពចំពោះការលែងលះដោយមូលហេតុផ្ទាល់របស់ភាគីដែលមិនបានកំណត់ក្នុងច្បាប់ ដោយគ្រាន់តែភាគីលើកយកចំណុចណាមួយដែលជាហេតុផលចំពោះការរស់នៅមិនចុះសម្រុងគ្នា ដោយយោងទៅតាមមាត្រាច្បាប់ត្រង់ចំណុចនេះ។ ជាក់ស្តែងភាគីដែលចង់លែងលះច្រើនតែលើកយកមូលហេតុផ្សេងៗដែលធ្លាប់បញ្ញត្តិពីមុនមាននៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដូចជា ការមើលងាយធ្ងន់ធ្ងរ ការធ្វើទុក្ខបុកម្នេញឬ ជេរប្រមាថចំពោះសហព័ទ្ធក្តី ឬចំពោះបុព្វញាតិរបស់សហព័ទ្ធ ការប្រព្រឹត្តអំពើអបាយមុខផ្ទុយពីសីលធម៌ និងអពលានុភាពនៃលិង្គដែលជាមូលហេតុនាំឲ្យភាគីទាមទារលែងលះ។[10] មូលហេតុខ្លះទៀតកើតចេញពីឆន្ទៈព្រមព្រៀងរបស់សហព័ទ្ធទាំងសងខាងដោយគ្មានវិការៈ។

ហេតុដូចនេះហើយ ករណីដែលមិនអាចធ្វើបដិទានបាន ជាចំណុចដែលមានចែងក្នុងក្រមរដ្ឋប្បវេណីបានផ្តល់ឲ្យពលរដ្ឋមានសិទ្ធិសេរីភាពចំពោះការលើកឡើងនូវមូលហេតុផ្សេងៗជាច្រើនដែលអាចកំណត់យកជាមូលហេតុនៃការលែងលះពីតុលាការបាន។

### ១.៣.២.៧ ការប្រើអំពើហិង្សា

ចំពោះមនុស្សគ្រប់ស្រទាប់វណ្ណៈក្នុងសង្គមមិនថា អ្នកមាន ឬអ្នកក្រ អ្នកមានចំណេះដឹងខ្ពង់ខ្ពស់ ឬមានចំណេះដឹងតិចតួច ការរស់នៅតែងតែមានភាពមិនចុះសម្រុងគ្នាទាំងផ្លូវកាយ និងផ្លូវចិត្ត ការខ្វែងគំនិតគ្នាដែលអាចឈានទៅដល់ការប្រើប្រាស់អំពើហិង្សា ដើម្បីយកឈ្នះលើភាគីម្ខាងទៀត។ អំពើហិង្សា ជាការប្រើអំពើឃោរឃៅដោយចេតនាដែលប៉ះពាល់ដល់រូបរាងកាយ ដូចជា វាយដំ ទាត់ធាក់ បង្អត់អាហារ ការបង្ខិតបង្ខំបៀតបៀនលើរូបរាងកាយ រួមបញ្ចូលទាំងការប្រមាថមាក់ងាយ។[11] អំពើដែលប៉ះពាល់លើផ្លូវចិត្ត ក៏អាចកើតមានដូចជា ការមិនឲ្យកាន់លុយកាក់ក្នុងគោលបំណងកំរិតលើការចាយវាយដែលធ្វើឲ្យភាគីម្ខាងទៀតមានអារម្មណ៍ដូចខ្លួនឯងជាមនុស្សគ្មានតម្លៃសម្រាប់គេសោះ។ អំពើហិង្សាអាចជាមូលហេតុនៃការលែងលះដែលកើតមានច្រើននៅក្នុងពេលបច្ចុប្បន្នព្រោះថា ការប្រើអំពើហិង្សានោះមិនមែនទើបតែកើតឡើងលើកដំបូងចំពោះសហព័ទ្ធនោះទេ តែអាចកើតឡើងជាបន្តបន្ទាប់ធ្វើឲ្យភាគីម្ខាងទៀតមិនអាចទ្រាំបាន ទើបសម្រេចចិត្តលែងលះគ្នា។

[10] មាត្រា៣៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ១៩៨៩

[11] ចំណុច១.០៦ដល់១.០៩ នៃសៀវភៅច្បាប់ និងអំពើហិង្សាក្នុងគ្រួសារ

ឧទាហរណ៍៖ លោកម៉ៅបានរៀបការជាមួយនារីម្នាក់ឈ្មោះ ស្រីមាន។ ក្រោយពីរៀបការហើយ លោកម៉ៅ បានចេញទៅធ្វើការរកលុយដោយ ភរិយាឈ្មោះ ស្រីមាន នៅមើលថែផ្ទះ។ ក្រោយរៀបការបាន១ឆ្នាំ លោកម៉ៅតែងតែប្រើអំពើហិង្សាលើស្រីមានជាញឹកញាប់ ពេលខ្លះដល់ថ្នាក់បែកក្បាលដេរជាច្រើនថ្នេរ មិនត្រឹមតែប្រើអំពើហិង្សារលើផ្លូវកាយប៉ុណ្ណោះទេ ថែមទាំងមានស្រីកំណាន់យកមកបញ្ឈឺចិត្តស្រីមានផងដែរ។

### ១.៣.៣ មូលហេតុនៃការលែងលះដោយការព្រមព្រៀង

ទិដ្ឋភាពទូទៅនៃការលែងលះដោយការព្រមព្រៀង ត្រូវបានធ្វើឡើងនៅពេលដែលភាគីនៃចំណងអាពាហ៍ពិពាហ៍បានព្រមព្រៀងគ្នាក្នុងការបញ្ចប់នូវសម្ព័ន្ធភាពអាពាហ៍ពិពាហ៍ដោយមិនមានការឈ្លោះទាស់ទែងគ្នា ឬបែងចែកសិទ្ធិនិងកាតព្វកិច្ចក្រោយការលែងលះឡើយ។ ការលែងលះដោយការព្រមព្រៀងត្រូវបានស្ថិតនៅក្រោមច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។[12] មូលហេតុដែលនាំឲ្យភាគីសម្រេចស្នើសុំលែងលះភាគច្រើនតែងតែលើកយកចំណុចមូលហេតុផ្សេងៗដែលនាំឲ្យការរស់នៅមិនចុះសម្រុង ហើយមិនអាចធ្វើបដិទានបាន ការលែងលះដោយការព្រមព្រៀងមិនមានលក្ខណៈស្មុគស្មាញនោះទេ ពីព្រោះភាគីបានយល់ព្រមរួចជាស្រេចទៅហើយក្នុងការលែងលះ។

#### ១.៣.៣.១ សហព័ន្ធអស់មនោសញ្ចេតនា

ភាពស្និតស្នាល និងការប្រាស្រ័យទាក់ទងគ្នា ពិតជាសំខាន់ណាស់សម្រាប់ប្តីប្រពន្ធទាំងឡាយ។ ប៉ុន្តែបើសហព័ទ្ធអស់ចិត្តស្រឡាញ់រៀងៗខ្លួន លែងមានការយកចិត្តទុកដាក់ចំពោះគ្នា មានភាពសោះកក្រោះរវាងគ្នានឹងគ្នា នោះនឹងឈានទៅរកការលែងលះគ្នាជាក់ជាពុំខាន។

ឧទាហរណ៍៖ លោក ពីរី និងភរិយាបានរៀបការជាមួយគ្នាអស់រយៈពេល១០ឆ្នាំហើយ។ ប៉ុន្តែស្រាប់តែមានពេលមួយ ពួកគេទាំងពីរបែរជាលែងមានអារម្មណ៍ល្អនឹងគ្នា និងពុំមានចិត្តស្រឡាញ់គ្នាទៀតឡើយ។ ដោយហេតុតែមើលឃើញសកម្មភាពបែបនេះរៀងៗខ្លួនហើយ ពួកគេក៏សម្រេចចិត្តនិយាយត្រង់ទៅត្រង់មកជាមួយគ្នាអំពីបញ្ហានេះ។ បន្ទាប់ពីពិភាក្សាគ្នាហើយ ពួកគេក៏បានសម្រេចចិត្ត ហើយព្រមព្រៀងថានឹងលែងលះគ្នា ដើម្បីល្អទាំងសងខាងព្រោះពួកគេទាំងពីរមិនទាន់មានកូននៅឡើយ។

#### ១.៣.៣.២ ការរស់នៅមិនចុះសម្រុងនឹងគ្នា

ជាក់ស្តែងណាស់ ការខ្វែងគំនិតគ្នា ភាពមិនចុះសម្រុងនឹងគ្នាទាំងកាយវាចាចិត្ត អាចធ្វើឲ្យប្តីប្រពន្ធមានអារម្មណ៍ថា ពិបាករស់នៅក្រោមដំបូលផ្ទះតែមួយណាស់ ព្រោះវានឹងធ្វើឲ្យជីវិតគូមានក្តីទុក្ខច្រើនជាងក្តីសុខ

[12] មាត្រា១ និងមាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

ហើយមិនអាចជួយថែរក្សាទំនាក់ទំនងរវាងប្តីប្រពន្ធឲ្យមានភាពរឹងមាំបានទេ។ ចំណុចនេះ ប្រសិនបើប្តីប្រពន្ធមិនរកដំណោះស្រាយទេ គឺអាចឈានទៅដល់ការលែងលះគ្នា។

ឧទាហរណ៍៖ លោក ជី និងលោកស្រី ដា ជាប្តីប្រពន្ធដែលទើបតែរៀបការថ្មីថ្មោង។ ពួកគាត់បានទៅរស់នៅផ្ទះល្វែងតែពីរនាក់ប្តីប្រពន្ធ។ ដោយហេតុថា ពួកគាត់មានអត្តចរិត និងការរស់នៅខុសគ្នា លោក ជី និងលោកស្រី ដាតែងតែមានភាពរកាំរកូសរហូត ព្រោះតែរស់នៅមិនមានភាពចុះសម្រុងគ្នា។ ដូចនេះ ពួកគាត់ក៏បានសម្រេចចិត្តក្នុងការព្រមព្រៀងថានឹងបញ្ចប់ចំណងអាពាហ៍ពិពាហ៍ជាមួយគ្នាព្រោះតែការមិនសូវយល់ចិត្តគ្នាទោះបីជាអ្នកទាំងពីរព្យាយាមនិយាយគ្នាតាមសន្តិវិធីក៏ដោយ។

### ១.៣.៣.៣ បញ្ហាសាច់ញាតិបងប្អូនខាងប្តី រឺប្រពន្ធ

នៅពេលដែលប្តីប្រពន្ធចាប់ផ្តើមមានការប៉ះទង្គិចផ្លូវចិត្តពីគ្រួសារទាំងសងខាង មិនថាខាងប្តី ឬខាងប្រពន្ធដោយសារមានពាក្យចាក់រុក ពេលមានបញ្ហាគ្រួសារឬសាច់ញាតិម្ខាងណាមិនព្រមជួយផ្សះផ្សា តែបែរជាទម្លាក់បន្ទុក ឬកំហុសទៅលើកូនប្រសា រហូតធ្វើឲ្យដៃគូម្នាក់ៗទទួលអារម្មណ៍ថាមានសម្ពាធ។ បញ្ហាដែលបង្កមកពីសាច់ថ្លៃមិនសូវជាកើតមាននោះទេ តែវាក៏ជាចំណុចមួយដែលគួរតែចាប់អារម្មណ៍ផងដែរ ព្រោះមានដៃគូមួយចំនួនដែលលែងលះគ្នាដោយសារមូលហេតុនេះដែរ។ ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងគ្រួសារពីសំណាក់ឪពុកម្តាយ ញាតិមិត្ត បងប្អូន ឬសមាជិកដទៃ គឺប្រាកដណាស់ថានឹងធ្វើឲ្យភាគីជាប្តីនិងប្រពន្ធបែកបាក់គ្នា។

ឧទាហរណ៍៖ លោក សុខ និង លោកស្រី ស្រីមុំ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន២ឆ្នាំ។ ស្រីមុំបានមកនៅផ្ទះជាមួយលោក សុខ ដែលជាស្វាមី ហើយផ្ទះរបស់ម្តាយក្មេកស្រីមុំក៏នៅជិតគ្នាផងដែរ។ ថ្ងៃមួយលោកសុខ មិនសប្បាយចិត្តនៅកន្លែងធ្វើការ ហើយត្រឡប់មកផ្ទះវិញឃើញស្រីមុំមិនទាន់រៀបចំម្ហូបរួចរាល់ក៏កើតមានចិត្តខឹង ឆេវឆាវ ថែមទាំងថាឲ្យស្រីមុំខ្លាំងៗទៀតផង ទើបកើតជាជម្លោះលឺទៅដល់ផ្ទះម្តាយក្មេក ។រួចសុខ ក៏បានដើរសំដៅទៅរកម្តាយពេលទៅដល់ម្តាយសុខបាននិយាយមិនល្អពីស្រីមុំថានាងជាមនុស្សមិនបានការ ខ្ជិលច្រអូស ថែមទាំងចាក់រុកថាស្រីមុំពេលទៅផ្សារម្តងៗយូរៗ ថែមទាំងឃើញមានមនុស្សប្រុសឌុបមកវិញទៀត។ ដូចនេះ ធ្វើឲ្យលោកសុខ កាន់តែខឹង ដោយជឿតាមពាក្យគ្រួសារចាក់រុក លោកសុខ បានសម្រេចចិត្តលែងលះជាមួយលោកស្រី ស្រីមុំ ។

## ១.៤ គោលបំណងផ្តាច់ចំណងអាពាហ៍ពិពាហ៍

គួរឲ្យកត់សំគាល់បានថា អាពាហ៍ពិពាហ៍គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់មនុស្សគ្រប់រូបដែលចង់បង្កើតគ្រួសារមួយពេញលេញ និងពោរពេញទៅដោយសេចក្តីសុខនិងសុភមង្គល។ កាលបើអាពាហ៍ពិពាហ៍នោះកើតឡើងដោយមានការចាប់បង្ខំឬ ក្នុងកំឡុងពេលរៀបអាពាហ៍ពិពាហ៍ភាគីមិនបានគោរពទៅតាម

កាតព្វកិច្ចព្រមទាំងធ្វើឲ្យកើតមានបញ្ហាស្មុគស្មាញដែលជាការលំបាកសម្រាប់ភាគីម្ខាងទៀតក្នុងការបន្តរួមរស់ជាមួយគ្នាដោយគ្មានសេចក្តីសុខ ទើបធ្វើឲ្យភាគីមានគោលបំណងក្នុងការផ្តាច់ចំណងអាពាហ៍ពិពាហ៍ ដើម្បីសេរីភាព និងតម្រូវការរបស់ភាគី។ នៅក្នុងការផ្តាច់ចំណងអាពាហ៍ពិពាហ៍មានការកំណត់យ៉ាងច្បាស់ចំពោះកាតព្វកិច្ច ក៏ដូចជាការបែងចែកទ្រព្យសម្បត្តិ ការមើលថែទាំកូន និងកាតព្វកិច្ចមួយចំនួនទៀត។

## ១.៥ ការកំណត់និង បែងចែកទ្រព្យសម្បត្តិ

នៅក្នុងទំនាក់ទំនងប្តីប្រពន្ធ ការគ្រប់គ្រង ចាត់ចែងនឹងបែងចែកទ្រព្យសម្បត្តិអាចនាំទៅរកវិវាទទាំងនៅក្នុងពេលជាប់ចំណងអាពាហ៍ពិពាហ៍ក៏ដូចជានៅពេលលែងលះ។ ដើម្បីបង្កានិងដោះស្រាយវិវាទទាំងនេះក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាមានចែងអំពីប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធនៅក្នុងមាត្រា៩៦៩ហើយបានបញ្ជាក់ថាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធចែកចេញជាពីរប្រភេទគឺ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។

### ១.៥.១ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធចាំបាច់ត្រូវធ្វើជាទម្រង់លាយល័ក្ខណ៍អក្សរ ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ មុនឬក្រោយរៀបអាពាហ៍ពិពាហ៍ កិច្ចសន្យានេះមិនអាចធ្វើផ្ទុយពីបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ចនិងភាគបម្រុងបានឡើយ។[13] ចំពោះការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធចាត់ទុកថា មានភាពងាយស្រួល ប្រសិនបើមានការលែងលះដោយភាគីទាំងសងខាងអាចធ្វើការបែងចែកទ្រព្យសម្បត្តិទៅតាមការព្រមព្រៀងដែលបានចុះក្នុងកិច្ចសន្យាដោយគ្មានវិការៈ។ តុលាការនឹងមិនចាំបាច់មានភាពស្មុគស្មាញក្នុងការកាត់សេចក្តី ពោលគឺគ្រាន់តែអនុវត្តទៅតាមកិច្ចសន្យាតែម្តង។

### ១.៥.២ ប្រព័ន្ធទ្រព្យសម្បត្តិកំណត់ដោយច្បាប់

បើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាលើទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិនឹងត្រូវអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់វិញ។ ដោយយោងទៅតាមស្មារតីក្រមរដ្ឋប្បវេណីមាត្រា៩៨០ បានចែងអំពីការបែងចែកទ្រព្យសម្បត្តិថា ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង។[14] ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់ដោយច្បាប់មាន២ប្រភេទដូចតទៅះ

[13] មាត្រា៩៦៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[14] មាត្រា៩៧១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ១.៥.២.១ ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក

ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យដែលសហព័ទ្ធមានមុនពេលរៀបអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិដែលទទួលបានដោយប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទាននៅក្នុងកំឡុងពេលអាពាហ៍ពិពាហ៍រួមទាំងទ្រព្យសម្បត្តិជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិកំណត់ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។ ទ្រព្យសម្បត្តិដែលសហព័ទ្ធណាមួយទទួលបានក្នុងចំណងអាពាហ៍ពិពាហ៍ ប៉ុន្តែ ទទួលជាកេរមរតក ឬដោយអំណោយ (ប្រទានកម្ម ឬអច្ច័យទាន)។

ឧទាហរណ៍៖ ឪពុករបស់លោក យី បានប្រគល់ផ្ទះមួយល្វែងឱ្យមកលោកយី តែម្នាក់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ព្រោះមុនពេលរៀបអាពាហ៍ពិពាហ៍លោក យី បានជួយការងារឪពុករបស់លោកបានច្រើនណាស់ដូចនេះឪពុករបស់លោកបានប្រគល់ផ្ទះឲ្យលោកមួយល្វែង។ នោះ គេចាត់ទុកថាផ្ទះនោះជាទ្រព្យដោយឡែករបស់លោក យី ទោះបីជាទ្រព្យនោះបានមកក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ។

ក្នុងករណីអំណោយ បើម្ចាស់អំណោយឲ្យទៅអ្នកណា គឺជាទ្រព្យផ្ទាល់របស់អ្នកនោះ បើសិនជាម្ចាស់អំណោយបញ្ជាក់ច្បាស់ថាឲ្យទៅទាំងពីរនាក់ប្តីប្រពន្ធ គឺជាទ្រព្យរួម។

ឧទាហរណ៍៖ ភាគីជាប្រពន្ធមានដីមួយកន្លែង ដែលជាទ្រព្យផ្ទាល់ ដែលគាត់មានតាំងពីមុនពេលរៀបការ។ ក្រោយមក ក្នុងពេលជាប់ចំណងអាពាហ៍ពិពាហ៍ គាត់លក់ដីនេះចេញ រួចហើយយកលុយដែលបានពីការលក់ដីនេះ ទៅទិញផ្ទះមួយល្វែង ផ្ទះនេះ នៅតែជាទ្រព្យសម្បត្តិផ្ទាល់របស់គាត់ ទោះបីជាទិញនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ក៏ដោយ។

ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិទាំងពីរចំណុចខាងលើ។[15]

ឧទាហរណ៍៖ លោក ដេត ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួច គាត់បានលក់ឡានរបស់គាត់ដែលបានទិញក្នុងតម្លៃ ៨ម៉ឺនដុល្លាក្នុងតម្លៃទាបជាងទីផ្សារដោយគាត់លក់តែ ៥ម៉ឺនដុល្លា ហើយបានយកលុយនោះទៅទិញឈុតគ្រឿងពេជ្រឲ្យទៅប្រពន្ធរបស់គាត់។ ដូចនេះឈុតគ្រឿងពេជ្រដែលគាត់បានទិញនេះក៏ត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិដោយឡែក ព្រោះវាជាតម្លៃតបនៃឡានដែលជាទ្រព្យដោយឡែក។

### ១.៥.២.២ ប្រព័ន្ធទ្រព្យសម្បត្តិរួម

ប្រព័ន្ធទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិដែលមានរួមគ្នា ហើយសំដៅទៅលើទ្រព្យទាំងឡាយណាដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ក្រៅពីទ្រព្យសម្បត្តិដោយឡែក

[15] មាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

និងត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិរួម។[16] ប្តីប្រពន្ធមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផល និងគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយផ្អែកទៅលើភាពចាំបាច់នៅក្នុងជីវភាព។[17] ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាពចំពោះការចំណាយផ្សេងៗ ដើម្បីជីវភាពរួម និង ដើម្បីដោះស្រាយបន្ទុកដូចជា ការអប់រំ ឬការថែទាំ កូន។[18] ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនអាចយកទៅលក់ ឬធ្វើការចាត់ចែងផ្សេងទៀតដោយមិនមានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងទេ ប្រសិនបើមានករណីបន្ទាន់សម្រាប់ការថែទាំជីវភាពរួមក្នុងចំណងអាពាហ៍ពិពាហ៍ ប្តីឬប្រពន្ធណាម្ខាងអាចលក់ ឬធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួមបានដោយទទួលការអនុញ្ញាតពីតុលាការ។ ការបែងចែកទ្រព្យសម្បត្តិរួមក្រោយការលែងលះអាចធ្វើឡើងតាមការព្រមព្រៀងរបស់ភាគី សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយកមួយភាគពីរនៃទ្រព្យសម្បត្តិរួមដែលបានរករួមគ្នា។ ប៉ុន្តែបើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួមដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍កម្រិតជីវភាពរស់នៅ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូនជាអាទិ៍។

មួយវិញទៀត គេហកិច្ចត្រូវបានចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ។ ជាគោលការណ៍ច្បាប់ការងារ គេហកិច្ច ឬការងារនៅក្នុងផ្ទះ ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែល ធ្វើនៅក្រៅផ្ទះដែរ មានន័យថា ប្តីមិនអាចបដិសេធចំពោះចំណូលដែលខ្លួនរក បានពីការងារក្រៅផ្ទះ ថាមិនមែនជាទ្រព្យរួម ឬបន្ថយសិទ្ធិរបស់ប្រពន្ធលើចំណូលរបស់ខ្លួន ដោយសំអាងថាប្រពន្ធរបស់ខ្លួនធ្វើតែការងារផ្ទះ មើលថែទាំកូន ដាំស្ល បោកគក់ជាដើម ដោយមិនបានប្រឡូកនឹងការងារខាងក្រៅ ដែលនឿយហត់ដូចការងាររបស់ខ្លួនឡើយ។

ឧទាហរណ៍៖ លោក ភក្តី និង ស្រីម៉ៅបានសម្រេចចិត្តថា រៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។ នៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អ្នកទាំងពីរបានបើកហាងលក់ផ្លែឈើមួយកន្លែងដែលជាញើសឈាមសន្សំសំចៃរបស់អ្នកទាំងពីររួមគ្នាដូចចំណូលដែលបានមកពីហាងផ្លែឈើត្រូវយកមក ផ្គត់ផ្គង់ជីវភាពគ្រួសារ។ ក្រោយពេលលែងលះហាងផ្លែឈើត្រូវយកមកបែងចែកតាមផ្លូវច្បាប់។

[16] មាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[17] មាត្រា៩៧៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[18] មាត្រា៩៧៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ១.៥.៣ ការព្រមព្រៀងអំពីអំណាចមេបាលើកូន

គោលការណ៍ចំពោះអ្នកមានអំណាចមេបាដែលមានចែងក្នុងក្រមរដ្ឋប្បវេណី បានកំណត់អំពីអំណាចមេបាទោលថា បើឪពុកម្ដាយលែងលះគ្នា ត្រូវកំណត់យកឪពុក ឬ ម្ដាយណាម្ខាង ជាអ្នកមានអំណាចមេបាតាមការពិភាក្សារបស់ឪពុកម្ដាយ។[19] ចំណែកឯ ក្នុងករណីដែលឪពុកម្ដាយបានលែងលះគ្នាមុនកំណើតរបស់កូនម្ដាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ។[20] ប៉ុន្តែនៅក្រោយកំណើតរបស់កូនអាចកំណត់យកឪពុកជាអ្នកមានអំណាចមេបាតាមការពិភាក្សារបស់ឪពុកម្ដាយបាន។ ម្យ៉ាងទៀត ការសម្រេចអំពីអ្នកមានអំណាចមេបាតាមការព្រមព្រៀងរបស់ឪពុកម្ដាយពុំមានការបង្ខិតបង្ខំដល់ឪពុក ឬម្ដាយម្ខាងណាឡើយក្នុងការទទួលយកកូនឲ្យមកស្ថិតក្រោមការ គ្រប់គ្រងរបស់ខ្លួន ព្រោះផ្អែកទៅលើហេតុផលជាច្រើនដែលជាប្រយោជន៍សម្រាប់កូនទៅថ្ងៃអនាគតចំពោះការព្រមព្រៀងរៀបចំទុកដាក់ការរស់នៅរបស់កូន។

[19] កថាខណ្ឌទី១ នៃមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[20] កថាខណ្ឌទី២ នៃមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី២៖

# នីតិវិធីនៃការលែងលះដោយការព្រមព្រៀង

# ជំពូកទី២៖ នីតិវិធីនៃការលែងលះដោយការព្រមព្រៀង

ការលែងលះគ្នាដោយការព្រមព្រៀងនឹងធ្វើឡើងនៅពេលដែលភាគីនៃអាពាហ៍ពិពាហ៍បានយល់ព្រមបញ្ចប់អាពាហ៍ពិពាហ៍ដោយគ្មានជម្លោះលើការបែងចែកសិទ្ធិនិងកាតព្វកិច្ចបន្ទាប់ពីការលែងលះ។ នៅក្នុងករណីនៃការលែងលះដោយព្រមព្រៀងគ្នា មានតែភាគីដែលផ្តួចផ្តើមដំណើរការដោះស្រាយដោយការដាក់ពាក្យសុំតាមនីតិវិធីច្បាប់។

## ២.១ ការដាក់ពាក្យសុំលែងលះដោយការព្រមព្រៀង

ប្តីប្រពន្ធស្ម័គ្រចិត្តទាំងសងខាងក្នុងការព្រមព្រៀងលែងលះពោលគឺមិនមានភាគីណាជំទាស់ ឬមានវិវាទមិនព្រមលែងលះនោះទេ ដោយយោងលើកិច្ចព្រមព្រៀងលែងលះរួចដាក់ពាក្យសុំទៅតុលាការដើម្បីបានដីកាសម្រេចលែងលះតាមច្បាប់។

### ២.១.១ ការដាក់ពាក្យសុំដោយលាយលក្ខណ៍អក្សរ

រឿងក្តីនៃការលែងលះដោយការព្រមព្រៀងគឺមានតែភាគីប្តី ឬ ភាគីប្រពន្ធដែលជាអ្នកផ្តើមដំណើរការនីតិវិធីដោះស្រាយដំបូងតាមរយៈការដាក់ពាក្យសុំទៅតុលាការ ។ កម្មវត្ថុនៃការសម្រេចដែលមានក្នុងការចេញដីកាសម្រេចគឺភាគីជាអ្នកកំណត់ក្នុងពាក្យសុំ ហើយតុលាការចាប់ផ្តើមជម្រះក្តីបានលុះត្រាតែទទួលបានពាក្យសុំជាមុនសិន។ ការព្រមព្រៀងលែងលះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរមានផ្តិតមេដៃ ឬជាការចុះហត្ថលេខាភាគីទាំងសងខាង (អាចមានមេធាវី ឬសាការី ឬមេឃុំ ឬជាសាក្សី) ដោយឡែកចំពោះការលែងលះដោយការព្រមព្រៀងនេះ ការដាក់ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរដោយនៅក្នុងលិខិតនៃពាក្យសុំដែលត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម៖

- ឈ្មោះ ឬនាមករណ៍និងអាស័យដ្ឋានរបស់អ្នកដាក់ពាក្យសុំព្រមទាំងឈ្មោះនិងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- ខ្លឹមសារនៃដីកាសម្រេច ឬសកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារនិងអង្គហេតុដែលជាមូលហេតុនៃការទាមទារគឺជាការអះអាងអង្គហេតុដែលជាមូលហេតុគាំទ្រដល់ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ។[21]

[21] កថាខណ្ឌទី១ និងទី២ នៃមាត្រា២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

### ២.១.២ ការដាក់ពាក្យសុំដោយផ្ទាល់មាត់

ទម្រង់នេះភាគច្រើនត្រូវបានប្រើប្រាស់ដោយប្រជាជនដែលមិនសូវយល់ដឹងពីច្បាប់និងមិនមានលទ្ធភាពពឹងពាក់មេធាវី។ តាមរយៈទម្រង់នេះនៅពេលដែលប្តីប្រពន្ធសម្រេចថាលែងលះគ្នាពួកគាត់និងទៅតុលាការ ហើយថ្លែងការអំពីឆន្ទៈព្រមព្រៀងលែងលះរបស់ខ្លួននៅចំពោះមុខក្រឡាបញ្ជី ហើយទទួលយកពាក្យសុំរួចធ្វើការដាក់ពាក្យសុំនៅពេលជាមួយគ្នាតែម្តង ក្នុងករណីនេះក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុនិងចុះហត្ថលេខា ហើយកំណត់ហេតុនេះត្រូវបានចាត់ទុកជាពាក្យសុំ។ ក្នុងករណីដែលភាគីមានឯកសារភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដើម ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយលិខិតនៃពាក្យសុំ ឬ ត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ។[22]

### ២.១.៣ ឯកសារភ្ជាប់សម្រាប់ការដាក់ពាក្យសុំ

#### ២.១.៣.១ កិច្ចសន្យាព្រមព្រៀង

ភាគីប្តីប្រពន្ធអាចរៀបចំកិច្ចព្រមព្រៀងលែងលះគ្នាជាមុនហើយភ្ជាប់ទៅជាមួយពេលយកពាក្យសុំទៅដាក់នៅតុលាការ។ ជាទូទៅកិច្ចព្រមព្រៀងនេះ ត្រូវសរសេរអំពីខ្លឹមសារសារជាតុចម្បងគឺឆន្ទៈនៃការព្រមព្រៀងលែងលះ ការបែងចែកសិទ្ធិអំណាចមេបាលើកូន ការចូលជួបប្រាស្រ័យទាក់ទងជាមួយកូន ការចំណាយដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន អាហារកាតព្វកិច្ចចំពោះឪពុកម្តាយឬជាសាច់ញាតិបងប្អូន ការបែងចែកទ្រព្យសម្បត្តិរួម និង ការបែងចែកលើបំណុលផងដែរ។

#### ២.១.៣.២ សំបុត្រអាពាហ៍ពិពាហ៍

ជាគោលការណ៍ ប្តីប្រពន្ធស្របច្បាប់គឺទាល់តែបានចុះបញ្ជីអាពាហ៍ពិពាហ៍ (សំបុត្រអាពាហ៍ពិពាហ៍) ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅពេលដែលចង់បញ្ចប់ចំណងអាពាហ៍ពិពាហ៍គឺមានតែអំណាចតុលាការទេទើបអាចកាត់សេចក្តីអោយលែងលះបាន។ សំបុត្រអាពាហ៍ពិពាហ៍មានសារៈសំខាន់ណាស់នៅពេលដែលភាគីទាំងសងខាងសម្រេចថាលែងលះគ្នាដោយស្របច្បាប់ ព្រោះសំបុត្រអាពាហ៍ពិពាហ៍បានចងភ្ជាប់កាតព្វកិច្ចនឹងផលប្រយោជន៍ដែលត្រូវទទួលបានក្រោយលែងលះ។ ដោយហេតុនេះហើយសំបុត្រអាពាហ៍ពិពាហ៍ក៏ត្រូវភ្ជាប់ជាឯកសារសម្រាប់ដាក់ពាក្យសុំលែងលះផងដែរ។

[22] មាត្រា២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមានជាបណ្តឹង ឆ្នាំ២០១០

### ២.១.៣.៣ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ក្នុងករណីដែលប្តីប្រពន្ធបានធ្វើកិច្ចសន្យា ផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ភាគីអាចប្រើប្រាស់កិច្ចសន្យានេះមកធ្វើជាឯកសារភ្ជាប់បាន។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធអាចជាការព្រមព្រៀងរបស់ភាគីក្នុងការបែងចែកទ្រព្យ ឬ ជាការផ្តល់សិទ្ធិទៅឲ្យភាគីម្ខាងទៀត ឬអាចជាការដាក់ទ្រព្យដោយឡែកឲ្យក្លាយទៅជាទ្រព្យរួម ឬអាចជាការដាក់ទ្រព្យរួមទៅជាទ្រព្យដោយឡែក។ កំណត់អំពីទំនាក់ទំនង កាតព្វកិច្ចសិទ្ធិលើបំណុល ជាពិសេសការចាត់ចែងកាតព្វកិច្ចដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ បន្ទុកនៃកាតព្វកិច្ចជាក់លាក់ដែលអាចកើតមានឡើងក្រោយរៀបអាពាហ៍ពិពាហ៍ជាអាទិ៍។ ការកំណត់ពីសិទ្ធិគ្រប់គ្រង និង ចាត់ចែងទ្រព្យសម្បត្តិដូចជា សិទ្ធិគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យដោយឡែករបស់ប្តីឲ្យទៅជារបស់ប្រពន្ធជាដើម។

ឧទាហរណ៍៖ សំណាង បានរៀបការជាមួយ គន្ធា។ មុនពេលរៀបអាពាហ៍ពិពាហ៍សំណាងធ្វើការសន្សំបានប្រាក់មួយចំនួនដាក់ក្នុងធនាគារ ដែលជាទ្រព្យដោយឡែក។ ក្រោយរៀបការរួចសំណាងបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិជាមួយគន្ធាដោយយកលុយសន្សំក្នុងធនាគារដាក់ជាទ្រព្យរួម។

### ២.១.៣.៤ ការស្រាវជ្រាវពិនិត្យភស្តុតាងផ្សេងៗ

ភស្តុតាងស្ទើរតែគ្រប់ប្រភេទអាចត្រូវបានប្រមូល និងប្រើប្រាស់នៅក្នុងការកាត់ក្តីលែងលះ។ ភស្តុតាងទាំងនេះរួមមាន ឯកសារ រូបថត វីដេអូ និងប្រភេទផ្សេងៗជាច្រើនទៀត។ ភាគីដែលចង់លែងលះគួរតែចងក្រងជាឯកសារឱ្យបានច្រើនតាមដែលអាចធ្វើទៅបាននៅក្នុងអំឡុងពេលដែលចាប់ផ្តើមមានបញ្ហាជាមួយគ្នា ព្រោះភស្តុតាងមានប្រយោជន៍ជាច្រើននៅក្នុងសវនការ ហើយភាគីក៏អាចប្រើប្រាស់ភស្តុតាងនេះជាអានុភាពក្នុងដំណាក់កាលសម្របសម្រួលការលែងលះផងដែរ។ ភស្តុតាងអាចមានសារៈសំខាន់ខ្លាំងណាស់ក្នុងការកាត់ក្តីលែងលះដោយសារហេតុផលមួយចំនួនដូចជា បង្ហាញអំពីចំណូលរបស់ភាគីប្តី ឬ ភាគីប្រពន្ធអាចរកបានទុកសម្រាប់ការគណនាអាហាររូបត្ថម្ភ ឯកសារបង្ហាញអំពីទ្រព្យសម្បត្តិដែលមានមុន ឬ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ ពេលខ្លះអាចជារូបថតនៃការចាប់បាន ការលួចលាក់ផិតឬស្មន់ រូបថតបង្ហាញអំពីស្លាកស្នាមដែលភាគីប្រើប្រាស់ហិង្សាជាដើម។

ជាក់ស្តែង តុលាការអាចយកអង្គហេតុដែលអ្នកដាក់ពាក្យសុំបានអះអាង ឬ ភាគីម្ខាងទៀតមកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន ព្រោះថានៅក្នុងអង្គហេតុបានបង្ហាញយ៉ាងច្បាស់អំពីហេតុផលគ្រប់គ្រាន់ ព្រមទាំងភាគីមានការយល់ព្រមក្នុងការលែងលះដោយគ្មានការកែប្រែនោះទេ។[23] ប្រសិនបើតុលាការយល់ឃើញថាហេតុ

[23] មាត្រា២៧ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

ផលដែលគូរភាគីបានផ្តល់មានចំណុចខ្វះខាតនិងមានការសង្ស័យតុលាការចាំបាច់ ត្រូវធ្វើការស្រាវជ្រាវអង្គហេតុ និង ធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ ដើម្បីស្វែងរកចំណុចវិវាទ ដែលភាគីបានលើកឡើងអំពីហេតុផលក្នុងការលែងលះចៀងវាងមានការចោទប្រកាន់ ឬ និយាយបំភ្លើសការពិត នឹងជួយជំរុញដល់នីតិវិធីតុលាការទទួលបាន លទ្ធផលត្រឹមត្រូវនិងច្បាស់លាស់សម្រាប់ភាគីទាំងសងខាង នឹងជួយអោយនីតិវិធីតុលាការកាន់តែមានភាពយុត្តិធម៌ថែមទៀតផង។

### ២.១.៤ ការបង់ពន្ធដាក់ពាក្យសុំ

បន្ទាប់ពីធ្វើពាក្យសុំរួចហើយ គឺត្រូវតែទៅបង់ពន្ធជាសាច់ប្រាក់។ ពន្ធដាក់ពាក្យសុំនេះជា ពន្ធដែលភាគីចាំបាច់ក្នុងការបង់ ហើយបង់ទៅតាមចំនួនដែលច្បាប់បានកំណត់រួច។ អ្នកដាក់ពាក្យសុំត្រូវតែរួសរាន់បង់ពន្ធដែលមានទឹកប្រាក់ចំនួន ៥០០០ (ប្រាំពាន់) រៀល ទៅលើពាក្យសុំនោះ។[24] ការបង់ពន្ធនោះគឺត្រូវបង់នៅខាងផ្នែករដ្ឋបាលនៃសាលាដំបូងខេត្តឬ ក្រុងដែលខ្លួនរស់នៅហៅថា កន្លែងទទួលពាក្យសុំនៃតុលាការ។[25] ចំពោះប្រាក់ប្រដាប់ក្តីនេះជាបន្ទុករបស់អ្នកដាក់ពាក្យសុំ តែលើកលែងក្នុងករណីមួយចំនួនដែលកំណត់ពិសេសពីអ្នកទទួលបន្ទុកនោះក្នុងច្បាប់ប៉ុណ្ណោះ។[26] ប្រសិនអ្នកដាក់ពាក្យសុំមិនបានធ្វើការបង់ពន្ធនេះទេ តុលាការនឹងលើកពាក្យសុំចោលតែម្តង ក្នុងករណីតុលាការបានកំណត់ពេលណាមួយដែលសមរម្យហើយបង្គាប់ឲ្យបង់ពន្ធនោះ។[27]

### ២.១.៥ សោហ៊ុយនីតិវិធី

សោហ៊ុយនីតិវិធីក្នុងរឿងលែងលះនេះ តុលាការជាអ្នកចេញលិខិតបង្គាប់ឲ្យភាគីបង់ ពោលគឺ តុលាការដែលមានសមត្ថកិច្ចជាអ្នកកំណត់សោហ៊ុយទៅតាមភាពជាក់ស្តែងដោយមើលទៅលើស្ថានភាពនៃរឿងក្តី ពោលគឺមិនអាចកំណត់ជាក់លាក់បានទេ។ ជាឧទាហរណ៍ ប្រសិនបើ ទីតាំងនៅឆ្ងាយពីតុលាការប្រាកដជាអស់សោហ៊ុយច្រើនហើយ។ សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ សោហ៊ុយស្នាក់នៅសម្រាប់ភាគី ដើម្បីបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់។ មួយវិញទៀត សោហ៊ុយផ្សេងទៀតដែលតុលាការទទួលស្គាល់ថាចាំបាច់ក្នុងការអនុវត្តនីតិវិធីបណ្តឹង។ ចំពោះការពិនិត្យភស្តុតាងស្រាវជ្រាវអង្គហេតុ និងសាកសួរភាគីដែលប្រព្រឹត្តនៅក្រៅតុលាការ មានការកំណត់យ៉ាងចាំបាច់ពីសំណាក់ចៅក្រម និងក្រឡាបញ្ជី។ ប៉ុន្តែនេះជា

---

[24] មាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[25] កថាខណ្ឌទី៧ នៃមាត្រា៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[26] កថាខណ្ឌទី៣ នៃមាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[27] កថាខណ្ឌទី៦ នៃមាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធដែលភាគី ឬបុគ្គលដែលមានការទាក់ទងនឹងរឿងក្តីលែងលះនេះត្រូវបង់ប្រាក់សម្រាប់ការចំណាយជាមុនដល់តុលាការ។[28]

### ២.១.៦ ការទាញហេតុផលដោយផ្ទាល់មាត់

ការទាញហេតុផលជំនុំជម្រះ ឬការទាញហេតុផលដោយផ្ទាល់ ក្នុងរឿងក្តីស៊ីវិលនេះ អាចថាជាដំណាក់កាលចុងក្រោយ។ ជាក់ស្តែង តុលាការមិនចាំបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ឡើយក្នុងការចេញដីកាសម្រេចពីរឿងក្តីលែងលះដោយការព្រមព្រៀងនេះ។[29] ជាងនេះទៅទៀតនោះ តុលាការអាចអនុញ្ញាតឲ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យ ចូលមកស្តាប់សេចក្តីសម្រេច ក្នុងករណីតុលាការសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនឯទៀតដែលតុលាការយល់ឃើញថាចាំបាច់។[30] គេសង្កេតឃើញថា ភាគច្រើនគឺគេធ្វើជានីតិវិធីសាកសួរភាគីវិញ ពោលគឺធ្វើឡើងនៅក្នុងបន្ទប់ផ្ទាល់របស់លោកចៅក្រមតែម្តង។

### ២.១.៧ ការកោះហៅ

ក្នុងការកោះហៅគូភាគីទាំងសងខាង ឬអ្នកដាក់ពាក្យសុំ គឺតុលាការជាអ្នកធ្វើការកំណត់ថ្ងៃបរិច្ឆេទឲ្យចូលមកតុលាការ ដើម្បីដំណើរការនីតិវិធីលែងលះដោយការព្រមព្រៀងនេះ ហើយភាគីត្រូវតែមកបង្ហាញខ្លួន ជានិច្ច។[31] ប្រសិនបើភាគីមិនបានមកបង្ហាញខ្លួនតាមការកោះហៅដោយពុំមានមូលហេតុច្បាស់លាស់ត្រឹមត្រូវទេនោះ តុលាការអាចផាកពិន័យភាគីនោះបាន ដោយការពិន័យជាប្រាក់នេះគឺមានសាច់ប្រាក់មិនលើសពី ១ ០០០ ០០០ (មួយលាន) រៀលឡើយ។[32] គោលបំណងក្នុងការកោះហៅនេះ គឺដើម្បីអ្នកដាក់ពាក្យសុំ ធ្វើការអះអាងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរជាដើម។ ទោះបីនេះជាការលែងលះដោយមានការព្រមព្រៀង និងជាការសម្តែងពីឆន្ទៈរបស់ភាគីក៏ពិតមែន ក៏ចៅក្រមនៅតែធ្វើការព្យាយាមផ្សះផ្សាឲ្យមានការត្រូវរ៉ូវគ្នាវិញដែរ។

## ២.២ ការចេញសេចក្តីសម្រេចដោយតុលាការ

### ២.២.១ ដីកាសម្រេច

ក្រោយពេលដែលសំណុំរឿងត្រូវបានបញ្ជូនទៅកាន់តុលាការ ដោយតុលាការមិនអាចធ្វើការវិនិច្ឆ័យបានភ្លាមៗនោះទេ ពីព្រោះថា តុលាការត្រូវធ្វើការសាកល្បងផ្សះផ្សាទៅកាន់សហព័ទ្ធតាមលទ្ធភាពដែលអាចធ្វើបាន។ ប្រសិនបើតុលាការយល់ឃើញថា ភាគីមិនអាចផ្សះផ្សាបន្តទៅទៀតបាន ពិតជាអស់មនោសញ្ចេតនា និង

---

[28] កថាខណ្ឌទី៣ នៃមាត្រា៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[29] កថាខណ្ឌទី១ នៃមាត្រា២៨ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[30] កថាខណ្ឌទី២ នៃមាត្រា២៨ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[31] កថាខណ្ឌទី១ នៃមាត្រា២៩ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[32] កថាខណ្ឌទី២ នៃមាត្រា២៩ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

មានបំណងលែងលះគ្នាពិតប្រាកដមែន នោះនីតិវិធីចុងក្រោយ តុលាការនឹងចេញសេចក្តីសម្រេចឲ្យលែងលះដោយឆ្លើយតបចំពោះការទាមទាររបស់អ្នកដាក់ពាក្យសុំ។ ដីកាសម្រេចត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានសរសេរពីសំអាងហេតុនិងសេចក្តីបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើដីកានេះ។

មួយវិញទៀត ដីកាសម្រេចនេះត្រូវជូនដំណឹងទៅដល់បុគ្គលប្តីនិងប្រពន្ធដែលត្រូវទទួលនោះ តាមរយៈការបញ្ជូន ឬការផ្ញើរឯកសារចម្លងយថាភូតនៃដីកាសម្រេចនោះ។[33] ដីកាសម្រេចចំពោះការលែងលះដោយមានការព្រមព្រៀងនេះ នឹងមានអានុភាពដោយការចូលជាស្ថាពរ។ ក្នុងរយៈពេល២សប្តាហ៍បន្ទាប់ពីការជូនដំណឹង បើគ្មានការបណ្តឹងឧបាស្រ័យទេ ដីកាសម្រេចនោះនឹងចូលជាស្ថាពរ។[34]

### ២.២.២ បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេច

ទោះបីការលែងលះនេះជាការព្រមព្រៀងក៏ដោយ ក៏ភាគីទាំងសងខាងអាចមាននូវការកើតទុក្ខមិនសុខចិត្តដែរដូចជា ការមិនពេញចិត្តពាក់ព័ន្ធនឹងការបែងចែកទ្រព្យសម្បត្តិនិងកូនជាដើម។

បណ្តឹងឧបាស្រ័យជាបណ្តឹងទៅកាន់តុលាការជាន់ខ្ពស់។ បណ្តឹងនេះជា បណ្តឹងដែលទាមទារដោយភាគីណាមួយ ដើម្បីសុំឲ្យតុលាការជាន់ខ្ពស់លុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចចេញដោយតុលាការជាន់ក្រោមនៅមុនពេលសេចក្តីសម្រេចមិនទាន់ចេញជាស្ថាពរ។[35] បណ្តឹងឧបាស្រ័យនេះ គឺសំដៅដល់ការធ្វើបណ្តឹងជំទាស់ដែលអាចធ្វើបានទាល់តែមានចែងកំណត់ជាក់លាក់ជាមុន ហើយអាចធ្វើបានតែម្តងគត់។[36] ជាក់ស្តែង ក្នុងសង្គមយើងគឺពុំសូវមាន ឬកម្រណាស់មានបណ្តឹងឧបាស្រ័យណាស់ក្នុងរឿងក្តីនៃការលែងលះដោយការព្រមព្រៀង។ នេះក៏ដោយសារតែ រឿងប្រភេទនេះជារឿងដែលមានការព្រមព្រៀងគ្នា និងជាសិទ្ធិឯកជនរបស់ប្តីប្រពន្ធផងដែរ។ មួយវិញទៀត ការសម្រេចខុសពីការទាមទាររបស់អ្នកដាក់ពាក្យសុំក៏ពុំងាយកើតមាននោះដែរ។

ប្រសិនបើរឿងក្តីនៃការលែងលះដោយការព្រមព្រៀងនេះមានការប្តឹងជំទាស់ មានតែបុគ្គលដែលជាប្តី ឬប្រពន្ធប៉ុណ្ណោះអាចមានសិទ្ធិប្តឹង ពីព្រោះរឿងក្តីនេះចាប់ផ្តើមដំណើរការដោយសារពួកគាត់ មិនមែនដោយឆន្ទានុសិទ្ធិ ឬអំណាចរបស់ចៅក្រមនោះឡើយ។[37] ចំពោះរយៈពេលនៃការប្តឹងជំទាស់គឺមានចំនួន២សប្តាហ៍ គិតចាប់ពីថ្ងៃទទួលដំណឹងពីដីកាសម្រេច។ ក្នុងករណីដែលភាគីអាចប្តឹងជំទាស់ដោយមិនគោរពរយៈពេលនោះទេ គឺអាចត្រូវបន្ថែមចំនួន១សប្តាហ៍ទៀតបើសិនជាគ្មានកំហុស។ មួយវិញទៀត បើភាគីនោះជាជនបរទេស រយៈពេលនៃ

[33] មាត្រា៣៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[34] មាត្រា៤០ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[35] សេចក្តីពន្យល់អំពី ក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី១៖ នីតិវិធីបណ្តឹង

[36] មាត្រា២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[37] កថាខណ្ឌទី២ នៃមាត្រា៣៩ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

ការប្តឹងជំទាស់នឹងត្រូវបន្ថែមឲ្យចំនួន២ខែ។[38] នៅពេលដាក់ពាក្យប្តឹងជំទាស់ត្រូវបង់ពន្ធដាក់ពាក្យសុំចំនួន ៥០០០(ប្រាំពាន់) រៀល។[39] បន្ទាប់មកទៀត ពាក្យបណ្តឹងនោះនឹងត្រូវបានបញ្ជូនទៅចៅក្រមទទួលបន្ទុកដែលជាអ្នកចេញដីកាសម្រេចឲ្យភាគីនោះ ដោយគាត់បង្គាប់ឲ្យក្រឡាបញ្ជីធ្វើការថតចម្លងលិខិតទាំងអស់ដោយមានបញ្ជាក់ថាថតចម្លងត្រឹមត្រូវតាមច្បាប់ដើម រួចបញ្ជូនសំណុំរឿងថតចម្លងនោះជាមួយពាក្យប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ដែលជាទូទៅមិនឲ្យលើសពី២សប្តាហ៍ ពោលគឺយ៉ាងលឿនបំផុតតាមដែលអាចធ្វើទៅបាន។[40]

[38] មាត្រា៤០និង៤១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[39] មាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[40] មាត្រា៤២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

# ជំពូកទី៣៖

# សិទ្ធិ និងភាតព្វកិច្ចក្រោយពេលលែងលះ

# ជំពូកទី៣៖ សិទ្ធិនិង ភាតព្វកិច្ចក្រោយការលែងលះ

## ៣.១ ទំនាក់ទំនងចំពោះភាគី

### ៣.១.១ ទំនាក់ទំនងរវាងកូននិងឪពុកម្តាយ

ជាទូទៅ ភាគីទាំងពីរក្លាយជាជនដទៃហើយ គ្មានចំណងគតិយុត្តទៀតនោះទេ គឺនៅមានតែជាមួយកូនតែប៉ុណ្ណោះ។ សាលក្រមដែលសម្រេចឲ្យប្តី ប្រពន្ធលែងលះគ្នានោះត្រូវសម្រេចអំពីអំណាចមេបា ដែលត្រូវប្រគល់ទៅឲ្យឪពុក ឬ ទៅម្តាយហើយនឹងត្រូវ សម្រេចអំពីការប្រាស្រ័យទាក់ទងគ្នារវាងឪពុកម្តាយនិងកូននោះផង។[41] អ្នកដែលមានអំណាចមេបាត្រូវពិភាក្សាជាមួយឪពុក ឬម្តាយដែលគ្មានអំណាចមេបាអំពីចំណុចទាក់ទងទៅនឹងកូនដូចជា ការអប់រំកូន ការផ្លាស់ប្តូរទីសំណាក់ សកម្មភាពព្យាបាល និង អាជីវកម្មឬវិជ្ជាជីវៈរបស់កូនជាដើម។[42]

### ៣.១.២ ករណីយកិច្ចអ្នកមានអំណាចមេបាលើកូន

ជាគោលការណ៍ នៅពេលដែលលែងលះគ្នា អ្នកមានអំណាចមេបាលើកូនត្រូវសម្រេចតាមកំណត់តាមការពិភាក្សារបស់ឪពុកម្តាយ។[43] ការប្រគល់អំណាចមេបា គឺជាការប្រគល់សិទ្ធិគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សា អប់រំកូនទៅភាគីណាមួយក្រោយពីបានលែងលះគ្នាហើយ។[44] ជាគោលការណ៍ទូទៅ កូនដែលនៅបៅដោះម្តាយគឺជាអ្នករក្សាបីបាច់កូន។ ចំពោះកូនជាអនីតិជន អ្នកមានអំណាចមេបាត្រូវអប់រំ មើលថែកូនឲ្យបានដិតដល់បំផុតដោយ មានការផ្គត់ផ្គង់អាហាររូបត្ថម្ភគ្រប់គ្រាន់ និងដាក់ចូលសាលាល្អៗឲ្យកូនមានការសិក្សាចប់ចុងចប់ដើមជាដើម។ ផ្ទុយទៅវិញបើកូននោះមាននីតិភាពហើយ គេមិនចាំបាច់ប្រើអំណាចមេបាលើកូនទេ គឺគ្រាន់តែផ្តល់នូវអាហារកិច្ចប៉ុណ្ណោះ។

### ៣.១.៣ ករណីយកិច្ចរបស់អ្នកគ្មានអំណាចមេបា

សហព័ទ្ធដែលពុំមានអំណាចមេបាអាចទាមទារ អំណាចមេបាដោយយោងទៅលើស្ថានភាពរបស់កូន។ ករណីនេះក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានកំណត់ពីករណីយកិច្ចពិភាក្សាអំពីចំណុចមួយចំនួនដែលទាក់ទងនឹងការគ្រប់គ្រង ការថែរក្សាកូន រវាងអ្នកមាននិងអ្នកគ្មានអំណាចមេបាផងដែរ។ ចំពោះសហព័ទ្ធដែលមិនបានរស់នៅជាមួយកូន ឬគ្មានអំណាចមេបាមានសិទ្ធិមួយចំនួនដូចខាងក្រោម៖

---

[41] មាត្រា៧២ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ១៩៨៩

[42] មាត្រា១០៤២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[43] មាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[44] មាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

➢ សិទ្ធិសួរសុខទុក្ខកូន

ការប្រាស្រ័យទាក់ទងរវាងឪពុក ម្តាយ និង កូន បើទោះបីជាប្រពន្ធបានផ្តាច់ចំណងអាពាហ៍ពិពាហ៍ពិតមែន ប៉ុន្តែឪពុកឬ ម្តាយមានសិទ្ធិទៅ ប្រាស្រ័យទាក់ទងកូនបាន។ ភាគីដែលជាប្តីឬប្រពន្ធដែលពុំបានរក្សាកូន និងមិននៅជាមួយកូនមែនពិត តែនៅតែអាចមានសិទ្ធិទៅជួបសួរសុខទុក្ខកូនបានជម្មតា ហើយភាគីដែលទទួលសិទ្ធិថែរក្សាកូនត្រូវបង្កលក្ខណៈងាយស្រួលទៅដល់ភាគីម្ខាងទៀត។[45] ក្រោយពេលលែងលះគ្នា ឪពុកឬ ម្តាយដែលគ្មានអំណាចមេបាមានសិទ្ធិចូលជួប ប្រាស្រ័យទាក់ទងកូនៗបាន ព្រមទាំងមានការបង់សោហ៊ុយចាំបាច់ក្នុងការគ្រប់គ្រងថែរក្សាកូន។[46]

ឧទាហរណ៍៖ ក្នុងកិច្ចព្រមព្រៀងលែងលះ ភាគី"ខ" ដែលគ្មានអំណាចមេបា មានសិទ្ធិទទួលយកកូនប្រុសទៅដើរលេង និងសម្រាកជាមួយនៅរៀងរាល់ថ្ងៃចុងសប្តាហ៍ និងបុណ្យជាតិធំៗជាដើម។

➢ សិទ្ធិប្តឹងទៅតុលាការ

បើមានការប៉ះពាល់ដល់ផលប្រយោជន៍របស់កូន ភាគីប្តីឬប្រពន្ធដែលមិនបានរក្សាកូននោះ មានសិទ្ធិប្តឹងទៅតុលាការគ្រប់ពេលវេលាឲ្យដកសិទ្ធិរក្សាកូនពីភាគីម្ខាងទៀតដែលមានអំណាចមេបានោះបាន។[47]

### ៣.១.៤ ការផ្លាស់ប្តូរអ្នកមានអំណាចមេបា

នៅក្នុងសង្គមជាក់ស្តែង យើងតែងតែឃើញមានករណីផ្លាស់ប្តូរអំណាចមេបា មិនថាជាប្តី ឬប្រពន្ធទេគឺមានការប្តូរអ្នកមានអំណាចមេបាលើកូន។ បើទទួលស្គាល់ថាចាំបាច់ ដើម្បីផលប្រយោជន៍របស់កូន តុលាការអាចផ្លាស់ប្តូរអ្នកដែលមានអំណាចមេបា តាមការទាមទាររបស់ញាតិក្នុង៤ថ្នាក់របស់កូនដោយសារតែការសម្រេចចិត្តមួយចំនួនរបស់ឪពុកម្តាយ និងតុលាការ។[48] បើតាមបញ្ញត្តិច្បាប់ ក្នុងករណីដែលឪពុកម្តាយតែម្ខាងជាអ្នកមានអំណាចមេបា ហើយកូនបានធ្លាក់ក្នុងស្ថានភាពដែលពុំមានអ្នកមានអំណាចមេបាដោយសារអ្នកនោះត្រូវបានប្រកាសការព្យួរ ឬការដកហូតអំណាចមេបា ឬ បានលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបាលើកូន តុលាការអាចសម្រេចយកឪពុក ឬម្តាយដែលគ្មានអំណាចមេបាទៅលើកូន មកធ្វើជាអ្នកមានអំណាចមេបារបស់កូនបាន។[49]

---

[45] មាត្រា៧៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ១៩៨៩

[46] មាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[47] មាត្រា៧៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ១៩៨៩

[48] មាត្រា១០៣៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[49] កថាខណ្ឌ១ មាត្រា១០៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

មួយវិញទៀត នៅពេលលែងលះគ្នា បើឪពុក ឬម្តាយដែលធ្វើជាអ្នកមានអំណាចមេបាតាមការពិភាក្សា បានទទួលមរណភាព បើកូននោះគ្មានអ្នកមានអំណាចមេបាទេ ឪពុក ឬម្តាយដែលពុំមានអំណាចមេបានោះ ត្រូវក្លាយជាអ្នកមានអំណាចមេបា។[50] ជាឧទាហរណ៍ជាក់ស្តែង ក្នុងកំឡុងពេលដែលម្តាយមានអំណាចមេបាលើកូនដែលជាអនីតិជន កូននឹងត្រូវបានទៅលើខាងឪពុកវិញ បើម្តាយរបស់ក្មេងបានស្លាប់បាត់បង់ជីវិតចោលកូនទៅហើយ។

### ៣.១.៤.១ វិបល្លាសស្មារតី

ភាគីដែលជាប្តី ឬប្រពន្ធមិនអាចមើលថែកូនឲ្យបាន ហើយសូម្បីតែសាមីខ្លួនក៏មិនអាចមើលថែខ្លួនឯងបានដែរដោយសារតែមានបញ្ហាខួរក្បាលនេះឯង។ ដូចនេះ កូននឹងត្រូវបានភាគីម្ខាងទៀតជាអ្នកមើលថែរក្សានិងមានអំណាចមេបាទៅលើកូននោះ។ មួយវិញទៀតបុគ្គលនោះ ប្រាកដជាត្រូវការជំនួយនិង ការទំនុកបម្រុងពីសំណាក់ភាគីម្ខាងទៀត។

ឧទាហរណ៍៖ ក្រោយពេលដែលធ្វើការលែងលះគ្នាជាមួយប្រពន្ធមក លោក រតនា ចាប់ផ្តើមមានវិបត្តិផ្លូវចិត្ត វង្វេងវង្វាយស្ទើររាល់ថ្ងៃ។ ប៉ុន្តែគាត់ជាអ្នកមានអំណាចមេបាលើកូនប្រុសរបស់គាត់ ដោយត្រូវធ្វើការរកប្រាក់មកចិញ្ចឹមកូន។ អស់រយៈពេល១ឆ្នាំមក ជំងឺផ្លូវចិត្តរបស់គាត់កាន់តែធ្ងន់ទៅៗ ដល់ថ្នាក់មិនស្គាល់កូនប្រុសខ្លួនឯង។ ក្នុងករណីនេះផងដែរនឹងមានការផ្លាស់ប្តូរអ្នកមានអំណាចមេបា។

### ៣.១.៤.២ ករណីមានជំងឺ

ករណីភាគីប្តី ឬប្រពន្ធមានជំងឺធ្ងន់ធ្ងរ ហើយខ្សោយដែលមិនអាចអនុវត្តអំណាចមេបាបានល្អ ព្រោះពុំអាចថែទាំកូនឲ្យបានដិតដល់ នោះគេនឹងធ្វើការផ្លាស់ប្តូរអំណាចមេបាលើកូន។ សម្រាប់អ្នកដែលមានអំណាចមេបា កាលណាសុខភាពចុះអន់ថយហើយ គាត់មិនអាចទ្រាំទ្ររួចទេក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនដែលនៅក្រោមបន្ទុករបស់គាត់។

ឧទាហរណ៍៖ លោកស្រី ពិសីជាអ្នកមានអំណាចមេបាលើកូនតែម្នាក់របស់គាត់។ ដោយហេតុថា លោកស្រីកើតមានជំងឺធ្ងន់ធ្ងរដែលពុំអាចព្យាបាលបាន ពោលគឺជំងឺមហារីក គាត់មិនអាចមានពេលយូរទៀតទេក្នុងការចិញ្ចឹមកូនតូចរបស់គាត់។ ដូចនេះ អ្នកមានអំណាចមេបានឹងត្រូវផ្លាស់ប្តូរពីលោកស្រី ពិសី ទៅជាឪពុកដែលជាអ្នកមានអំណាចមេបាវិញ។

---

[50] កថាខណ្ឌ៣ មាត្រា១០៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ៣.១.៤.៣ ការប្រើអំពើហិង្សា

ការធ្វើការផ្លាស់ប្តូរអ្នកមានអំណាចមេបានេះ ជាយន្តការមួយក្នុងការជួយសង្គ្រោះកូនក្នុងករណីដែលភាគីដែលនៅជាមួយកូននោះបានវាយធ្វើបាបកូន មិនថាផ្លូវកាយ ឬផ្លូវចិត្តនោះទេ។ ការឃាត់ឃាំងកូនមិនឲ្យដើរហើរ មិនឲ្យទៅសាលារៀនសូត្រ ឬប្រើប្រាស់ពាក្យសម្តីវាយប្រហារកូន ក៏អាចហៅថាជាការធ្វើបាបផ្លូវចិត្តកូនដែរ។ កាលដែលមិនឲ្យកូនចូលសាលាទទួលយកចំណេះដឹង ការបិទសិទ្ធិកូនមិនឲ្យចេញក្រៅផ្ទះ ការប្រើដៃជើងទៅលើកូនខ្លួន អាចធ្វើឲ្យប៉ះពាល់ផ្លូវចិត្ត និងសតិអារម្មណ៍របស់កូនបានគ្រប់ពេលផងដែរ។ ប្រសិនជាមិនបានផ្លាស់ប្តូរអំណាចមេបាទេ កូនដែលរស់នៅជាមួយនោះ ប្រាកដជាមានបញ្ហាដល់ជីវិតប្រចាំថ្ងៃនាពេលបច្ចុប្បន្ន និងនាពេលអនាគតជាក់ជាពុំខាន។

ឧទាហរណ៍៖ លោក វីណា និងលោកស្រី ដាវី បានព្រមព្រៀងលែងលះគ្នា ដោយលោក វីណា ជាអ្នកមានអំណាចមេបាលើកូនប្រុសឈ្មោះ វិសាល។ ដើមឡើយ លោកវីណា ស្រឡាញ់ ថ្នាក់ថ្នមកូន គាត់ណាស់។ ប៉ុន្តែនៅពេលដែលរស់នៅជាមួយគ្នាបានពីរឆ្នាំ គាត់បានប្រើអំពើហិង្សាទៅលើ វិសាល ជាញឹកញ៉ាប់ ព្រោះគាត់តែងតែផឹកស្រាក្រោយមកពីធ្វើការហត់។ គាត់បានប្រព្រឹត្តទង្វើបែបនេះសឹងតែរាល់ថ្ងៃ ហើយដំណឹងនេះបានលិចឮទៅដល់ លោកស្រី ដាវី។ លោកស្រី ដាវីមិនពេញចិត្តនឹងទង្វើនេះឡើយ គាត់ក៏ចង់បានកូនប្រុសមកចិញ្ចឹមវិញ។ ដូចនេះដើម្បីផលប្រយោជន៍របស់កូនប្រុសនោះ តុលាការអាចផ្លាស់ប្តូរអ្នកដែលមានអំណាចមេបាបានដោយកូនប្រុសឈ្មោះ វិសាលត្រូវស្ថិតនៅក្រោមអំណាចមេបារបស់លោកស្រី ដាវី វិញ។

### ៣.១.៤.៤ បញ្ហាសេដ្ឋកិច្ច

អំណាចមេបាទៅលើកូនអាចនឹងត្រូវបានផ្លាស់ប្តូរ នៅពេលដែលភាគីមានអំណាចមេបារកប្រាក់ចំណូលបានតិចតួចបំផុតពោលគឺមានវិបត្តិសេដ្ឋកិច្ចដែលមិនអាចចិញ្ចឹមខ្លួននិងកូនរួច។ ហេតុដូចនេះហើយបុគ្គលនោះពុំមានលទ្ធភាពក្នុងការមើលថែរក្សាកូនឲ្យបានល្អប្រសើរឡើយ។

ឧទាហរណ៍៖ លោក វី ជាអ្នកមានអំណាចមេបាលើកូនចំនួន៣នាក់។ មុខរបររបស់គាត់ជាអ្នករត់ម៉ូតូឌុប ហើយរស់នៅយ៉ាងតោកយ៉ាកបំផុតនៅផ្លូវរថភ្លើង។ គាត់មានជីវភាពខ្វះខាតយ៉ាងខ្លាំងបន្ទាប់ពីលែងលះគ្នាជាមួយប្រពន្ធព្រមទាំងមានបន្ទុកកូន៣នាក់ទៀត។ ក្នុងទិដ្ឋភាពបែបនេះ ម្តាយក៏សម្រេចចិត្តថានឹងយកកូនៗមកចិញ្ចឹមវិញ ដោយសារតែខាងលោក វី ពុំមានប្រាក់គ្រប់គ្រាន់ក្នុងការមើលថែរក្សាកូនទាំង៣ឡើយ។ ដូច្នេះ អ្នកមានអំណាចមេបាត្រូវបានផ្លាស់ប្តូរ។

### ៣.១.៥ សិទ្ធិក្នុងការប្រើប្រាស់នាមត្រកូលសហព័ន្ធក្នុងច្បាប់

ជាទូទៅ សិទ្ធិប្រើប្រាស់នាមត្រកូលរបស់ប្ដីប្រពន្ធក្នុងអំឡុងពេលរៀបការ ប្ដីប្រពន្ធខ្លះប្រើនាមត្រកូលរបស់សហព័ទ្ធម្ខាងទៀត។ បន្ទាប់ពីការលែងលះក៏ភាគីក៏នៅតែមានសិទ្ធិប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធផងដែរ ពោលគឺការប្រើប្រាស់ត្រកូលរបស់ភាគីម្ខាងទៀតពុំមានបញ្ហាអ្វីឡើយ។ តាមច្បាប់គឺគេបានផ្ដល់ជម្រើសដល់ប្ដី ឬប្រពន្ធដែលចង់ផ្លាស់ប្ដូរនាមត្រកូលថ្មី ដោយអាចបន្តប្រើនាមត្រកូលមុនពេលរៀបការ ឬអាចប្រើប្រាស់នាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាបាន។[51]

### ៣.១.៦ សិទ្ធិក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មី

ជាទូទៅបន្ទាប់ពីលែងលះគ្នា ភាគីទាំងពីរមានសិទ្ធិរៀបការម្ដងទៀត។ សិទ្ធិមួយដែលបានបន្សល់ក្រោយពីការលែងលះ គឺការផ្ដល់ឱ្យភាគីប្ដី រឺប្រពន្ធនូវសិទ្ធិបង្កើតអាពាហ៍ពិពាហ៍ថ្មីតាមឆន្ទៈរបស់ភាគីទាំងសងខាង។ ក្នុងកំឡុងពេលរៀបការ ភាគីត្រូវបានហាមឃាត់ដោយច្បាប់ ក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មីបន្ថែមជាមួយអ្នកផ្សេងឡើយ។[52] នៅពេលដែលការលែងលះត្រូវបានបញ្ចប់ មានន័យថា ភាគីទាំងពីរមានសិទ្ធិទទួលបាននូវសិទ្ធិស្របច្បាប់ក្នុងការរៀបការម្ដងទៀត។ ទន្ទឹមនឹងគ្នានោះដែរ រយៈពេលដែលភាគីខាងប្រុសមានសិទ្ធិរៀបការម្ដងទៀតគឺមិនមានទេ។ ប៉ុន្តែសម្រាប់ស្ត្រី នៅក្នុងក្រមរដ្ឋប្បវេណីកំណត់រយៈពេលដែលស្ត្រីមានសិទ្ធិរៀបការម្ដងទៀត។ បន្ទាប់ពីការលែងលះ ខាងនារីត្រូវរង់ចាំ ១២០ (មួយរយម្ភៃ) ថ្ងៃ ដើម្បីរៀបអាពាហ៍ពិពាហ៍ពោលគឺត្រូវនៅទំនេរសិន។ អាពាហ៍ពិពាហ៍ថ្មីអាចប្រព្រឹត្តទៅបាន ១២០ (មួយរយម្ភៃ) ថ្ងៃ មុនថ្ងៃកំណត់ប្រសិនបើមានវិញ្ញាបនបត្រពីវេជ្ជបណ្ឌិតថា នារីនោះមិនមានផ្ទៃពោះ។[53] នេះគឺដើម្បីការពារការយល់ច្រឡំអំពីទំនាក់ទំនងរវាងទារកក្នុងផ្ទៃម្ដាយ ដែលអាចឱ្យឪពុករបស់ទារកមានការពិបាកក្នុងការបែងចែកច្បាស់។ ក្នុងករណីដែលខាងនារីច្បាស់ថា មិនមានផ្ទៃពោះ នាងមានសិទ្ធិពេញលេញក្នុងការរៀបការម្ដងទៀតបាន។ ប្រសិនបើប្ដីក្រោយគាត់បានព្រមព្រៀងទទួលស្គាល់មើលថែកូនដែលជាកូនប្ដីមុនហើយ ស្ត្រីនោះមិនចាំបាច់បំពេញលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់ដែលត្រូវតែពិនិត្យសុខភាពនោះក៏បានដែរ។

### ៣.១.៧ អានុភាពចំពោះទ្រព្យសម្បត្តិ

នៅក្នុងសង្គមកម្ពុជាការលែងលះគ្នារវាងប្ដីនិងប្រពន្ធ គឺជារឿងធម្មតាទៅហើយ តែអ្វីដែលគេមើលឃើញមិនធម្មតានោះ គឺការបែកចែកទ្រព្យសម្បត្តិគ្នានៅពេលលែងលះ។ ប្ដីឬប្រពន្ធតែងតែកើតមានជម្លោះរវាងគ្នានឹង

[51] មាត្រា៩៨១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[52] មាត្រា៩៤៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[53] មាត្រា៩៥០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

គ្នាទៅវិញទៅមកមិនចេះចប់មិនចេះហើយ រហូតឈានដល់ការប្ដឹងផ្ដល់ដល់តុលាការឱ្យជួយបែកចែកទ្រព្យ នៅពេលដែលភាគីណាមួយកើតទុក្ខមិនសុខចិត្ត។ ដូច្នេះហើយទើបនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាក៏មានចែងអំពីនីតិវិធីនៃការបែងចែកទ្រព្យសម្បត្តិដើម្បីបញ្ចប់នូវបញ្ហានេះផងដែរ។

**៣.១.៧.១ ទ្រព្យសម្បត្តិរួម**

ការបែងចែកទ្រព្យសម្បត្តិរួមក្រោយការលែងលះអាចធ្វើឡើងតាមការព្រមព្រៀងរបស់ភាគី សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយកមួយភាគពីរនៃទ្រព្យសម្បត្តិរួមដែលបានរករួមគ្នា។ ប៉ុន្តែបើមានករណីពិសេស និងមានការទាមទាររបស់ប្ដីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួមដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍កម្រិតជីវភាពរស់នៅ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូនជាអាទិ៍។

**៣.១.៧.២ ទ្រព្យសម្បត្តិដោយឡែក**

ក្រោយពេលលែងលះគ្នាចប់ហើយ សហព័ទ្ធនឹងទទួលបានទ្រព្យសម្បត្តិផ្ទាល់របស់ខ្លួន ដោយភាគីម្ខាងទៀតមិនអាចធ្វើការទាមទារបានឡើយ ព្រោះទ្រព្យសម្បត្តិដោយឡែកនេះស្ថិតនៅក្រោមកម្មសិទ្ធិរបស់ សហព័ទ្ធតែម្ខាង។ នៅពេលបែងចែកទ្រព្យសម្បត្តិក្រោយការសម្រេចចិត្តលែងលះ ទ្រព្យដោយឡែកត្រូវបានដកចេញដើម្បីកុំអោយមានការលាយលំជាមួយនឹងទ្រព្យរួមនៃចំណងអាពាហ៍ពិពាហ៍។ ទ្រព្យដោយឡែកមិនត្រូវបានចែកទៅឲ្យសហព័ទ្ធទេ ប៉ុន្តែបើក្នុងករណី ម្ចាស់ទ្រព្យយល់ព្រមក្នុងការចែកព្រោះដោយមូលហេតុផ្សេងៗដូចជា ទុកសម្រាប់ជាមធ្យាបាយ ជាការដោះទាល់ ឬ ឲ្យដោយនៅសល់មនោសញ្ចេតនាជាមួយគ្នាខ្លះ។ ភាគីក៏អាចចែកទ្រព្យដោយឡែកនេះមកឲ្យកូនបានដែរ ព្រោះជាទ្រព្យផ្ទាល់ខ្លួនឲ្យមកកូនដើម្បីជាកាដូរ ឬឲ្យសម្រាប់កូនទុកប្រើប្រាស់ទៅថ្ងៃមុខបាន។

ឧទាហរណ៍៖ ដា និង លីន បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា នឹងមានកូនប្រុសម្នាក់ឈ្មោះ ធា អាយុ៤ឆ្នាំ។ ក្រោយពីការរស់នៅជាមួយគ្នាមិនចុះសម្រុង ដា និង លីនក៏សម្រេចចិត្តលែងលះគ្នា ហើយកូនប្រុសឈ្មោះ ធា ត្រូវនៅជាមួយលីនដែលជាម្ដាយ។ ដា មានក្រុមហ៊ុន A មួយកន្លែងជាក្រុមហ៊ុនរបស់ឪពុកគាត់ដែលបានប្រគល់មកឲ្យ ដា ជាអ្នកបន្តវេន ក្រុមហ៊ុន A មានចំណូលចូលរាល់ខែ មុនពេលលែងលះចំណូលដែលបានមកពីក្រុមហ៊ុន A ដា បានឲ្យមកលីនរាល់ខែចំនួន១០លានរៀល។ ក្រោយពេលលែងលះ ដា ក៏នៅតែបន្តកាតព្វកិច្ចឲ្យប្រាក់មកលីនចំនួន ១០លានរៀលដដែល។

### ៣.១.៧.៣ ទ្រព្យសម្បត្តិតាមកិច្ចសន្យា

នៅក្នុងការបែងចែកទ្រព្យតាមកិច្ចសន្យាបែបនេះពិតជាមានភាពងាយស្រួលដល់ភាគីទាំងសងខាង ក្រោយពេលលែងលះ ដោយតម្រូវឲ្យភាគីព្រមព្រៀងតាម កិច្ចសន្យាទ្រព្យសម្បត្តិដែលបានបញ្ជាក់ចំនួនទ្រព្យសម្បត្តិ ឬ ជាគ្រឿងសម្ភារៈ ដោយសន្តិវិធី។ ប៉ុន្តែបើក្នុងករណីភាគីមានទំនាស់ និង មិនព្រមបែងចែកទ្រព្យតាមកិច្ចសន្យានោះទេ ភាគីទាំងសងខាងអាចធ្វើការដាក់ពាក្យប្តឹងទៅតុលាការដើម្បីបែងចែកជំនួសភាគី ដោយទុកឲ្យចៅក្រមជាអ្នកបែងចែក ព្រមទាំងស្វែងរកការពិតអំពីការព្រមព្រៀងលើការបែងចែកទ្រព្យរបស់ភាគីដូចបានចែងក្នុងកិច្ចសន្យា។

ឧទាហរណ៍៖ លោក សួរ និង ស្រីគីម បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន២ឆ្នាំ។ ក្រោយមក លោក សួរ បានផិតក្បត់ ស្រីគីម ដោយលោកសួរ មានស្រីកំណាន់ ធ្វើឲ្យស្រីគីម ឈឺចាប់ជាមួយនឹងទង្វើរបស់លោក សួរ ជាខ្លាំងទើបអ្នកទាំងពីរបានសម្រេចចិត្តលែងលះតែម្តង។ ក្នុងកំឡុងពេលរៀបការ លោកសួរ និង ស្រីគីម បានចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយបានបញ្ជាក់ថា ផ្ទះវីឡា២ខ្នង លុយ១០០លានរៀល ឡាន១គ្រឿង ត្រូវប្រគល់មកឲ្យស្រីគីមតែម្នាក់។

### ៣.១.៧.៤ ទ្រព្យសម្បត្តិតាមការព្រមព្រៀង

ចំពោះការបែងចែកទ្រព្យ ក្នុងករណីមានការលែងលះច្បាប់ទុកអាទិភាពទៅលើការព្រមព្រៀងរបស់ប្តីប្រពន្ធ។ ទ្រព្យតាមការព្រមព្រៀងអាចកើតមានឡើងតាមឆន្ទៈរបស់ភាគីយល់ឃើញថាជាការចាំបាច់ក្នុងការប្រគល់ទៅឲ្យភាគីម្ខាងទៀត ក្រោយពេលលែងលះ ។

ឧទាហរណ៍៖ លោក នី និង ចរិយា បានរួមរស់ជាមួយគ្នាដោយមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់។ លោក នី និង ចរិយាស្រលាញ់គ្នាណាស់តែដោយសារ លោក នី ជាគ្រួសារចិន ចង់បានកូនប្រុសស្នងត្រកូល ចរិយាមិនអាចមានកូនបានទេ លោក នី ក៏បានសម្រេចចិត្តលែងលះជាមួយចរិយា។ លោក នី និង ចិរិយា បានធ្វើជំនួញនឹងជួយឲ្យអ្នកទាំងពីរមានជីវភាពធូធារមានផ្ទះវីឡា មួយកន្លែងកំពុងរស់នៅ ដីចំនួន១០០ហិចតា មាស ១០ជី តែក្រោយសម្រេចចិត្តលែងលះលោកនី បានប្រគល់ទ្រព្យសម្បត្តិទាំងអស់ ទៅឲ្យចរិយា ទុកជាដើមទុនរកស៊ីទៅថ្ងៃមុខ ហើយលោកនី មិនបានសុំបែងចែកទ្រព្យសម្បត្តិទេ។

### ៣.១.៨ ទ្រព្យសម្បត្តិរបស់កូន

អ្នកមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និង ជាអ្នកតំណាងឲ្យកូនចំពោះសកម្មភាពដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ។ ប៉ុន្តែបើសកម្មភាពរបស់អ្នកមានអំណាចមេបា បង្កើតកាតព្វកិច្ច ដែលមានកម្មវត្ថុជាសកម្មភាពរបស់កូននោះ អ្នកមានអំណាចមេបា ត្រូវទទួល

យកការយល់ព្រមពីកូននោះសិន។[54] អ្នកមានអំណាចមេបាត្រូវមានកាតព្វកិច្ចមើលថែ គ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនដោយមានការប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត មិនត្រូវយកទ្រព្យសម្បត្តិរបស់កូនទៅធ្វើជារបស់ផ្ទាល់ខ្លួន ឬ ចាយវាយ ទិញដូរតាមចិត្តឡើយ ។[55] ទ្រព្យរបស់កូន មិនមែនសុទ្ធតែជាទ្រព្យដែលបានមកពីភាគីសហព័ទ្ធប្រគល់ឲ្យកូនក្រោយការលែងលះនោះទេ ទ្រព្យសម្បត្តិនេះក៏អាចបានមកពីជីដូន ជីតាបន្សល់ទុកជាកេរ្តិ៍សម្រាប់ចៅ ឬ ជាទ្រព្យសម្បត្តិដែលទទួលបានមកពីតតិយជនទៅឲ្យកូនដោយមិនគិតថ្លៃ ព្រមទាំងបានបង្ហាញឆន្ទៈមិនឲ្យទៅឪពុកម្តាយណាម្ខាង ឬ ទាំងសងខាងដែលអនុវត្តអំណាចមេបាគ្រប់គ្រងទ្រព្យសម្បត្តិនោះទេ ទ្រព្យសម្បត្តិនោះ ពុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយណាម្ខាងឬ ទាំងសងខាងឡើយ។[56]

សរុបមក នៅពេលដែលកូនគ្រប់អាយុ ហើយក្លាយជានីតិជនពេញសិទ្ធិ អ្នកមានអំណាចមេបាត្រូវគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ដោយគ្មានការយឺតយ៉ាវ។ ចំពោះសោហ៊ុយចិញ្ចឹមបីបាច់កូននោះ និង សោហ៊ុយគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ត្រូវចាត់ទុកថាបានទូទាត់ជាមួយនឹងផលចំណូលពីទ្រព្យសម្បត្តិរបស់កូននោះ។[57]

## ៣.២ កាតព្វកិច្ចក្រោយការលែងលះ

ទោះបីមានការបញ្ចប់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធដែលនៅរស់ក៏ដោយ តែកាតព្វកិច្ចរបស់សហព័ទ្ធនៅតែមាន។ កាតព្វកិច្ចដែលបានបន្សល់ទុកទៅដល់ភាគីក្រោយពេលលែងលះមានដូចជា កាតព្វកិច្ចបង់ថ្លៃចំណាយចាំបាច់ក្នុងការថែទាំកូន ការបញ្ចប់កាតព្វកិច្ចប្តីប្រពន្ធ និងកាតព្វកិច្ចចំពោះភាគីទីបីជាដើម។

### ៣.២.១ ការបង់សោហ៊ុយចាំបាច់ដើម្បីថែទាំកូន

ឪពុកម្តាយដែលរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវតែអនុវត្តនិងប្រើប្រាស់សិទ្ធិអំណាចមេបាក្នុងលក្ខណៈសាមគ្គីភាព ពោលគឺមានការសហការគ្នា។[58] ប៉ុន្តែ ក្រោយការលែងលះ មានតែភាគីម្ខាងមានសិទ្ធិ អំណាចមេបាលើកូនដែលជាអំណាចមេបាទោល។ ដោយសារការបែងចែកកូនពាក់ព័ន្ធនឹងអាហារ កាតព្វកិច្ចចិញ្ចឹមកូន ដូច្នេះហើយបន្ទាប់ពីលែងលះគ្នា តុលាការត្រូវពិចារណា និងសម្រេចថាភាគីណាជាឪពុកឬ ម្តាយមានសិទ្ធិអំណាចលើកូន។ ប្រសិនបើតុលាការកំណត់ថា ម្តាយជាអ្នកមានសិទ្ធិអំណាច ម្តាយត្រូវពិចារណាថាអ្នកមានសិទ្ធិក្នុងការ

[54] មាត្រា១០៥៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[55] មាត្រា១០៥៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[56] មាត្រា១០៥៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[57] មាត្រា១០៥៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[58] វាក្យខណ្ឌទី១ នៃមាត្រា១០៣៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ចំណាយចាំបាច់ដើម្បីមើលថែកូន ហើយឪពុកត្រូវពិចារណាថាអ្នកមានកាតព្វកិច្ចត្រូវចំណាយលើការចំណាយចាំបាច់ដើម្បីមើលថែកូន។[59] ដូច្នេះ ឪពុកម្ដាយអាចធ្វើការពិភាក្សាលើចំណុចនេះបាន[60] ប៉ុន្តែប្រសិនបើការពិភាក្សាមិនបានសម្រេចដោយភាពជោគជ័យទេនោះ តុលាការត្រូវសម្រេចលើការចំណាយចាំបាច់ ដើម្បីទទួលខុសត្រូវលើការមើលថែ។[61] ចំពោះករណីលែងលះដោយការព្រមព្រៀងដែលមានការយល់ស្របគ្នាទៅវិញទៅមករវាងឪពុកម្ដាយ ប្រាកដជាមិនមានអ្វីពិបាក និងសាំញ៉ាំ សម្រាប់តុលាការក្នុងការសម្រេចនោះ ឡើយ។

**៣.២.១.១ អាហារកិច្ចចំពោះកូន**

កាលណាមានការលែងលះគ្នាឪពុកម្ដាយដែលលែងលះគ្នានៅតែបន្តការទទួលខុសត្រូវចំពោះកូនតាមផ្លូវច្បាប់ដើម្បីជាការផ្គត់ផ្គង់កូនសម្រាប់ការចំណាយបីបាច់ថែរក្សា ជួយផ្ដល់សោហ៊ុយ ការអប់រំរៀនសូត្រ ថ្លៃសាលា ថ្លៃសម្ភារៈសិក្សា ការហូបចុកតាមលទ្ធភាពរបស់ខ្លួន។ ចំពោះអាហារកិច្ចដែលត្រូវឲ្យទៅកូនភាគីទាំងសងខាងអាចព្រមព្រៀងគ្នា ឬ គូរភាគីមិនឯកភាពគ្នាច្បាប់ផ្ដល់អាទិភាពទៅតុលាការជាអ្នកសម្រេចជំនួសដោយមើលទៅតាមស្ថានភាព និងលទ្ធភាពរបស់សហព័ទ្ធម្នាក់ៗ។

ជាឧទាហរណ៍ជាក់ស្ដែង នៅក្នុងកិច្ចព្រមព្រៀងលែងលះ ភាគី″ក″ និងភាគី″ខ″ ត្រូវបំពេញកាតព្វកិច្ចបង់ អាហារកិច្ចដល់កូនប្រុសរហូតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ ប៉ុន្តែបើកូនចង់បន្តការសិក្សា ភាគី″ខ″ នឹងជួយជ្រោមជ្រែងបន្ថែមទៅតាមលទ្ធភាពរបស់ខ្លួនទៀត។

**៣.២.១.២ អាហារកាតព្វកិច្ច**

ជាទូទៅ ការបញ្ចប់អាពាហ៍ពិពាហ៍មានន័យថា សហព័ទ្ធបញ្ចប់សិទ្ធិនិង កាតព្វកិច្ចដែលមានចំពោះគ្នាក្នុងឋានៈជាប្ដីប្រពន្ធ។ ទោះបីភាគីទាំងពីរបានលែងលះគ្នាក្លាយទៅជាអ្នកដទៃក៏ដោយ ក៏ភាគីប្ដីឬប្រពន្ធដែលមានភាពខ្វះខាតអាចស្នើសុំអាហារកាតព្វកិច្ចពីភាគីម្ខាងទៀតបានដែរដោយជួយឧបត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួនហើយ កម្រិតនៃអាហារកាតព្វកិច្ចនេះត្រូវមានការសម្រេចចិត្តយល់ព្រមរបស់ភាគីទាំងសងខាងផងដែរ។[62] ប៉ុន្តែកាតព្វកិច្ចមួយចំនួននៅតែត្រូវបំពេញចំពោះគ្នាដូចក្នុងកំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ដែរ ដើម្បីបំពេញករណីយកិច្ច ផ្គត់ផ្គង់ឪពុកម្ដាយរបស់សហព័ទ្ធអាចជាប្រាក់ឬជាទ្រព្យសម្បត្តិផ្សេងទៀតដែលជាការចេញឲ្យ។ ការចេញប្រាក់បែបនេះហៅថា អាហារកាតព្វកិច្ច។ អាហារកាតព្វកិច្ចត្រូវបំពេញតាមច្បាប់ ឬតាមសេចក្ដី

---

[59] កថាខណ្ឌ១ នៃមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[60] កថាខណ្ឌ២ និង៣ នៃមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[61] កថាខណ្ឌ៤ នៃមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[62] មាត្រា៧៦ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ១៩៨៩

សម្រេចរបស់តុលាការអំពីអាហារកាតព្វកិច្ចតាមពាក្យសុំឬដោយឆន្ទៈរបស់ខ្លួនបាន ប្រសិនបើតុលាការយល់ឃើញថាចាំបាច់ ដែលតម្រូវអោយបុគ្គលដែលមានកាតព្វកិច្ចផ្តល់នូវប្រាក់ឬទ្រព្យដល់បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងញាតិនឹងគ្នា។[63]

**ក.ចំពោះឪពុកម្តាយ**

ចំពោះកាតព្វកិច្ចដែលកើតចេញពីកិច្ចការគ្រួសារប្រចាំថ្ងៃ ត្រូវក្លាយជាការទទួលខុសត្រូវ យ៉ាងហោចណាស់យើងត្រូវទទួលស្គាល់ការផ្តល់អាហារកាតព្វកិច្ចពីភាគីអតីតសហព័ទ្ធដែលមានជីវភាពធូរធារ ជួយមកខាងភាគីម្ខាងទៀតដែលកំពុងមានជីវភាពលំបាក។ ចំណុចដែលត្រូវពិចារណាមានដូចជា ធនធាន ចំណូលប្រចាំថ្ងៃ អាយុ ការងារ ស្ថានអំពីជីវភាពដែលមានក្រោយពេលលែងលះ។ ចំពោះការផ្គត់ផ្គង់ឪពុកម្តាយពិតជារឿងត្រឹមត្រូវណាស់ព្រោះ ពួកគាត់សុទ្ធតែមានវ័យចាស់ជរា ឪពុកម្តាយខ្លះក៏មានជម្ងឺទៀតផង ដូចនេះទោះបីជាមានការលែងលះប៉ុន្តែការផ្គត់ផ្គង់អាហាកាតព្វកិច្ចចំពោះឪពុកម្តាយ គួរតែបន្តមានផងដែរ។

ឧទាហរណ៍៖ តុលា ជាម្ចាស់ក្រុមហ៊ុនមានចំណូលខ្ពស់ ចំណែកឯ ធីតា ជាអ្នកកាត់ដេរ អ្នកទាំងពីរបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន៦ឆ្នាំ ក៏បានលែងលះគ្នា។ កំឡុងពេលរួមរស់ជាមួយគ្នាតុលា តែងតែផ្គត់ផ្គង់ម្តាយឪពុករបស់ ធីតា ជារៀងរាល់ខែ មួយខែ ២លានរៀល សម្រាប់ការចាយវាយរបស់ពួកគាត់ ។ នៅពេលលែងលះ ធីតាជាជាងកាត់ដេរ ចំណូលក៏មិនសូវបានច្រើន តុលាឃើញបែបនេះក៏សម្រេចថា នឹងជួយផ្គត់ផ្គង់ដល់ឪពុកម្តាយ ធីតា មួយខែ ២លានរៀលដដែល ។

**ខ.ចំពោះសាច់ញាតិ**

អាហារកាតព្វកិច្ចចំពោះញាតិជាសញ្ញាណថ្មីមួយទាំងផ្នែកទ្រឹស្តី និង ការអនុវត្តទោះបីជានៅក្នុងក្រមរដ្ឋប្បវេណីខ្មែរសង្គមចាស់ ក៏ពុំមានចែងអំពីអាហារកាតព្វកិច្ចប្រភេទនេះដែរ។ អាហារកាតព្វកិច្ចចំពោះញាតិសម្រាប់តែជនដែលមានករណីយកិច្ចត្រូវផ្តល់មានទំនាក់ទំនងញាតិជាក់លាក់មួយជាមួយជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ដោយមិនរាប់បញ្ចូល នូវទំនាក់ទំនងរវាង សហព័ទ្ធនិងទំនាក់ទំនងរវាងឪពុកម្តាយនិងកូនដែលជាអនីតិជននោះឡើយ។

**៣.២.២ ការបញ្ចប់ករណីយកិច្ចសហព័ទ្ធ**

ជាការពិតណាស់ ក្នុងអំឡុងពេលរៀបការជាមួយគ្នា ប្តីប្រពន្ធត្រូវតែមានភារកិច្ចនិងករណីយកិច្ចរួមគ្នាដូចជា ការរួមរស់ជាមួយគ្នា កិច្ចសហការគ្នា និងការជួយសង្គ្រោះគ្នាទៅវិញទៅមក ដើម្បីកសាងគ្រួសារ

[63] មាត្រា៧៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ១៩៨៩

ប្រកបដោយសុខសុភមង្គល។[64] ប៉ុន្តែអ្វីៗទាំងអស់នេះនឹងត្រូវបានបញ្ចប់ដោយការលែងលះ។ ដូច្នេះហើយ នៅពេលដែលសហព័ទ្ធធ្វើការលែងលះគ្នា ភាគីទាំងសងខាងនឹងត្រូវបានរួចផុតពីកាតព្វកិច្ចទាំងនោះ។

### ៣.២.៣ កាតព្វកិច្ចចំពោះតតិយជន

កាតព្វកិច្ចចំពោះតតិយជន គឺសំដៅទៅលើសហព័ទ្ធដែលត្រូវទទួលខុសត្រូវក្នុងការបំពេញកាតព្វកិច្ចចំពោះបុគ្គលផ្សេងទៀត ដែលជាម្ចាស់បំណុលដែលទទួលស្គាល់ដោយស្របច្បាប់។[65]

#### ៣.២.៣.១ កាតព្វកិច្ចរួមគ្នា

សហព័ទ្ធទាំងពីរត្រូវមានកាតព្វកិច្ចរួមក្នុងការទទួលខុសត្រូវចំពោះកាតព្វកិច្ច និងភារកិច្ចដទៃទៀតដែលបានព្រមព្រៀងដោយ ប្តីប្រពន្ធជាមួយតតិយជនក្នុងទម្រង់ជាលាយលក្ខណ៍អក្សរក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។[66] ទោះបីជាភាគីសងខាងបានលែងលះគ្នាក៏ដោយ ក៏ភាគីទាំងពីរនៅតែត្រូវទទួលខុសត្រូវចំពោះភាគីទីបី ឬ តតិយជនដែលជាម្ចាស់បំណុលចំពោះបំណុលដែលជំពាក់ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ដែរ។

ឧទាហរណ៍៖ ក្រោយពេលរៀបអាពាហ៍ពិពាហ៍បាន១ឆ្នាំ លោក ដែន និងលោកស្រី យ៉ា បានជំពាក់ប្រាក់គេចំនួន៣០០០ (បីពាន់) ដុល្លាអាមេរិក ដោយមានចុះកិច្ចសន្យាត្រឹមត្រូវ។ ប៉ុន្តែប៉ុន្មានឆ្នាំមកទៀត ពួកគាត់ទាំងពីរបានព្រមព្រៀងក្នុងការលែងលះគ្នាទៅហើយ។ នៅពេលដល់ថ្ងៃត្រូវសងប្រាក់គេ ពួកគាត់នៅតែមានកាតព្វកិច្ចសងរួមគ្នាដដែល ទោះបីជាគាត់បានលែងលះគ្នាដាច់ស្រេចក៏ដោយ។

#### ៣.២.៣.២ កាតព្វកិច្ចដោយឡែក

បំណុលដែលសហព័ទ្ធម្នាក់បានជាប់ជំពាក់មុនពេលរៀបអាពាហ៍ពិពាហ៍ ក្នុងករណីនេះជាបំណុលផ្ទាល់ខ្លួនរបស់សហព័ទ្ធពោលគឺជា បំណុលដាច់ដោយឡែក។ ដូច្នេះភាគីទាំងសងខាងត្រូវតែទទួលខុសត្រូវលើបំណុលនោះរៀងៗខ្លួន។ អាចមានករណីខ្លះទៀត ទោះបីក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ តែបំណុលនោះសហព័ទ្ធតែម្ខាងជាអ្នកជំពាក់បំណុលគេ ហើយសហព័ទ្ធម្ខាងទៀតមិនបានដឹងពីការខ្ចីបំណុលនោះ ឬការខ្ចីនោះធ្វើឡើងព្រោះតែប្រយោជន៍ផ្ទាល់ខ្លួនដូចជា ទិញរបស់របរ លេងល្បែងជាដើម នោះក៏ហៅថាជាបំណុលផ្ទាល់ខ្លួនដែរ មិនពាក់ព័ន្ធដល់ការទទួលខុសត្រូវរបស់សហព័ទ្ធម្ខាងទៀតឡើយ។

ឧទាហរណ៍៖ ហេង និងភា បានរៀបអាពាហ៍ពិពាហ៍នឹងគ្នា។ ម្តាយរបស់ភាចង់ទិញដីមួយកន្លែង គាត់បានមកសុំលុយពីភា ប៉ុន្តែភាមិនហ៊ានប្រាប់ហេងដែលជាប្តីឲ្យដឹងនោះទេ ព្រោះហេងជាអ្នកកាន់កាប់លុយ

[64] មាត្រា៩៦៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[65] មាត្រា៩៧៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[66] មាត្រា៩៧៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

កាក់។ ភាក៏បានទៅខ្ចីលុយពីអ្នកចងការម្នាក់ ដោយមិនឲ្យហេងដឹងទេ។ ក្រោយមកភា និងហេងក៏បានលែងលះគ្នា ដូចនេះបំណុលដែលភាបានទៅជំពាក់ដែលជាលុយទិញដីឲ្យម្ដាយនោះត្រូវចាត់ទុកថាជា បំណុលផ្ទាល់ខ្លួន។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់អស់មួយរយៈពេលកន្លងមកលើប្រធានបទ **"នីតិវិធីនៃការលែងលះដោយការព្រមព្រៀង"** ធ្វើឱ្យយើងខ្ញុំបានយល់ដឹងកាន់តែច្បាស់អំពីសារៈសំខាន់នៃប្រធានបទនេះ។ ជាក់ស្តែង នៅកម្ពុជានាពេលកន្លងមកនេះប្រជាពលរដ្ឋខ្មែរ តែងតែប្រារព្ធពិធីរៀបអាពាហ៍ពិពាហ៍ដែលអាពាហ៍ពិពាហ៍នោះខ្លះកើតឡើងតាមរយៈឪពុកម្តាយជាអ្នករៀបចំផ្សំផ្គុំ និងខ្លះទៀតកើតឡើងតាមឆន្ទៈរវាងបុរស និងនារីដែលជាភាគីនៃអាពាហ៍ពិពាហ៍ផ្ទាល់តែម្តង។ យើងអាចសង្កេតឃើញថា ទោះបីជាមានការរៀបអាពាហ៍ពិពាហ៍ដែលមានលក្ខណៈតាមផ្លូវច្បាប់ ក៏នៅតែអាចមានការទាស់ទែងគ្នារហូតដល់ថ្នាក់លែងលះបានដែរ។

នីតិវិធីនៃការលែងលះនៅកម្ពុជាយើងក៏មិនមានភាពខុសគ្នាខ្លាំងនឹងប្រទេសផ្សេងទៀតដែរ គ្រាន់តែការលែងលះមានភាពងាយស្រួល ខ្លះមានភាពលំបាកដោះស្រាយទៅតាមហេតុផលច្បាស់លាស់ ឬមិនច្បាស់ប៉ុណ្ណោះ រួមទាំងអានុភាពរបស់វាផងដែរ។ ចំពោះការលែងលះគឺ មានកត្តាជាច្រើនដែលអាចឲ្យប្តីប្រពន្ធឈានទៅដល់ការបែកបាក់គ្នា ព្រោះតែមិនមានការចុះសម្រុងក្នុងរង្វង់គ្រួសារឬ បញ្ហាណាមួយក្នុងគ្រួសារ។ ការលែងលះតាមការស្ម័គ្រចិត្ត ឬព្រមព្រៀងនេះ គឺកើតឡើងដោយភាគីទាំងសងខាងសុខចិត្តបែកគ្នាដោយមានហេតុផលជាក់លាក់ណាមួយដូចដែលបានបរិយាយនៅក្នុងអត្ថបទសារណាខាងលើ នោះតុលាការនឹងសម្រេចឲ្យលែងលះគ្នា ដោយមានការត្រួតពិនិត្យលើស្ថានភាពឲ្យបានច្បាស់លាស់មុននឹងសម្រេចសេចក្តី។ការលែងលះដោយការព្រមព្រៀងនេះផងដែរ ត្រូវធ្វើឡើងតាមផ្លូវតុលាការដែលជាមធ្យោបាយមួយដែលគេយកមកប្រើប្រាស់ដើម្បីការរស់នៅ ក្រោយពេលលែងលះតាមផ្លូវតុលាការ នោះមានលក្ខណៈស្របច្បាប់ និងមានសេរីភាពក្នុងការធ្វើអ្វីតាមការសម្រេចចិត្តរបស់បុគ្គលឯកជនម្នាក់ៗ។

ចំពោះផលប្រយោជន៍ដែលកើតចេញពីការលែងលះដោយការព្រមព្រៀងនេះមានដូចជា ទទួលបាននូវសិទ្ធិសេរីភាពក្រោយលែងលះគ្នា ពុំមានជម្លោះរវាងគ្នានឹងគ្នា មិនទទួលរងនូវសម្ពាធធ្ងន់ធ្ងរពីសំណាក់សហព័ទ្ធម្ខាង ទៀតជាដើម។ ផលវិជ្ជមាននៃនីតិវិធីនេះ យើងខ្ញុំគិតថា តុលាការតម្រូវថាភាគីត្រូវតែមានលក្ខខណ្ឌ និងមូលហេតុច្បាស់លាស់ក្នុងការលែងលះទោះបីជាការព្រមព្រៀងក៏ដោយ។ យើងខ្ញុំយល់ស្របនិងគាំទ្រ ឲ្យតុលាការតម្រូវបែបនេះ ពីព្រោះមានមូលហេតុនៃការលែងលះមួយចំនួនដែលភាគីទាំងសងខាងលើកឡើងមក គឺពុំសមហេតុសមផលឡើយ។

# អនុសាសន៍

# អនុសាសន៍

យោងទៅតាមបរិបទសង្គមបច្ចុប្បន្ន ដោយមានការវិវត្តន៍នៃការពង្រឹងនៃការអនុវត្តច្បាប់របស់រាជរដ្ឋាភិបាល ដែលមានក្រសួងយុត្តិធម៌ជាសេនាធិការ ក្នុងការតាក់តែងច្បាប់ និងធ្វើការកែទម្រង់លើវិស័យយុត្តិធម៌នៅប្រទេសកម្ពុជា ដោយបានដាក់ចេញនូវផែនការ យុទ្ធសាស្ត្រ និង ការអនុវត្តយ៉ាងម៉ឺងម៉ាត់ចំពោះមន្ត្រីដែលធ្វើការអនុវត្តច្បាប់ផ្ទុយនឹងបទបញ្ញត្តិដែលមាន ក្នុងគោលបំណងឲ្យការអនុវត្តច្បាប់មានប្រសិទ្ធិភាពខ្ពស់ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ដូចគ្នានេះផងដែរ ស្ថាប័នអយ្យការដែលមានតួនាទី គឺបានអនុវត្តសកម្មភាពបំពេញការងាររបស់ខ្លួនបានយ៉ាងល្អប្រសើរច្រើន ដោយហេតុថា ស្ថាប័នមួយនេះបានអនុវត្តសកម្មភាពយ៉ាងសកម្ម ស្របតាមច្បាប់ដែលមានចែង និង ការប្តេជ្ញាចិត្តធ្វើការបម្រើប្រជាជននៅតាមដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាដល់ការបង្ការកុំឲ្យមានការលែងលះកើនឡើង និង កាត់បន្ថយកុមារកំព្រា ដែលកើតមានឡើងដោយសារឪពុកម្តាយលែងលះគ្នា នៅក្នុងសង្គមនាពេលខាងមុខ ដោយអនុវត្តទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ និង ការអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ នៃព្រះរាជាណាចក្រកម្ពុជា ។

ប៉ុន្តែទន្ទឹមនឹងនេះ ទោះបីជាមានចំណុចល្អប្រសើរយ៉ាងណាក៏ដោយ ក្នុងនោះក៏នៅតែមាននូវភាពខ្វះខាត និង ភាពខ្វះចន្លោះនូវការងារមួយចំនួនផងដែរ ។

ដូចនេះដើម្បីឲ្យនីតិវិធីនៃការលែងលះដោយការព្រមព្រៀង របស់តំណាងអយ្យការមានកាន់តែមានប្រសិទ្ធិភាពខ្ពស់ជាងមុន យើងខ្ញុំសូមការអនុញ្ញាតផ្តល់ជាអនុសាសន៍មួយចំនួន ក្នុងការអនុវត្តការងាររបស់តំណាងអយ្យការ ដូចខាងក្រោមនេះ៖

១. ការសម្រេចមួយដែលមានលក្ខណៈប្រកបដោយវិជ្ជាជីវៈ ដោយធ្វើការងារឈរលើគោលការណ៍ច្បាប់ឲ្យបានតឹងរ៉ឹងបំផុត ស្របតាមមូលហេតុនិងការទាមទាររបស់ភាគី ដើម្បីជាផលប្រយោជន៍ដល់ជនដែលពាក់ព័ន្ធនិងជាប្រយោជន៍ដល់សង្គមជាតិ។

២. ពាក់ព័ន្ធការយល់ដឹងពីច្បាប់ដូចជា ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី គួរមានការផ្សព្វផ្សាយឲ្យបានទូលំទូលាយ និង មានការអប់រំ ទៅដល់ប្រជាពលរដ្ឋ ដើម្បីងាយស្រួលក្នុងការអនុវត្តច្បាប់ និង មិនមានការរំលោភបំពានលើសិទ្ធិនានា មានការការពារដោយច្បាប់។

# ឯកសារយោង

# ឯកសារយោង

## I. ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ កញ្ញា ១៩៩៣
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩
- ច្បាប់ស្តីពី ឯកពន្ធភាព លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

## II. សៀវភៅ និងអត្ថបទផ្សេងៗ

- រៀបរៀងដោយ មេធាវី សុក សំអឿន, សៀវភៅ ច្បាប់ និងអំពើហិង្សាក្នុងគ្រួសារ ឆ្នាំ២០០៦
- រៀបរៀងដោយ លោក គន ឃឿន, សៀវភៅ នីតិគ្រួសារ និងអាពាហ៍ពិពាហ៍ ភាគ២ ឆ្នាំ២០១៣
- រៀបរៀងដោយ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ និងនីតិគ្រួសារ ឆ្នាំ២០១៧

## III. គេហទំព័រ

https://monoroom.info/cultur-lif/lov/svn-rasons-marrid-coupls-today-gt-divorcd/amp/

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១

- រដ្ឋធម្មនុញ្ញ

## ឧបសម្ព័ន្ធទី២

- ក្រមនីតិវិធីរដ្ឋប្បវេណី

## ឧបសម្ព័ន្ធទី៣

- ក្រមរដ្ឋប្បវេណី

## ឧបសម្ព័ន្ធទី៤

- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ
- ច្បាប់ឯកពន្ធភាព

## ឧបសម្ព័ន្ធទី៥

- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

## ឧបសម្ព័ន្ធទី៥

- កិច្ចព្រមព្រៀងលែងលះតាមការព្រមព្រៀង
- ដីកាសម្រេចរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
- រូបមន្តអនុវត្តដីកាសម្រេច

# ឧបសម្ព័ន្ធទី១

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា

# ឧបសម្ព័ន្ធទី២

# ក្រម

# នីតិវិធីរដ្ឋប្បវេណី

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

ខែ កក្កដា ឆ្នាំ ២០០៦

# ព្រះរាជក្រម

នស/រកម/០៧០៦/០២១

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ ក្នុងសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៦ក្នុងសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ក្រុម
# នីតិវិធីរដ្ឋប្បវេណី

នៅតុលាការដែលចៅក្រមនោះស្ថិតនៅក្រោម ត្រូវសម្រេចសេចក្តី ដោយដីកាសម្រេច ។

២-ចៅក្រមមិនអាចចូលរួមក្នុងការសម្រេចសេចក្តីអំពីការដកហូត ឬ បណ្តឹងជិតចិត្ត ចំពោះខ្លួនបានទេ ។ ប៉ុន្តែ ចៅក្រមនោះអាចបញ្ចេញមតិយោបល់អំពីពាក្យសុំនូវការដកហូត ឬ បណ្តឹងជិតចិត្តបាន ។

៣-ពាក្យសុំនូវការដកហូត ឬ បណ្តឹងជិតចិត្ត ត្រូវបានធ្វើឡើងដោយធ្វើសេចក្តីបញ្ជាក់ដំបូងជាលាយល័ក្ខណ៍អក្សរនូវមូលហេតុ ។

៤-ពេលដែលមានពាក្យសុំនូវការដកហូត ឬ បណ្តឹងជិតចិត្ត នីតិវិធីនៃបណ្តឹងត្រូវបានផ្អាករហូតដល់ពេលដែលដីកាសម្រេចអំពីបណ្តឹងនេះ ចូលជាស្ថាពរ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពដែលត្រូវការជាបន្ទាន់ ដូចជាការថែរក្សាការពារភស្តុតាង ជាអាទិ៍ ។

៥-ចំពោះដីកាសម្រេចដែលសម្រេចថា ការដកហូត ឬ បណ្តឹងជិតចិត្តមានមូលហេតុត្រឹមត្រូវនោះ មិនអាចប្តឹងឧបាស្រ័យឡើយ ។

៦-ចំពោះដីកាសម្រេចដែលសម្រេចថា ការដកហូត ឬ បណ្តឹងជិតចិត្តពុំត្រឹមត្រូវ អាចប្តឹងជំទាស់បាន ។

**មាត្រា ៣១.–** ការអនុវត្តដូចគ្នាចំពោះក្រឡាបញ្ជី

បញ្ញត្តិនៃផ្នែកនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះក្រឡាបញ្ជី ។ ក្នុងករណីនេះ ការសម្រេចសេចក្តីអំពីពាក្យសុំនូវការដកហូត ឬ បណ្តឹងជិតចិត្ត ត្រូវធ្វើដោយតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅក្រោម ។

## ជំពូកទី ៣
## ភាគី

### ផ្នែកទី ១
### សមត្ថភាពភាគី និង សមត្ថភាពក្នុងការធ្វើបណ្តឹង

**មាត្រា ៣២.–** សមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្តឹង ការតំណាងដែលច្បាប់បាន

៤-ពាក្យសុំជាលាយល័ក្ខណ៍អក្សរដែលបានកំណត់នៅកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវបញ្ជូនទៅអ្នកផ្សេងដែលធ្វើសហបណ្តឹង និង ភាគីម្ខាងទៀត ។

**មាត្រា ៥០.-** ការជូនដំណឹងអំពីបណ្តឹង

១-ភាគីអាចជូនដំណឹងអំពីបណ្តឹង ទៅតតិយជនដែលអាចចូលរួមអន្តរាគមន៍ក្នុងបណ្តឹងនោះបាន នៅពេលដែលតុលាការកំពុងចាត់ការបណ្តឹង ។

២-ការជូនដំណឹងអំពីបណ្តឹង ត្រូវធ្វើឡើងដោយដាក់លិខិតជាលាយល័ក្ខណ៍អក្សរដែលបញ្ជាក់អំពីមូលហេតុក្នុងការជូនដំណឹង និង អំពីដំណើរការនៃបណ្តឹងនោះ ទៅតុលាការ ។ តុលាការត្រូវបញ្ជូនលិខិតនេះទៅអ្នកដែលត្រូវទទួលដំណឹង និង ភាគីម្ខាងទៀតនៃបណ្តឹង ។

៣-ទោះបីជាអ្នកទទួលដំណឹងអំពីបណ្តឹងនេះមិនបានចូលរួមអន្តរាគមន៍ក៏ដោយ ចំពោះការអនុវត្តបញ្ញត្តិនៃមាត្រា ៤៧ (អានុភាពនៃការសម្រេចសេចក្តីទៅលើអ្នកចូលរួមជួយអន្តរាគមន៍) នៃក្រមនេះ អ្នកទទួលដំណឹងអំពីបណ្តឹងនេះត្រូវបានចាត់ទុកថា បានចូលរួមហើយ នៅពេលអ្នកនោះអាចចូលរួមបាន ។

**មាត្រា ៥១.-** បណ្តឹងដែលមានដើមចោទ និង ចុងចម្លើយ ជាសហចុងចម្លើយ

១-តតិយជនដែលអះអាងថា ចំពោះសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹងរវាងភាគីដទៃ សិទ្ធិទាំងមូល ឬ មួយភាគជាសិទ្ធិរបស់ខ្លួន អាចដាក់ពាក្យបណ្តឹងចំពោះភាគីទាំងសងខាងនៃបណ្តឹងខាងលើនោះ ជាសហចុងចម្លើយ ទៅតុលាការនៃការជំនុំជម្រះលើកទី ១ ដែលបានទទួលពាក្យបណ្តឹងរវាងភាគីដទៃនោះ នៅពេលបណ្តឹងនោះកំពុងនៅក្រោមការចាត់ការរបស់តុលាការណាមួយ ។

២-ក្នុងករណីដែលមានការដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតុលាការនៃការជំនុំជម្រះលើកទី ១ កំពុងចាត់ការបណ្តឹងរវាងភាគីដទៃនោះ តុលាការដែលទទួលពាក្យបណ្តឹងពីតតិយជននោះ អាចបញ្ចូលបណ្តឹងទាំងពីរជាមួយគ្នាបាន ។

ដោយអាណត្តិ លុបចោល ឬ កែតម្រូវភ្លាមៗ ។

## ជំពូកទី ៤
## ប្រាក់ប្រដាប់ក្តី

### ផ្នែកទី ១
### អត្ថន័យ និង ប្រភេទនៃប្រាក់ប្រដាប់ក្តី

**មាត្រា ៥៩.-** ទំហំ និង ចំនួននៃប្រាក់ប្រដាប់ក្តីរដ្ឋប្បវេណីដែលភាគី ឬ បុគ្គលផ្សេង ត្រូវទទួលបន្ទុក

យោងទៅតាមបញ្ញត្តិនៃមាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនេះ ភាគី ឬ បុគ្គលផ្សេង ត្រូវទទួលបន្ទុកក្នុងការបង់ប្រាក់ប្រដាប់ក្តីតុលាការដែលបានកំណត់នៅក្នុងមាត្រា ៦១ (ពន្ធដាក់ពាក្យសុំ) និង មាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ) និង ប្រាក់ប្រដាប់ក្តីភាគីដែលបានកំណត់នៅក្នុងមាត្រា ៦៣ (ប្រាក់ប្រដាប់ក្តីភាគី) នៃក្រមនេះ ។

**មាត្រា ៦០.-** ការគណនាតម្លៃកម្មវត្ថុនៃបណ្តឹង ការគណនាតម្លៃក្នុងករណីបណ្តឹងទាមទារច្រើនចំណុច

១-តម្លៃកម្មវត្ថុនៃបណ្តឹងត្រូវបានគណនា ដោយផ្អែកលើមូលដ្ឋាននៃផលប្រយោជន៍ដែលបានទាមទារក្នុងបណ្តឹងនោះ ។ ក្នុងករណីដែលការទាមទារច្រើនចំណុចក្នុងបណ្តឹងតែមួយ តម្លៃសរុបនៃការទាមទារទាំងនោះ ត្រូវបានចាត់ទុកជាតម្លៃកម្មវត្ថុនៃបណ្តឹង ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះការទាមទារនីមួយៗ ក្នុងករណីដែលផលប្រយោជន៍ដែលបានទាមទារ មានលក្ខណៈដូចគ្នាចំពោះការទាមទារនីមួយៗនោះ ។

២-ក្នុងករណីដែលការទាមទារលើផល សំណងនៃការខូចខាត ប្រាក់ធានាសងក្នុងករណីបំពានកិច្ចសន្យា ឬ សោហ៊ុយ គឺជាកម្មវត្ថុបន្ទាប់បន្សំនៃបណ្តឹង នោះតម្លៃទាំងនោះមិនត្រូវបូកសរុបលើការគណនាតម្លៃកម្មវត្ថុនៃបណ្តឹងឡើយ ។

៣-ក្នុងករណីដែលមានការពិបាកក្នុងការគណនាតម្លៃដែលបានកំណត់ក្នុងកថា-

ខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវកំណត់តម្លៃនោះ ដោយឆន្ទានុសិទ្ធិសមហេតុផល ។ ក្នុងករណីដែលតម្លៃនោះមិនអាចគណនាបានទេ នោះត្រូវចាត់ទុកថា មានចំនួន ៥.៥០០.០០០ (ប្រាំលានប្រាំសែន) រៀល ។

**មាត្រា ៦១.-** ពន្ធដាក់ពាក្យសុំ

១-ពេលដែលដាក់ពាក្យបណ្ដឹង ត្រូវបង់ពន្ធដែលមានចំនួនប្រាក់ដោយគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្ដឹង ដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ ទៅតុលាការ :

ក-ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្ដឹងដល់ ១០.០០០.០០០ (ដប់លាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ១.០០០ (មួយពាន់) រៀល ។

ខ-ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្ដឹងដែលលើស ១០.០០០.០០០ (ដប់លាន) រៀលដល់ ១០០.០០០.០០០ (មួយរយលាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ៧០០ (ប្រាំពីររយ) រៀល ។

គ-ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្ដឹងដែលលើស ១០០.០០០.០០០ (មួយរយលាន) រៀលដល់ ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ៣០០ (បីរយ) រៀល ។

ឃ-ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្ដឹងដែលលើស ១.០០០.០០០.០០០(មួយពាន់លាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ១០០ (មួយរយ) រៀល ។

២-តម្លៃកម្មវត្ថុនៃបណ្ដឹង ដែលជាមូលដ្ឋានដើម្បីធ្វើការគណនាពន្ធដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគណនាតាមបញ្ញត្តិនៃមាត្រា ៦០ (ការគណនាតម្លៃកម្មវត្ថុនៃបណ្ដឹង ការគណនាតម្លៃក្នុងករណីបណ្ដឹងទាមទារច្រើនចំណុច) នៃក្រមនេះ ។

៣-ចំពោះការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ត្រូវបង់ពន្ធ ១,៥ ដង (មួយក្បៀសប្រាំដង) នៃពន្ធដែលបានគណនាតាមកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ រីឯចំពោះការដាក់ពាក្យបណ្ដឹងសាទុក្ខវិញ ត្រូវបង់ពន្ធ ២ ដង (ពីរដង) នៃពន្ធដែលបានគណនាតាមកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ទៅតុលាការ ។

៤-ចំពោះការដាក់ពាក្យបណ្ដឹងជំនុំជម្រះសាជាថ្មី ត្រូវបង់ ១០.០០០ (មួយម៉ឺន) រៀល ទៅតុលាការ ។

៥-ចំពោះការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ត្រូវបង់ពន្ធដែលមានចំនួន ១ ភាគ ២ (មួយភាគពីរ) នៃចំនួនប្រាក់ដោយគណនាតាមកថាខណ្ឌទី ១ ខាងលើនេះ ទៅតាមតម្លៃកម្មវត្ថុនៃការទាមទារ ។ បើចាត់ទុកថា មានការដាក់ពាក្យបណ្ដឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣២៧ (អានុភាពនៃពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន) ឬ មាត្រា ៣៣១ (ការផ្ទេរនីតិវិធីដាស់តឿនទៅនីតិវិធីនៃបណ្ដឹង ដោយពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន) នៃក្រមនេះ អ្នកដែលបានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ត្រូវបង់ពន្ធចំនួនប្រាក់ដែលគណនា ដោយដកចំនួនពន្ធដែលខ្លួនបានបង់ចំពោះការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ពីចំនួនពន្ធដែលបានគណនាតាមកថាខណ្ឌទី ១ ខាងលើនេះ ។

៦-ចំពោះករណីដាក់ពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្ដី ក្រៅពីការកំណត់នៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ និង បញ្ញត្តិពីកថាខណ្ឌទី ៣ ទៅទី ៥ ត្រូវបង់ ៥.០០០ (ប្រាំពាន់) រៀលទៅតុលាការ ។

៧-ការបង់ពន្ធត្រូវធ្វើដោយការបង់ជាប្រាក់នៅកន្លែងទទួលពាក្យនៃតុលាការ ។ ពាក្យសុំដែលមិនបានបង់ពន្ធនៅពេលដាក់ទេ ត្រូវចាត់ទុកថាជាពាក្យសុំមិនស្របច្បាប់ ។

៨-ក្នុងករណីដែលបានរៀបរាប់ខាងក្រោមនេះ យោលទៅតាមពាក្យសុំរបស់អ្នកដែលបានបង់ តុលាការនឹងត្រូវសងនូវពន្ធដែលកំណត់ដោយចំណុចខាងក្រោមនេះ :

ក-ករណីដែលបង់ពន្ធលើស : សងពន្ធដែលបានបង់លើសទៅវិញ ។

ខ-ករណីដែលការផ្សះផ្សាបានលទ្ធផលមុនពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ករណីដែលដកពាក្យបណ្ដឹងមុនពេលចប់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង និង ករណីដែលសេចក្ដីសម្រេចលើកចោលពាក្យបណ្ដឹងដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ចូលជាស្ថាពរ : សងពាក់កណ្ដាលនៃពន្ធដែលបានបង់ហើយទៅវិញ ។

**មាត្រា ៦២.-** ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

១-ភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្ដី ត្រូវបង់ប្រាក់ប្រដាប់ក្ដីខាងក្រោមនេះ ទៅ

តាមចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ :

ក-ចំនួនទឹកប្រាក់ចាំបាច់ដើម្បីឱ្យតុលាការធ្វើការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ ឬ សកម្មភាពផ្សេងទៀត តាមនីតិវិធីក្នុងបណ្តឹងរដ្ឋប្បវេណី ។

ខ-ចំនួនទឹកប្រាក់ស្មើនឹងសោហ៊ុយធ្វើដំណើរ និង សោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និង ក្រឡាបញ្ជី ក្នុងករណីដែលត្រូវធ្វើការពិនិត្យភស្តុតាង ការស្រាវ-ជ្រាវអង្គហេតុ ឬ សកម្មភាពផ្សេងទៀត ដែលប្រព្រឹត្តទៅនៅក្រៅតុលាការ ។

២-ភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្តី ដែលត្រូវបង់ប្រាក់ប្រដាប់ក្តីដូចបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះប្រាក់ប្រដាប់ក្តីសម្រាប់សកម្មភាពដែលធ្វើឡើងដោយពាក្យសុំ គឺអ្នកដាក់ពាក្យសុំ រីឯចំពោះប្រាក់ប្រដាប់ក្តីសម្រាប់សកម្មភាពដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ គឺអ្នកដែលតុលាការបានកំណត់ឱ្យបង់ ។

៣-ចំពោះសកម្មភាពដែលត្រូវបង់ប្រាក់ប្រដាប់ក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវបង្គាប់ឱ្យភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្តី បង់ចំនួននោះជាមុន ។

៤-ក្នុងករណីដែលតុលាការបានបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីជាមុន តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ តែសាមីខ្លួនមិនបានបង់ជាមុនទេនោះ តុលាការអាចមិនធ្វើនូវសកម្មភាពដែលចាំបាច់ត្រូវមានប្រាក់ប្រដាប់ក្តីនោះបាន ។

៥-ចំពោះប្រាក់ប្រដាប់ក្តីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ដែលមិនបានបង់ជាមុនទេ តុលាការអាចប្រមូលពីអ្នកដែលត្រូវទទួលបន្ទុកលើការបង់ប្រាក់ប្រដាប់ក្តីនោះបាន ដោយអាស្រ័យលើដីកាសម្រេចរបស់តុលាការ តាមបញ្ញត្តិនៃមាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនេះ ។

**មាត្រា ៦៣.-** ប្រាក់ប្រដាប់ក្តីភាគី

ក្រៅពីការកំណត់នៅក្នុងមាត្រា ៦១ (ពន្ធដាក់ពាក្យសុំ) និង មាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ) ខាងលើនេះ ចំនួនទឹកប្រាក់ដែលតុលាការកំណត់ថាសមរម្យដោយគិតពិចារណានូវលក្ខណៈនៃរឿងក្តី ឬ លទ្ធភាពទ្រព្យធនរបស់ភាគី ជាអាទិ៍ ក្នុងចំណោមការកំណត់ក្នុងចំណុចខាងក្រោមនេះ ក៏ត្រូវចាត់ទុកថាជាប្រាក់ប្រដាប់ក្តីដែរ :

ក-ថ្លៃធ្វើលិខិត ដូចជា លិខិតពាក្យបណ្តឹង លិខិតពាក្យសុំផ្សេងទៀត ឬ ឯក-

សារផ្សេងៗ ដូចជា ឯកសារត្រៀម ជាអាទិ៍ និង ថ្ងៃដាក់ឯកសារនោះទៅតុលាការ ។

ខ-សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និង សោហ៊ុយស្នាក់នៅសម្រាប់ភាគីនិងអ្នកតំណាង ដើម្បីបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់ ។

គ-សោហ៊ុយផ្សេងទៀត ដែលតុលាការទទួលស្គាល់ថាជាសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តនូវនីតិវិធីបណ្តឹង ។

## ផ្នែកទី ២
## បន្ទុកនៃប្រាក់ប្រដាប់ក្តី

**មាត្រា ៦៤.-** ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ

១-ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី ។ ក្នុងករណីដែលបានចាញ់ក្តីតែមួយភាគទេ តុលាការត្រូវសម្រេចនូវបន្ទុកដែលភាគីម្នាក់ៗត្រូវទទួល ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

២-ទោះបីមានកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏តុលាការអាចសម្រេចតាមកាលៈទេសៈ ឱ្យភាគីឈ្នះក្តីទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីទាំងអស់ ឬ មួយភាគបាន ក្នុងករណីដែលភាគីឈ្នះក្តីនោះបានប្រព្រឹត្តសកម្មភាពបណ្តឹងណាមួយ ដែលមិនចាំបាច់ក្នុងការតទល់ ឬ ការការពារខ្លួន ឬ បានធ្វើនីតិវិធីនៃបណ្តឹងឱ្យមានការយឺតយ៉ាវ ។

៣-អ្នកដែលធ្វើសហបណ្តឹងត្រូវទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីស្មើភាគគ្នា ។ ប៉ុន្តែតុលាការអាចសម្រេចតាមកាលៈទេសៈ ឱ្យភាគីដែលធ្វើសហបណ្តឹងទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ដោយសាមគ្គីភាពបាន ឬ អាចសម្រេចឱ្យភាគីណាមួយដែលបានប្រព្រឹត្តសកម្មភាពបណ្តឹងណាដែលមិនចាំបាច់ក្នុងការតទល់ ឬ ការការពារខ្លួន ទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីច្រើនជាងភាគីដែលធ្វើសហបណ្តឹងផ្សេងទៀតបាន ។

៤-ក្នុងករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកតំណាងដោយអាណត្តិ ឬ ក្រឡាបញ្ជី បានធ្វើឱ្យចំនួនទឹកប្រាក់ប្រដាប់ក្តីដែលគ្មានប្រយោជន៍កើតឡើង ដោយចេតនា ឬ ដោយមានកំហុសធ្ងន់ធ្ងររបស់ខ្លួន តុលាការដែលបានទទួលពាក្យបណ្តឹង អាចបង្គាប់ឱ្យអ្នកនោះសងនូវចំនួននៃប្រាក់ប្រដាប់ក្តីនោះវិញបាន ដោយដីកាសម្រេច តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

៥-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៦៥.-** ការសម្រេចសេចក្ដីលើបន្ទុកនៃការបង់ប្រាក់ប្រដាប់ក្ដី

១-ក្នុងការសម្រេចសេចក្ដីដើម្បីបញ្ចប់រឿងក្ដី តុលាការត្រូវធ្វើការសម្រេចសេចក្ដីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដីទាំងអស់ នៅថ្នាក់នៃការជម្រះក្ដីនោះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

២-ក្នុងករណីដែលតុលាការជាន់ខ្ពស់បានផ្លាស់ប្ដូរសេចក្ដីសម្រេចអង្គសេចក្ដី តុលាការត្រូវធ្វើការសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដីទាំងអស់ឡើងវិញ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលតុលាការដែលទទួលបណ្ដឹងដែលត្រូវបានបញ្ជូនត្រឡប់មកវិញ ឬ ត្រូវបានផ្ទេរ សម្រេចសេចក្ដីដើម្បីបញ្ចប់រឿងក្ដីនោះ ។

៣-ក្នុងករណីដែលរឿងក្ដីនោះបានចប់ដោយមិនធ្វើទៅតាមការសម្រេចសេចក្ដីទេនោះ តុលាការនៃការជំនុំជម្រះលើកទី ១ ត្រូវបង្គាប់ឱ្យទទួលបន្ទុកក្នុងការបង់ប្រាក់ប្រដាប់ក្ដីនោះ តាមពាក្យសុំ ដោយដីកាសម្រេច ។ ប៉ុន្ដែ ចំពោះបណ្ដឹងដែលបានផ្សះផ្សាគ្នាហើយនោះ ប្រាក់ប្រដាប់ក្ដីត្រូវបានបង់ទៅតាមការព្រមព្រៀងគ្នា ហើយប្រសិនបើគ្មានការព្រមព្រៀងគ្នាទេ ភាគីនីមួយៗត្រូវទទួលបន្ទុកក្នុងការបង់រៀងៗខ្លួន ។

**មាត្រា ៦៦.-** នីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្ដី

១-ចំនួនប្រាក់ប្រដាប់ក្ដីដែលត្រូវទទួលបន្ទុកបង់ ត្រូវកំណត់ដោយក្រឡាបញ្ជីរបស់តុលាការនៃការជំនុំជម្រះលើកទី ១ តាមពាក្យសុំ នៅក្រោយពេលដែលសេចក្ដីសម្រេចអំពីបន្ទុកនោះបានបង្កើតអានុភាពនៃការអនុវត្ត ។

២-ចំពោះករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគូភាគីទាំងសងខាងទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដី ប្រាក់ដែលភាគីនីមួយៗត្រូវទទួលបន្ទុកបង់នោះ ត្រូវបានចាត់ទុកថា បានធ្វើការទូទាត់ជាមួយនឹងគ្នា ចំពោះចំនួនទឹកប្រាក់ដែលត្រូវគ្នារួចហើយ ។

៣-ការចាត់ចែងលើពាក្យសុំដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ នឹងមានអានុភាព បន្ទាប់ពីបានជូនដំណឹង តាមរបៀបដែលអាចចាត់ទុកថាសមរម្យ ។

៤-ការធ្វើបណ្ដឹងតវ៉ាចំពោះការចាត់ចែងដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) សប្ដាហ៍ ក្រោយពីបានទទួលដំណឹងនោះ ។

ការទាមទារតាមផ្លូវតុលាការដែលចាំបាច់សម្រាប់ការផ្អាកអាជ្ញាយុកាល ឬ សម្រាប់ការប្រព្រឹត្តទៅតាមអំឡុងពេលគតិយុត្ត នឹងបង្កើតអានុភាពនៅពេលបានដាក់ពាក្យបណ្ដឹង ឬ ពេលដែលដាក់ទៅតុលាការនូវឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ មាត្រា ៨៤ (ការបន្ថែម ឬ ការផ្លាស់ប្ដូរនូវកម្មវត្ថុនៃបណ្ដឹង) ឬ កថាខណ្ឌទី ២ មាត្រា ៨៤ (ការបន្ថែម ឬ ការផ្លាស់ប្ដូរនូវកម្មវត្ថុនៃបណ្ដឹង) ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងបញ្ញត្តិនៃកថា-ខណ្ឌទី ២ មាត្រា ៨៥ (ការប្ដឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្ដាលទី) នៃក្រមនេះ ។

**មាត្រា ៨៨.–** អនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាអាទិ៍

១-ទោះបីបណ្ដឹងកំពុងត្រូវបានចាត់ការក៏ដោយ ក៏ភាគីនៃបណ្ដឹងមិនត្រូវបានរារាំងក្នុងការធ្វើអនុប្បទាន ឬ ការផ្ទេរវត្ថុដែលជាកម្មវត្ថុនៃវិវាទ ឬ សិទ្ធិឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹងនោះដែរ ។

២-អនុប្បទាន ឬ ការផ្ទេរដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំមានឥទ្ធិពលទៅលើបណ្ដឹងទេ ។ អ្នកដែលបានធ្វើអនុប្បទាន ឬ ផ្ទេរ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក៏នៅតែមានឋានៈជាភាគីនៃបណ្ដឹងដដែល ក្រោយពីបានផ្ទេរ ។

៣-បញ្ញត្តិនៃមាត្រា ៤៨ (ការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្ដឹង) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះករណីដែលអ្នកដែលបានទទួលអនុប្បទាន ឬ ការផ្ទេរដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្លាយជាអ្នកចូលរួមជួយអន្តរាគមន៍ ។

## ជំពូកទី ២
## ការទាញហេតុផលដោយផ្ទាល់មាត់ និង ការរៀបចំ

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៨៩.–** ការដឹកនាំនីតិវិធីនៃបណ្ដឹងដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ

១-ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវដឹកនាំចាត់ចែងនីតិវិធីត្រៀមសម្រាប់ការទាញ

ហេតុផល និង ត្រូវដឹកនាំចាត់ចែងការទាញហេតុផលដោយផ្ទាល់មាត់ ។

២-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់និយាយបាន និង អាចហាមជនដែលមិនស្តាប់បញ្ជារបស់ខ្លួនមិនឱ្យនិយាយបាន ។

**មាត្រា ៩០.-** សិទ្ធិឱ្យបំភ្លឺ ជាអាទិ៍

១-ដើម្បីឱ្យចំណុចនៃអង្គហេតុ និង អង្គច្បាប់ដែលទាក់ទងនឹងបណ្តឹង មានភាពច្បាស់លាស់ តុលាការអាចសាកសួរភាគី ឬ ឱ្យភាគីអះអាង ឬ បញ្ជាក់ភស្តុតាង ចំពោះចំណុចនោះ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់បាន ។

២-ភាគីអាចទាមទារឱ្យតុលាការសួរសំណួរចាំបាច់ទៅភាគីម្ខាងទៀត នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់បាន ។

៣-នៅក្រៅពីកាលបរិច្ឆេទ តុលាការអាចបង្គាប់ឱ្យភាគីត្រៀមខ្លួននឹងរៀបចំការឆ្លើយបំភ្លឺ នៅកាលបរិច្ឆេទបន្ទាប់ ដោយបញ្ជាក់ចំណុចដែលតុលាការយល់ឃើញថា ត្រូវការឱ្យបំភ្លឺជាចាំបាច់ ។

**មាត្រា ៩១.-** បណ្តឹងតវ៉ាចំពោះការដឹកនាំនីតិវិធីបណ្តឹង

ក្នុងករណីដែលភាគីបានធ្វើបណ្តឹងតវ៉ា ចំពោះការដឹកនាំការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់ ឬ ចំពោះការចាត់ចែងរបស់តុលាការ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៩០ (សិទ្ធិឱ្យបំភ្លឺ ជាអាទិ៍) ខាងលើនេះ តុលាការត្រូវសម្រេចសេចក្តី ចំពោះបណ្តឹងតវ៉ានោះ ដោយដីកាសម្រេច ។

**មាត្រា ៩២.-** ករណីយកិច្ចស្រាវជ្រាវរបស់ភាគី

ភាគីត្រូវធ្វើការស្រាវជ្រាវឱ្យបានលំអិតជាមុន នូវទំនាក់ទំនងនៃអង្គហេតុចំពោះសាក្សី និង ភស្តុតាងផ្សេងៗ ដើម្បីធ្វើការអះអាង និង បញ្ជាក់ឱ្យបានគ្រប់គ្រាន់ច្បាស់លាស់ក្នុងបណ្តឹង ។

**មាត្រា ៩៣.-** ពេលដែលត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន

មធ្យោបាយតទល់ ឬ ការពារខ្លួន ត្រូវដាក់ឱ្យតុលាការនៅពេលណាមួយដែលសម-

រម្យ ទៅតាមដំណើរការនៃបណ្តឹង ។

**មាត្រា ៩៤.-** ការលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ

១-ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់ទៅតុលាការយឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ ដោយចេតនា ឬ ដោយកំហុសដ៏ធ្ងន់ធ្ងររបស់ភាគី តុលាការអាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនបាន តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រសិនបើតុលាការយល់ឃើញថា ការដាក់មធ្យោបាយនោះ ធ្វើឱ្យមានការយឺតយ៉ាវក្នុងការបញ្ចប់នីតិវិធីនៃបណ្តឹង ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដែរ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនដែលមានអត្ថន័យមិនច្បាស់លាស់ ក្នុងករណីដែលភាគីមិនបានធ្វើការបំភ្លឺចាំបាច់ ឬ មិនបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកោះហៅឱ្យមកបំភ្លឺទេ ។

**មាត្រា ៩៥.-** អង្គហេតុដែលអាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រម

តុលាការមិនអាចយកអង្គហេតុណា ដែលភាគីណាមួយមិនបានអះអាង មកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ ។

**មាត្រា ៩៦.-** ការចាត់ទុកថាបានសារភាព

១-ក្នុងករណីដែលភាគីមិនបានបង្ហាញច្បាស់លាស់ នូវឆន្ទៈតវ៉ាអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់ទេ ភាគីនោះត្រូវបានចាត់ទុកថា បានសារភាពអំពីអង្គហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតុលាការគិតពិចារណាអំពីដំណើរការ និង ខ្លឹមសារនៃរឿងក្តី ហើយយល់ឃើញថា ភាគីនោះបានតវ៉ាអំពីអង្គហេតុ ។

២-ក្នុងករណីដែលភាគីធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនមិនដឹងអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង ភាគីនោះ ត្រូវបានសន្មតថា បានតវ៉ាអំពីអង្គហេតុនោះ ។

**មាត្រា ៩៧.-** ការសាកល្បងធ្វើការផ្សះផ្សា

តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាល

ណាក៏ដោយ ។

**មាត្រា ៩៨.-** ការបាត់បង់នូវសិទ្ធិប្ដឹងតវ៉ាស្ដីអំពីនីតិវិធីនៃបណ្ដឹង

១-ក្នុងករណីដែលភាគីម្ខាង ឬ តុលាការ បានធ្វើសកម្មភាពបណ្ដឹងណាមួយដែលផ្ទុយពីបញ្ញត្តិអំពីនីតិវិធីនៃបណ្ដឹង ភាគីអាចប្ដឹងតវ៉ាចំពោះសកម្មភាពនោះទៅតុលាការ ហើយអាចអះអាងអំពីមោឃភាពនៃសកម្មភាពនោះបាន ។

២-ក្នុងករណីដែលភាគីដឹង ឬ អាចដឹងអំពីភាពខុសច្បាប់ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ហើយមិនបានធ្វើការប្ដឹងតវ៉ានៅពេលសមរម្យទេ ភាគីនោះត្រូវបាត់បង់សិទ្ធិប្ដឹងតវ៉ានេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមិនអាចបោះបង់សិទ្ធិនេះបាន ។

**មាត្រា ៩៩.-** ការបំបែក និង ការរួមបញ្ចូលរឿងក្ដី

១-តុលាការអាចបង្គាប់ឱ្យបំបែក ឬ បញ្ចូលរឿងក្ដី ដោយដីកាសម្រេច ឬ អាចលុបចោលដីកាសម្រេចនោះបាន ។

២-ក្នុងករណីតុលាការ បានបង្គាប់ឱ្យបញ្ចូលរឿងក្ដីដែលមានភាគីខុសគ្នា នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលភាគីដែលមិនមានឱកាសសាកសួរសាក្សី ដោយសារសាក្សីនោះត្រូវបានសាកសួររួចហើយមុនពេលបញ្ចូលរឿងក្ដី បានដាក់ពាក្យសុំសាកសួរសាក្សីនោះ តុលាការត្រូវសាកសួរសាក្សីនោះ ។

**មាត្រា ១០០.-** ការចូលរួមរបស់អ្នកបកប្រែ ជាអាទិ៍

១-ប្រសិនបើជនដែលទាក់ទងនឹងនីតិវិធីរដ្ឋប្បវេណី មិនអាចយល់ភាសាខ្មែរ ឬ ថ្លង់ ឬ គ តុលាការត្រូវឱ្យមានអ្នកបកប្រែដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ចូលរួមជាមួយនឹងជននោះ ។ ប៉ុន្តែ តុលាការអាចសួរជនដែលថ្លង់ ជាអក្សរ ឬ ឱ្យជនដែលគ ធ្វើសេចក្ដីថ្លែងការណ៍ ជាអក្សរ បាន ។

២-បញ្ញត្តិស្ដីពីអ្នកធ្វើកោសលវិច័យនៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកបកប្រែ លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនោះ ។

## ផ្នែកទី ២
## ឯកសារត្រៀម

**មាត្រា ១០១.–** ឯកសារត្រៀម

១-នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀមបាន ។

២-នៅក្នុងឯកសារត្រៀម ត្រូវមានសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួន និងសេចក្ដីថ្លែងការណ៍ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនរបស់ភាគីម្ខាងទៀត ។

៣-នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ត្រូវមានសរសេរអំពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្ដឹង និង ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង និង អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង ជាអាទិ៍ ។

**មាត្រា ១០២.–** ពេលវេលាដែលត្រូវដាក់ឯកសារត្រៀម ជាអាទិ៍

តុលាការអាចកំណត់អំឡុងពេលដែលត្រូវដាក់ឯកសារត្រៀមលើកដំបូងរបស់ចុងចម្លើយ ឬ ឯកសារត្រៀមដែលមានសរសេរអំពីការអះអាងចំពោះចំណុចជាក់លាក់ណាមួយ ឬ ត្រូវធ្វើការស្នើសុំឱ្យពិនិត្យភស្តុតាងដែលទាក់ទងនឹងចំណុចជាក់លាក់ណាមួយ ។

## ផ្នែកទី ៣
## នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

**មាត្រា ១០៣.–** គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្ដីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្ដីដែលគូភាគីយល់មិនស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្ដីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្ដីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់ ។

**មាត្រា ១០៤.–** ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន លើកលែងតែយល់ឃើញថាមិនសមរម្យ ។

**មាត្រា ១០៥.–** កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

១-នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចចូលរួមបាន ។

២-កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ ។ ប៉ុន្តែ តុលាការអាចអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យចូលស្តាប់ជាអ្នកសង្កេតការណ៍បាន ។

**មាត្រា ១០៦.–** សកម្មភាពនៃបណ្តឹង ជាអាទិ៍ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំឱ្យពិនិត្យភស្តុតាង ឬ ដីកាសម្រេចផ្សេងទៀតដែលអាចសម្រេចបាន ក្រៅពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និង អាចពិនិត្យភស្តុតាងជាឯកសារ ដោយមានកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី និង ភស្តុតាង ។

**មាត្រា ១០៧.–** ការបញ្ជាក់អំពីអង្គហេតុដែលនឹងត្រូវបំភ្លឺ ជាអាទិ៍

នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់ការរៀបចំចំណុចវិវាទនៃរឿងក្តី និង ភស្តុតាងហើយ នោះតុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីនូវអង្គហេតុដែលនឹងត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅពេលក្រោយ ។

**មាត្រា ១០៨.–** អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីបានទៀតទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមធ្យោបាយនោះ ទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬ ករណីដែលការដាក់មធ្យោបាយថ្មីនោះ មិនធ្វើឱ្យមានការយឺត

យ៉ាងដល់នីតិវិធីនៃបណ្ដឹង ឬ ករណីដែលភាគីបានធ្វើសេចក្ដីបញ្ជាក់ដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះ មុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយគ្មានកំហុសធ្ងន់ធ្ងរឡើយ ។

**មាត្រា ១០៩.–** កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅគ្រប់កាលបរិច្ឆេទនីមួយៗ ។

**មាត្រា ១១០.–** ចំណុចជារូបមន្តនៃកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

១-នៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះ :

ក-សញ្ញាណរឿងក្ដី ។

ខ-ឈ្មោះចៅក្រម និង ក្រឡាបញ្ជី ។

គ-ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និង អ្នកបកប្រែដែលបានបង្ហាញខ្លួន ។

ឃ-ពេលវេលា និង ទីកន្លែង ។

២-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និង ក្រឡាបញ្ជី ត្រូវចុះហត្ថលេខាលើកំណត់ហេតុដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១១១.–** ចំណុចសារធាតុនៃកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវសេចក្ដីសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ :

ក-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង ចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារនោះ ។

ខ-ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និង ការស្នើសុំឱ្យពិនិត្យភស្ដុតាង ។

គ-ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ភាគី ចំពោះអង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត និង ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះភាពត្រឹមត្រូវ

នៃឯកសារ ។

ឃ-ការដកពាក្យបណ្ដឹង ការផ្សះផ្សា ការលះបង់ការទាមទារ និង ការទទួលស្គាល់ការទាមទារ ។

ង-ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និង ចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រា តាមការទាមទាររបស់ភាគី ។

ច-ការសម្រេចសេចក្ដីដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះ ដោយមិនធ្វើជាលាយល័ក្ខណ៍អក្សរ ។

**មាត្រា ១១២.–** ការប្ដឹងតវ៉ាចំពោះសេចក្ដីកត់ត្រានៃកំណត់ហេតុ ស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាអាទិ៍

១-ក្នុងករណីដែលភាគី ឬ អ្នកដទៃទៀតដែលពាក់ព័ន្ធ ប្ដឹងតវ៉ាចំពោះសេចក្ដីកត់ត្រានៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ ត្រូវកត់សេចក្ដីប្ដឹងតវ៉ានេះ នៅក្នុងកំណត់ហេតុនោះ ។

២-ភាពត្រឹមត្រូវក្នុងការអនុវត្តតាមបញ្ញត្តិទាក់ទងនឹងរបៀបធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចបញ្ជាក់បាន ដោយកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែប៉ុណ្ណោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកំណត់ហេតុនេះបានបាត់ ឬ បានវិនាស ។

## ផ្នែកទី ៤
## ការទាញហេតុផលដោយផ្ទាល់មាត់

**មាត្រា ១១៣.–** ការកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួម ។

**មាត្រា ១១៤.–** ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់

១-ដើម្បីចេញសាលក្រមទៅលើបណ្តឹង តុលាការចាំបាច់ត្រូវតែឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់ ។ ប៉ុន្តែ ចំពោះរឿងក្តី ឬ ចំណុចណាដែលត្រូវសម្រេចដោយដីកាសម្រេច តុលាការត្រូវកំណត់ថា ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ មិនត្រូវធ្វើ ។

២-ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដោយអនុលោមទៅតាមវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចសួរភាគីបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

**មាត្រា ១១៥.–** ការទាញហេតុផលដោយផ្ទាល់មាត់

១-ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចមានវត្តមានបាន ។

២-ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើង នៅសាលសវនាការជាសាធារណៈ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាពជាសាធារណៈនេះ បណ្តាលឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ ឬករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

**មាត្រា ១១៦.–** សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផល

១-នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

២-សេចក្តីថ្លែងការណ៍ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងដោយចង្អុលបង្ហាញឱ្យបានច្បាស់លាស់នូវអង្គហេតុដែលនឹងត្រូវបញ្ជាក់ដោយការពិនិត្យភស្តុតាងនៅពេលក្រោយ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ។

៣-នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ភាគីអាចអះអាងបន្ថែមទៀត

អំពីអង្គហេតុ និង ដាក់ភស្តុតាងមកទៀតបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការអះអាងអង្គហេតុ ឬ ការដាក់ភស្តុតាងនោះ ផ្ទុយនឹងមាត្រា ១០៨ (អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) នៃក្រមនេះ ។

៤-ក្រោយពីបានពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់ហើយ បើយល់ឃើញថា ត្រូវការជាចាំបាច់ពិសេស តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាថ្មីម្តងទៀតបាន ដោយដីកាសម្រេច ។

៥-តុលាការអាចអនុញ្ញាតឱ្យភាគីនីមួយៗធ្វើការទាញហេតុផលចុងក្រោយបាន មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

**មាត្រា ១១៧.–** កំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់

១-តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ នៅគ្រប់កាលបរិច្ឆេទនីមួយៗ ។

២-បញ្ញត្តិនៃមាត្រា ១១២ (ការប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៃកំណត់ហេតុ ស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់នេះ ។

**មាត្រា ១១៨.–** ចំណុចជារូបមន្តនៃកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់

១-នៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះ :

ក-សញ្ញាណរឿងក្តី ។

ខ-ឈ្មោះចៅក្រម និង ក្រឡាបញ្ជី ។

គ-ឈ្មោះតំណាងអយ្យការដែលបានចូលរួម ប្រសិនបើមាន ។

ឃ-ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និង អ្នកបកប្រែដែលបានបង្ហាញខ្លួន ។

ង-ពេលវេលា និង ទីកន្លែងនៃការទាញហេតុផលដោយផ្ទាល់មាត់ ។

ច-ហេតុការណ៍ដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ឬ ហេតុការណ៍ និង មូលហេតុ ដែលមិនបានធ្វើជាសាធារណៈក្នុងករណីមិនធ្វើជាសាធារណៈ ។

២-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និង ក្រឡាបញ្ជី ត្រូវចុះហត្ថលេខានៅក្នុងកំណត់-

ហេតុ ដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១១៩.–** ចំណុចសារធាតុនៃកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់

១-នៅក្នុងកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវសេចក្ដីសង្ខេបអំពីការទាញហេតុផលនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ :

ក-ការដកពាក្យបណ្ដឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់ការទាមទារ និង ការសារភាព ។

ខ-សេចក្ដីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និង របស់អ្នកធ្វើកោសលវិច័យ ។

គ-ការធ្វើសម្បថ ឬ មិនធ្វើសម្បថរបស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និង របស់អ្នកធ្វើកោសលវិច័យ និង មូលហេតុដែលមិនបានឱ្យសាក្សី និង អ្នកធ្វើកោសលវិច័យធ្វើសម្បថ ។

ឃ-លទ្ធផលនៃការត្រួតពិនិត្យ ។

ង-ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និង ចំណុចដែលតុលាការអនុញ្ញាត ឱ្យកត់ត្រាតាមការទាមទាររបស់ភាគី ។

ច-ការសម្រេចសេចក្ដីដែលបានធ្វើឡើងដោយមិនបានធ្វើជាលាយល័ក្ខណ៍អក្សរ ។

ឆ-ការប្រកាសសេចក្ដីសម្រេច ។

២-ទោះបីមានបញ្ញត្តិនៅកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក្នុងករណីដែលបណ្ដឹងត្រូវបានបញ្ចប់ដោយមិនតាមការសម្រេចសេចក្ដីទេ សេចក្ដីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និង របស់អ្នកធ្វើកោសលវិច័យ និង លទ្ធផលនៃការត្រួតពិនិត្យ អាចមិនសរសេរក្នុងកំណត់ហេតុបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីទាមទារឱ្យកត់ត្រាក្នុងកំណត់ហេតុ ក្នុងអំឡុងពេល ១ (មួយ) សប្ដាហ៍ គិតចាប់ពីថ្ងៃដែលខ្លួនបានដឹងថាបណ្ដឹងនោះត្រូវបានចប់ ។

# ជំពូកទី ៣
# ភស្តុតាង
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៣.–** គោលការណ៍សម្រេចសេចក្តីដោយភស្តុតាង

១-តុលាការត្រូវទទួលស្គាល់អង្គហេតុដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន ។ ប៉ុន្តែ តុលាការអាចពិចារណាអំពីស្ថានភាពទាំងមូល ដែលបានលេចឡើងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន ។

២-អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលតុ-លាការយល់ឃើញថា មានភាពជាក់ស្តែង តុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុនោះដោយផ្អែកលើភស្តុតាងទេ ។

៣-ភាគីអាចដកសេចក្តីសារភាពបាន ក្នុងករណីដូចខាងក្រោមនេះ :

ក-ភាគីម្ខាងទៀតពុំតវ៉ា ។

ខ-ការសារភាពនោះ ផ្ទុយនឹងការពិត ដោយភាន់ច្រឡំ ។

គ-ការសារភាពនេះបណ្តាលមកពីសកម្មភាពបទល្មើសរបស់អ្នកដទៃ ។

**មាត្រា ១២៤.–** ការពិនិត្យភស្តុតាង

១-ការពិនិត្យភស្តុតាង ត្រូវធ្វើឡើងតាមការស្នើសុំឱ្យពិនិត្យរបស់ភាគី ។

២-ប្រសិនបើតុលាការពុំអាចសម្រេចថា ត្រូវទទួលស្គាល់ ឬ មិនទទួលស្គាល់នូវការអះអាងអំពីអង្គហេតុ ដោយភស្តុតាងដែលគូភាគីបានស្នើសុំឱ្យពិនិត្យ ឬ បើយល់ឃើញថាមានការចាំបាច់ផ្សេងទៀត នោះតុលាការអាចធ្វើការពិនិត្យភស្តុតាង ដោយឆន្ទានុសិទ្ធិបាន ។

**មាត្រា ១២៥.–** ការស្នើសុំឱ្យពិនិត្យភស្តុតាង

១-ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាង ត្រូវតែកំណត់ឱ្យបានជាក់លាក់អំពីអង្គហេតុដែលត្រូវបញ្ជាក់ ។

២-ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាង គប្បីបំភ្លឺឱ្យច្បាស់លាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ និង ទំនាក់ទំនងរវាងអង្គហេតុនោះនិងភស្តុតាង ។

៣-ការស្នើសុំឱ្យពិនិត្យភស្តុតាង ក៏អាចធ្វើមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ មុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បានដែរ ។

៤-ការស្នើសុំឱ្យសាកសួរសាក្សី និង សាមីភាគី បើអាចធ្វើបាន ត្រូវធ្វើជាមួយគ្នាឱ្យស្រេចតែម្តង ។

**មាត្រា ១២៦.–** ការទទួលយកភស្តុតាង

តុលាការត្រូវពិនិត្យភស្តុតាងដែលភាគីបានស្នើសុំឱ្យពិនិត្យ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ចំពោះភស្តុតាងដែលគ្មានទំនាក់ទំនងជាមួយនឹងអង្គហេតុដែលនឹងត្រូវបញ្ជាក់ និង ភស្តុតាងឯទៀតដែលតុលាការយល់ឃើញថាមិនចាំបាច់ឡើយ ។

**មាត្រា ១២៧.–** ការពិនិត្យភស្តុតាងដោយសម្ហូហវិធី

១-តុលាការត្រូវធ្វើឱ្យការពិនិត្យភស្តុតាងអាចប្រព្រឹត្តទៅជាបន្ទាន់ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដំបូង បន្ទាប់ពីបានបញ្ចប់ការរៀបចំចំណុចវិវាទ និង ភស្តុតាងរួចហើយ ។

២-ការសាកសួរទៅលើសាក្សី ឬ សាមីភាគី បើអាចធ្វើបាន ត្រូវតែធ្វើដោយសម្ហូហវិធី ។

៣-ឯកសារដែលបម្រុងនឹងប្រើនៅក្នុងការសាកសួរសាក្សី ជាអាទិ៍ ត្រូវដាក់ជូននៅក្នុងអំឡុងពេលដែលសមរម្យ មុនពេលចាប់ផ្តើមធ្វើការសាកសួរទៅលើសាក្សី ជាអាទិ៍ នោះលើកលែងតែឯកសារដែលនឹងប្រើជាភស្តុតាង ដើម្បីប្រជែងលើភាពជំនឿនៃសេចក្តីថ្លែង-ការណ៍របស់សាក្សី ជាអាទិ៍ ។

**មាត្រា ១២៨.–** សិទ្ធិចូលរួមរបស់ភាគី

១-តុលាការត្រូវធានានូវឱកាសឱ្យមានវត្តមានរបស់ភាគី ដើម្បីចូលរួមក្នុងការពិនិត្យភស្តុតាង ។

២-ការពិនិត្យភស្តុតាង អាចធ្វើទៅបាន ទោះជាក្នុងករណីដែលភាគីមិនបានចូលខ្លួនតាមកាលបរិច្ឆេទក៏ដោយ ។

**មាត្រា ១២៩.–** ការពិនិត្យភស្តុតាងនៅបរទេស

១-ការពិនិត្យភស្តុតាងដែលត្រូវធ្វើនៅបរទេស តុលាការត្រូវប្រគល់កិច្ចការនេះទៅក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះ ឬ ឯកអគ្គរាជទូត ភារធារី ឬ កុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសនោះ ។

២-ការពិនិត្យភស្តុតាងដែលបានធ្វើនៅបរទេស ទោះបីជាក្នុងករណីដែលការពិនិត្យភស្តុតាងនោះខុសច្បាប់របស់ប្រទេសនោះក៏ដោយ ក៏នៅតែមានសុពលភាពដែរ បើការពិនិត្យភស្តុតាងនោះមិនផ្ទុយនឹងក្រមនេះទេ ។

**មាត្រា ១៣០.–** ការប្រគល់កិច្ចការស្រាវជ្រាវ

តុលាការអាចប្រគល់កិច្ចការស្រាវជ្រាវដែលចាំបាច់ ទៅស្ថាប័នក្នុងប្រទេស ឬ ស្ថាប័នបរទេសបាន ។

**មាត្រា ១៣១.–** សេចក្តីបញ្ជាក់ដំបូង

សេចក្តីបញ្ជាក់ដំបូង ត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន ។

## ផ្នែកទី ២
## ការសាកសួរសាក្សី

**មាត្រា ១៣២.–** ករណីយកិច្ចរបស់សាក្សី

១-លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេង តុលាការអាចសាកសួរជនណាមួយជាសាក្សីក៏បាន ។

២-តុលាការអាចបង្គាប់ឱ្យនាំខ្លួនសាក្សីដែលមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ ដោយដីកាសម្រេចបាន ។

៣-ប្រសិនបើសាក្សីមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀលបាន ដោយដីកាសម្រេច ។

៤-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ឬ ទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

# ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមរដ្ឋប្បវេណី

កាលបរិច្ឆេទប្រកាសឱ្យប្រើ

## ០៨ ធ្នូ ២០០៧

ការបោះពុម្ពដែលបានសម្រួលតាមច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

## មីនា ២០២១

# ក្រមរដ្ឋប្បវេណី

# ផ្នែកទី ៣
# ប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ

## កថាភាគទី ១
## ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

**មាត្រា ៩៦៩.–** កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ និង ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

១-ប្ដីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬ ក្រោយអាពាហ៍ពិពាហ៍បាន ។ ប៉ុន្តែ កិច្ចសន្យានេះ មិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្ដីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និង ភាគបម្រុងបានឡើយ ។

២-បើប្ដីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិនោះ ត្រូវអនុលោមតាមបញ្ញត្តិនៃកថាភាគទី ២ (ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់) ។

**មាត្រា ៩៧០.–** ភាពចាំបាច់នៃទម្រង់ជាលាយលក្ខណ៍អក្សរនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ និង លក្ខខណ្ឌតតាំង

១-កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

២-ក្នុងករណីដែលប្ដីប្រពន្ធបានធ្វើកិច្ចសន្យា ផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេ មិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ ។

## កថាភាគទី ២
## ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

**មាត្រា ៩៧១.–** ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

ប្ដីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍

ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និង ស្ថានភាពផ្សេងៗទៀត ។

**មាត្រា ៩៧២.–** ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដែលកំណត់ដូចខាងក្រោមនេះ គឺជាទ្រព្យសម្បត្តិដោយឡែក ដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់ :

ក-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍ ។

ខ-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។

គ-ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់ក្នុងចំណុច ក និង ចំណុច ខ ខាងលើនេះ ។

**មាត្រា ៩៧៣.–** ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ក្នុងចំណុច ខ និង ចំណុច គ នៃមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ខាងលើនេះ ។

**មាត្រា ៩៧៤.–** ការគ្រប់គ្រង និង ការប្រើប្រាស់ទ្រព្យសម្បត្តិ

១-ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរួម ។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន ។

២-សហព័ទ្ធ មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព ។

៣-សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា ។ សហព័ទ្ធម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀត ឱ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និង រក្សាទុកនូវទ្រព្យសម្បត្តិរួមបាន ។

៤-បើការពិភាក្សាអំពីការគ្រប់គ្រង ឬ ប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

មិនបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន ។

**មាត្រា ៩៧៥.–** ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច

ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលកំណត់ខាងក្រោមនេះ :

ក-សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និង សោហ៊ុយដើម្បីការអប់រំ ឬ ការព្យាបាល ថែទាំកូន ជាអាទិ៍ ។

ប្តីប្រពន្ធទាំងសងខាង

ខ-កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែល~~ប្តី ឬ ប្រពន្ធទាំងសងខាង~~ បានព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្តី ឬ ប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរ ពីប្រពន្ធ ឬ ប្តីម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។

គ-សោហ៊ុយដើម្បីគ្រប់គ្រង និង រក្សាទ្រព្យសម្បត្តិរួម ។

**មាត្រា ៩៧៦.–** ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

១-បើគ្មានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនអាចយកទៅលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតបានឡើយ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើក៏ដោយ បើមានស្ថានភាពមិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និង ដើម្បីរក្សាជីវភាពរស់នៅ នោះប្តីប្រពន្ធណាម្ខាង អាចលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀត នូវទ្រព្យសម្បត្តិរួមបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-ក្នុងករណីដែលប្តី ឬ ប្រពន្ធណាម្ខាង បានលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និង គ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រម អាចទាមទារឱ្យលុបចោលនូវការចាត់ចែងនោះ ទៅតុលាការបាន នៅក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីពេលដែលបាន

អចលនវត្ថុ

ដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជា~~អចលនវត្ថុ~~
សម្រាប់ការអាស្រ័យនៅរបស់គ្រួសារ
និង នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាទ្រព្យសម្បត្តិផ្សេង ។

**មាត្រា ៩៧៧.–** ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក

១-ប្តីប្រពន្ធម្ខាងអាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ហើយដែលត្រូវបានប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ បាន ។

២-ក្នុងករណីដែលប្តីប្រពន្ធម្ខាងអាស្រ័យនៅអចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ទោះបីជាសហព័ទ្ធម្ខាងទៀតបានចាត់ចែងអចលនវត្ថុនោះក៏ដោយ ក៏អាចបន្តអាស្រ័យនៅអចលនវត្ថុនោះ បានដែរ ។

## ផ្នែកទី ៤
## ការលែងលះគ្នា

### កថាភាគទី ១
### មូលហេតុនៃការលែងលះគ្នា

**មាត្រា ៩៧៨.–** មូលហេតុនៃការលែងលះគ្នា

១-ប្តី ឬ ប្រពន្ធ អាចដាក់ពាក្យបណ្តឹងលែងលះគ្នាបាន តែក្នុងករណីដែលកំណត់ខាងក្រោមនេះ :

ក-បើបានប្រព្រឹត្តអំពើផិត ទៅលើសហព័ទ្ធ ។

ខ-បើបានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ។

គ-បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ។

ឃ-បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ។

ង-ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយ

គ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន ។

២-ទោះបីជាក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើយល់ឃើញថា ការលែងលះគ្នានោះនឹងបណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬ កូន ក្រលំបាកយ៉ាងខ្លាំង ឬ មានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន តុលាការអាចច្រានចោលការទាមទារលែងលះគ្នា ដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន។

៣-ក្នុងករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងចំណុច ឃ ឬ ចំណុច ង នៃកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថា ការទាមទារនោះផ្ទុយនឹងភាពសុចរិត ដោយជនដែលទាមទារឱ្យលែងលះគ្នានោះ ធ្វេសប្រហែសយ៉ាងខ្លាំង ក្នុងការសហប្រតិបត្តិ និង ជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះ ដោយឆន្ទានុសិទ្ធិបាន ។

**មាត្រា ៩៧៩.-** ការលែងលះដោយការព្រមព្រៀង

ភាគីនៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្តឹងលែងលះ ទៅតុលាការបាន ក្នុងករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា ។ ប៉ុន្តែ តុលាការអាចឱ្យលែងលះគ្នាបាន ក្រោយពីបានយល់ឃើញថា ភាគីសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ។

**មាត្រា ៩៨០.-** ការបែងចែកទ្រព្យសម្បត្តិ

១-ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ។

២-ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិ ដោយផ្អែកតាមចំណុចនីមួយៗ ដូចកំណត់ខាងក្រោមនេះ :

ក-សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែកដែលបានកំណត់នៅក្នុងមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ។

ខ-បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម ។ ប៉ុន្តែ បើមានករណីពិសេស និង មានការ

ទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូន ជាអាទិ៍ ។

៣-គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ ។

**មាត្រា ៩៨១.-** ការលែងលះគ្នា និង នាមត្រកូល

ប្តី ឬ ប្រពន្ធ ដែលបានប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបាន ឬ អាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន ។

## កថាភាគទី ២
## នីតិវិធីនៃការលែងលះគ្នា

**មាត្រា ៩៨២.-** បណ្តឹងនៃការលែងលះគ្នា

១-ពាក្យបណ្តឹងលែងលះគ្នា អាចដាក់ទៅតុលាការដែលមានសមត្ថកិច្ច ដោយយោងតាមបញ្ញត្តិមាត្រា ១០ (សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និង រឿងក្តីអំពីបុត្តភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន ។

២-ភាគីអាចដាក់ពាក្យសុំលែងលះគ្នា ទៅក្រុមប្រឹក្សាឃុំសង្កាត់ ខាងលំនៅឋាន ឬ ទីសំណាក់ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ៣ នៃមាត្រា ១០ (សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និង រឿងក្តីអំពីបុត្តភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន ។ ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំសង្កាត់ អាចធ្វើការបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ ។ បើមិនអាចបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានទេ ត្រូវចាត់ទុកថាមានពាក្យបណ្តឹងលែងលះគ្នា ហើយក្រុមប្រឹក្សា

ឃុំសង្កាត់ ត្រូវបញ្ជូនពាក្យបណ្តឹងនោះ ទៅតុលាការជាបន្ទាន់ ។

**មាត្រា ៩៨៣.–** ការចាត់ចែងរក្សាការពារ

តុលាការដែលទទួលពាក្យបណ្តឹងលែងលះគ្នា ក្នុងករណីចាំបាច់ អាចចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការចាត់ចែងរក្សាការពារ ចំពោះការបំបែកលំនៅ ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ទ្ធ បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ និង សោហ៊ុយចិញ្ចឹមបីបាច់កូន ជាអាទិ៍ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន ។

**មាត្រា ៩៨៤.–** ការសាកល្បងផ្សះផ្សា ដោយតុលាការ

១-ទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំង ចំពោះការលែងលះគ្នាក៏ដោយ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ។

២-បើការផ្សះផ្សាពុំអាចសម្រេចបានទេ តុលាការត្រូវយកបណ្តឹងលែងលះគ្នា មកធ្វើការវិនិច្ឆ័យ ហើយធ្វើការប្រកាសសាលក្រម ។

## ជំពូកទី ៤
## ឪពុកម្តាយ និង កូន

### ផ្នែកទី ១
### បុត្តភាព

#### កថាភាគទី ១
#### បទប្បញ្ញត្តិទូទៅ

**មាត្រា ៩៨៥.–** ករណីយកិច្ចនៃការសុំចុះកំណើត

១-ឪពុក ឬ ម្តាយរបស់កូន ត្រូវសុំចុះកំណើតរបស់កូន នៅសាលាឃុំសង្កាត់នៃលំនៅឋានរបស់ឪពុក ឬ ម្តាយ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពី

២-ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្តាយចិញ្ចឹម មិនអាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះកូនសុំបានឡើយ ។

៣-បើកូនសុំជាអនីតិជន បញ្ញត្តិចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនសុំដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះឪពុកម្តាយចិញ្ចឹម ។

**មាត្រា ១០៣២.–** អានុភាពនៃការកាត់កាល់សុំកូនធម្មតា

១-អានុភាពទាំងឡាយនៃសុំកូនធម្មតា ត្រូវបញ្ចប់ឆ្ពោះទៅអនាគត ដោយការកាត់កាល់ ។

២-ក្រោយការកាត់កាល់ កូនសុំអាចទទួលវិញ នូវនាមត្រកូលមុនសុំកូនក៏បាន ឬអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន ។

**មាត្រា ១០៣៣.–** ការចុះបញ្ជីនៃសុំកូនធម្មតា និង បញ្ជីកំណើត

ប្រសិនបើបានបង្កើតសុំកូនធម្មតា ត្រូវសរសេរការបង្កើតសុំកូនធម្មតា នៅលើរឹមទំព័រនៃបញ្ជីកំណើតដើមរបស់កូនសុំនោះ ។

## ជំពូកទី ៥

## អំណាចមេបា

### ផ្នែកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១០៣៤.–** អត្ថន័យនៃអំណាចមេបា

អ្នកដែលមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ត្រូវបីបាច់រក្សារូបកាយ

របស់កូនដែលជាអនីតិជន និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ។

**មាត្រា ១០៣៥.–** អំណាចមេបាលើកូនសុំ

អ្នកដែលមានអំណាចមេបាលើកូនសុំ គឺឪពុកម្តាយចិញ្ចឹម ។

**មាត្រា ១០៣៦.–** គោលការណ៍នៃការសហការប្រើប្រាស់អំណាចមេបា

ឪពុកម្តាយដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា ។ ប៉ុន្តែ បើឪពុក ឬ ម្តាយណាម្ខាង ពុំអាចប្រើប្រាស់អំណាចមេបាបានទេ ឪពុក ឬ ម្តាយម្ខាងទៀតត្រូវប្រើអំណាចមេបានោះ ។

## ផ្នែកទី ២
## ការសម្រេចអំពីអ្នកមានអំណាចមេបា ក្នុងករណីលែងលះគ្នា និង ការទទួលស្គាល់

**មាត្រា ១០៣៧.–** ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា

១-បើឪពុកម្តាយលែងលះគ្នា ត្រូវកំណត់យកឪពុក ឬ ម្តាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ ។

២-ក្នុងករណីដែលឪពុកម្តាយបានលែងលះគ្នានៅមុនកំណើតរបស់កូន ម្តាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ ។ ប៉ុន្តែ នៅក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយបាន ។

៣-បើការពិភាក្សានៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ ។

**មាត្រា ១០៣៨.–** ទំនាក់ទំនងរវាងការទទួលស្គាល់ និង អំណាចមេបា

១-អ្នកមានអំណាចមេបាលើកូន ដែលម្តាយមិនទាន់បានរៀបអាពាហ៍ពិពាហ៍បានបង្កើត គឺម្តាយ ។

២-ឪពុក អាចប្រើប្រាស់អំណាចមេបា ចំពោះកូនដែលខ្លួនបានទទួលស្គាល់បាន

តែក្នុងករណីដែលការពិភាក្សារបស់ឪពុកម្ដាយ បានកំណត់យកឪពុកនោះ ជាអ្នកមានអំណាចមេបា ។

៣-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សានោះបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា តាមការទាមទាររបស់ឪពុក ឬ ម្ដាយ ។

៤-ក្រោយពេលដែលឪពុកបានទទួលស្គាល់កូនហើយ ប្រសិនបើឪពុកម្ដាយបានរៀបអាពាហ៍ពិពាហ៍ ឪពុកម្ដាយត្រូវអនុវត្តអំណាចមេបា ដោយសហការគ្នា ។

**មាត្រា ១០៣៩.–** ការផ្លាស់ប្ដូរអ្នកដែលមានអំណាចមេបា

នៅក្នុងករណីនៃបញ្ញត្តិមាត្រា ១០៣៧ (ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា) និង មាត្រា ១០៣៨ (ទំនាក់ទំនងរវាងការទទួលស្គាល់ និង អំណាចមេបា) ខាងលើនេះ តុលាការអាចផ្លាស់ប្ដូរអ្នកដែលមានអំណាចមេបា តាមការទាមទាររបស់ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់កូនបាន ប្រសិនបើទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន ។

**មាត្រា ១០៤០.–** សិទ្ធិ និង ករណីយកិច្ចរបស់ឪពុកម្ដាយដែលមិនរស់នៅជាមួយកូន

១-ឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង មានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ។

២-ឪពុកម្ដាយដែលមានបំណងចង់លែងលះគ្នា ត្រូវពិភាក្សា និង កំណត់អំពីរបៀបចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន ។

៣-ឪពុកដែលមិនបានរស់នៅជាមួយកូនដែលបានទទួលស្គាល់ អាចពិភាក្សា និង កំណត់ ជាមួយម្ដាយ អំពីរបៀបចូលជួប ប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនបាន ។

៤-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ

ពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ តុលាការត្រូវកំណត់អំពីរបៀបចូលជួប ប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន តាមការទាមទាររបស់ឪពុក ឬ ម្ដាយ ។

៥-បើទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន តុលាការអាចផ្លាស់ប្ដូររបៀបចូលជួប ប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន តាមការទាមទាររបស់ឪពុក ឬ ម្ដាយ បាន ។

៦-នៅក្នុងការសម្រេចសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ និង ទី ៥ ខាងលើនេះ តុលាការត្រូវកំណត់អំពីការចូលជួប ប្រាស្រ័យទាក់ទង ដោយយកផលប្រយោជន៍របស់កូនជាអាទិភាព និង ត្រូវកំណត់អំពីសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន ដោយគិតពិចារណាទៅលើស្ថានភាពនៃជីវភាព និង ស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្ដាយ ។

៧-ប្រសិនបើឪពុក ឬ ម្ដាយ មិនអាចពិភាក្សា ឬ មិនអាចទាមទារទៅតុលាការបានទេ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់កូន អាចធ្វើការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ និង ទី ៥ ខាងលើនេះបាន ។

**មាត្រា ១០៤១.-** សិទ្ធិទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន

១-ឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបាលើកូន អាចទាមទារឱ្យអ្នកដែលមានអំណាចមេបា រាយការណ៍អំពីស្ថានភាពរបស់កូននោះបាន ។

២-ចំពោះខ្លឹមសារ និង របៀបរបបនៃការរាយការណ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់តាមការពិភាក្សារវាងឪពុកម្ដាយ ។ ប៉ុន្តែ បើការពិភាក្សាពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ តុលាការអាចសម្រេចសេចក្ដីជំនួសការពិភាក្សា តាមការទាមទាររបស់ឪពុក ឬ ម្ដាយ បាន ។

៣-ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន អាចទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូនចំពោះអ្នកមានអំណាចមេបាបាន ។

**មាត្រា ១០៤២.–** ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងទៅនឹងកូន

លើកលែងតែករណីដែលមានភាពចាំបាច់បន្ទាន់ អ្នកដែលមានអំណាចមេបា ត្រូវពិភាក្សាជាមួយឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបា អំពីចំណុចដែលទាក់ទងទៅនឹងកូន ដូចមានកំណត់ខាងក្រោមនេះ ៖

ក-ការអប់រំរបស់កូន ដែលហួសពីកម្រិតនៃកាតព្វកិច្ចអប់រំដែលជាករណីយកិច្ចកំណត់ដោយច្បាប់ ។

ខ-ការផ្លាស់ប្ដូរទីសំណាក់របស់កូន ពី~~ខេត្ត-ក្រុង~~ រាជធានី ខេត្ត មួយ ទៅ~~ខេត្ត-ក្រុង~~ រាជធានី ខេត្ត មួយទៀត ។

គ-វិជ្ជាជីវៈ ឬ អាជីវកម្មរបស់កូន ។

ឃ-សកម្មភាពព្យាបាល ដែលទាក់ទងដល់អាយុជីវិតរបស់កូន ។

ង-ការចាត់ចែងទ្រព្យសម្បត្តិសំខាន់របស់កូន ។

ច-ចំណុចសំខាន់ៗផ្សេងទៀត ដែលទាក់ទងទៅនឹងការគ្រប់គ្រងថែរក្សាកូន និងទ្រព្យសម្បត្តិរបស់កូន ។

## ផ្នែកទី ៣
## សិទ្ធិ និង ករណីយកិច្ចរបស់អ្នកដែលមានអំណាចមេបា

**មាត្រា ១០៤៣.–** ការអប់រំកូន

អ្នកមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ចអប់រំកូន ។

**មាត្រា ១០៤៤.–** ទីសំណាក់របស់កូន

ទីសំណាក់របស់កូន ត្រូវកំណត់នៅទីកន្លែងដែលអ្នកមានអំណាចមេបា បានកំណត់ ។

**មាត្រា ១០៤៥.–** ការដាក់ទណ្ឌកម្មកូន

អ្នកមានអំណាចមេបា អាចដាក់ទណ្ឌកម្មកូន ដោយខ្លួនឯង នៅក្នុងទំហំដែលចាំបាច់បាន ។

**មាត្រា ១០៤៦.–** ការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈ និង អាជីវកម្ម

១-កូន មិនអាចប្រកបវិជ្ជាជីវៈបានឡើយ បើមិនបានទទួលការអនុញ្ញាតពីអ្នកមានអំណាចមេបា ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ មាត្រា ២០ (អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម) នៃក្រមនេះ អ្នកមានអំណាចមេបា អាចលុបចោល ឬ កម្រិតការអនុញ្ញាត ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ នេះបាន ។

**មាត្រា ១០៤៧.–** ការទាមទារឱ្យប្រគល់កូន

១-អ្នកមានអំណាចមេបា អាចទាមទារឱ្យតតិយជន ដែលមិនព្រមប្រគល់កូនដោយផ្ទុយនឹងច្បាប់ ប្រគល់កូនបាន ។

២-អ្នកមានអំណាចមេបា អាចទាមទារឱ្យឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបាប្រគល់កូនបាន ។

## ផ្នែកទី ៤
## ការព្យួរ និង ការដកហូតអំណាចមេបា

**មាត្រា ១០៤៨.–** ការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា

បើឪពុក ឬ ម្ដាយដែលអនុវត្តអំណាចមេបា បានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬ បើបានធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា តុលាការអាចប្រកាសព្យួរ ឬ ការដកហូតអំណាចមេបា តាមការទាមទាររបស់ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន មេឃុំ ឬ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។

**មាត្រា ១០៤៩.–** ការលុបចោលនូវការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា

បើមូលហេតុដែលបានកំណត់ក្នុងមាត្រា ១០៤៨ (ការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា) ខាងលើនេះ បានបញ្ចប់ហើយ តុលាការអាចលុបចោលការប្រកាសការ

ល្បួរ ឬ ការដកហូតសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា តាមការទាមទាររបស់សាមីជនដែលបានទទួលការប្រកាសការល្បួរ ឬ ការដកហូតអំណាចមេបា ឬ ញាតិក្នុង ៤ (បួន) ថ្នាក់ របស់ជននោះបាន ។

**មាត្រា ១០៥០.-** ការលាឈប់ និង បដិទានរបស់អ្នកមានអំណាចមេបា

១-បើមានមូលហេតុដែលពុំអាចជៀសវាងបាន ឪពុក ឬ ម្តាយ ដែលអនុវត្តអំណាចមេបា អាចលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបាបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើមូលហេតុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានបញ្ចប់ហើយ ឪពុក ឬ ម្តាយ ដែលបានលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា អាចទទួលបដិទាននូវអំណាចមេបានោះវិញបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

**មាត្រា ១០៥១.-** ការផ្លាស់ប្តូរអ្នកមានអំណាចមេបា

១-ក្នុងករណីដែលឪពុកម្តាយតែម្ខាង ជាអ្នកមានអំណាចមេបា ហើយកូនបានធ្លាក់ទៅក្នុងស្ថានភាពដែលពុំមានអ្នកមានអំណាចមេបា ដោយសារអ្នកនោះត្រូវបានប្រកាសការល្បួរ ឬ ការដកហូតអំណាចមេបា ឬ បានលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា តុលាការអាចយកឪពុក ឬ ម្តាយ ដែលពុំមានអំណាចមេបា មកធ្វើជាអ្នកមានអំណាចមេបារបស់កូនបាន ។

២-ប្រសិនបើមានការចាំបាច់ ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន អាចទាមទារឱ្យធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

៣-នៅពេលលែងលះគ្នា ប្រសិនបើឪពុក ឬ ម្តាយ ដែលធ្វើជាអ្នកមានអំណាចមេបារបស់កូន តាមការពិភាក្សា បានទទួលមរណភាព ប្រសិនបើកូនពុំមានអ្នកមានអំណាចមេបាទេ ឪពុក ឬ ម្តាយ ដែលពុំបានធ្វើជាអ្នកមានអំណាចមេបា ត្រូវក្លាយជាអ្នកមានអំណាចមេបា ។

**មាត្រា ១០៥២.-** ការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន

១-បើមានស្ថានភាពដែលពុំមានអ្នកមានអំណាចមេបា ចំពោះកូន តាមបញ្ញត្តិនៃមាត្រា ១០៤៨ (ការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា) ឬ កថាខណ្ឌទី ១ នៃមាត្រា ១០៥០ (ការលាឈប់ និង បដិទានរបស់អ្នកមានអំណាចមេបា) ហើយបើពុំបានផ្លាស់ប្ដូរអ្នកមានអំណាចមេបា តាមបញ្ញត្តិនៃមាត្រា ១០៥១ (ការផ្លាស់ប្ដូរអ្នកមានអំណាចមេបា) ខាងលើនេះទេ អាណាព្យាបាលសម្រាប់អនីតិជនចំពោះកូននោះ ត្រូវចាប់ផ្ដើម តាមបញ្ញត្តិនៃមាត្រា ១០៦៧ (មូលហេតុនៃការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន) ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ១០៦៨ (អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និង មូលដ្ឋាននៃការជ្រើសតាំង) ។

## ផ្នែកទី ៥
## សិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន

**មាត្រា ១០៥៣.-** ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង

អ្នកមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និង ក្នុងការតំណាងឱ្យកូននោះ ចំពោះសកម្មភាពដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ បើសកម្មភាពរបស់អ្នកមានអំណាចមេបា បង្កើតកាតព្វកិច្ច ដែលមានកម្មវត្ថុជាសកម្មភាពរបស់កូននោះ អ្នកមានអំណាចមេបា ត្រូវទទួលការយល់ព្រមពីកូននោះ ។

**មាត្រា ១០៥៤.-** សកម្មភាពដែលអ្នកមានអំណាចមេបាតែម្ខាងបានធ្វើ ក្នុងនាមជាអ្នកមានអំណាចមេបាទាំងសងខាង

១-បើឪពុក ឬ ម្ដាយណាម្ខាង ក្នុងចំណោមអ្នកមានអំណាចមេបារួម ធ្វើសកម្ម-

ភាពណាមួយជំនួសកូន ក្នុងនាមជាអ្នកមានអំណាចមេបាទាំងសងខាង ទោះជាសកម្មភាពនោះ ផ្ទុយនឹងឆន្ទៈរបស់ឪពុក ឬ ម្ដាយម្ខាងទៀតក៏ដោយ អានុភាពនៃសកម្មភាពនោះ ពុំត្រូវបានរារាំងឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀត នៃសកម្មភាពនោះ មានបំណងទុច្ចរិត ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលឪពុក ឬ ម្ដាយណាម្ខាង ក្នុងចំណោមអ្នកមានអំណាចមេបារួម បានយល់ព្រមឱ្យកូនធ្វើសកម្មភាពណាមួយ ទោះបីជាសកម្មភាពនោះ ផ្ទុយនឹងឆន្ទៈរបស់ឪពុក ឬ ម្ដាយម្ខាងទៀតក៏ដោយ ។

**មាត្រា ១០៥៥.–** ករណីយកិច្ចប្រុងប្រយ័ត្ន នៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ

អ្នកមានអំណាចមេបា ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

**មាត្រា ១០៥៦.–** ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ

បើកូនបានក្លាយជានីតិជនហើយ អ្នកមានអំណាចមេបា ត្រូវគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ សោហ៊ុយចិញ្ចឹមបីបាច់កូននោះ និង សោហ៊ុយគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ត្រូវចាត់ទុកថាបានទូទាត់ជាមួយនឹងផលចំណូលពីទ្រព្យសម្បត្តិរបស់កូននោះ ។

**មាត្រា ១០៥៧.–** បញ្ញត្តិពិសេស

បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃមាត្រា ១០៥៦ (ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះទ្រព្យសម្បត្តិដែលត្រូវបានផ្ដល់ដោយមិនគិតថ្លៃទៅឱ្យកូន ដោយតតិយជនដែលបានបង្ហាញឆន្ទៈផ្ទុយនឹងវាក្យខណ្ឌទី ២ នៃមាត្រា ១០៥៦ នោះ ។

**មាត្រា ១០៥៨.–** ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្ដល់ទៅឱ្យកូន

១-ប្រសិនបើតតិយជនដែលបានផ្ដល់ទ្រព្យសម្បត្តិឱ្យទៅកូនដោយមិនគិតថ្លៃ បាន

បង្ហាញឆន្ទៈថា មិនឱ្យឪពុកម្ដាយណាម្ខាង ឬ ទាំងសងខាង ដែលអនុវត្តអំណាចមេបា គ្រប់គ្រងទ្រព្យសម្បត្តិនោះទេ ទ្រព្យសម្បត្តិនោះ ពុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុកម្ដាយណាម្ខាង ឬ ទាំងសងខាងឡើយ ។

២-ក្នុងករណីដែលអ្នកមានអំណាចមេបា ពុំបានអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតតិយជនពុំបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះទេ តុលាការអាចជ្រើសតាំងអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ តាមការទាមទាររបស់កូន ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន ឬ តំណាងអយ្យការបាន ។

៣-ទោះបីជាតតិយជនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាដែរ នៅក្នុងករណីដែលសិទ្ធិអំណាចរបស់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ បានរលត់ ឬ មានការចាំបាច់ត្រូវផ្លាស់ប្ដូរអ្នកនោះ តែតតិយជននោះ មិនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិផ្សេងទៀត ។

៤-បញ្ញត្តិចាប់ពីមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) រហូតដល់មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ ។

**មាត្រា ១០៥៩.–** ការអនុវត្តដូចគ្នានៃបញ្ញត្តិស្ដីពីអាណត្តិ

បញ្ញត្តិនៃមាត្រា ៦៥០ (ករណីយកិច្ចសង្គ្រោះបន្ទាន់ របស់អាណត្តិគាហក នៅក្រោយពេលបញ្ចប់អាណត្តិ) និង មាត្រា ៦៥១ (ល័ក្ខខ័ណ្ឌតតាំងនៃការបញ្ចប់អាណត្តិ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកមានអំណាចមេបា ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និង ករណីដែលបានកំណត់នៅក្នុងមាត្រា ១០៥៨ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្ដល់ទៅឱ្យកូន) ខាងលើនេះ ។

**មាត្រា ១០៦០.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ រវាងឪពុកម្ដាយ និង កូន

១-សិទ្ធិលើបំណុលដែលកើតឡើងរវាងអ្នកមានអំណាចមេបា និង កូន ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិ ត្រូវរលត់ដោយអាជ្ញាយុកាល បើពុំបានអនុវត្តសិទ្ធិនោះ ក្នុងអំឡុងពេល ៣ (បី) ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិអំណាចនៃការអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិបានរលត់ ។

២-ក្នុងករណីដែលសិទ្ធិអំណាចក្នុងការអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ បានរលត់នៅក្នុងពេលដែលកូនពុំទាន់ក្លាយជានីតិជន បើកូនពុំមានអ្នកតំណាងដែលច្បាប់បានកំណត់ អំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគណនាអំឡុងពេល ដោយគិតចាប់ពីពេលដែលកូននោះក្លាយជានីតិជន ឬ ពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់ ដែលស្នងបន្តនោះ បានឡើងកាន់តំណែង ។

## ផ្នែកទី ៦
## ការព្យួរ និង ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

**មាត្រា ១០៦១.-** ការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

បើអ្នកមានអំណាចមេបា បានធ្វើឱ្យអន្តរាយដល់ទ្រព្យសម្បត្តិរបស់កូន ដោយសារការគ្រប់គ្រងមិនត្រឹមត្រូវ តុលាការអាចប្រកាសព្យួរ ឬ ដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រង តាមការទាមទាររបស់ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន មេឃុំ ឬ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។

**មាត្រា ១០៦២.-** ការលុបចោលការប្រកាសការព្យួរ និង ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ១០៦១ (ការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ខាងលើនេះ បានបញ្ចប់ហើយ តុលាការ

អាចលុបចោលការប្រកាសការល្បួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ តាមការទាមទាររបស់សាមីជនដែលបានទទួលការប្រកាសការល្បួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ឬ ញាតិក្នុង ៤ (បួន) ថ្នាក់ របស់ជននោះ បាន ។

**មាត្រា ១០៦៣.–** ការលាឈប់ និង បដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ

១-បើមានមូលហេតុពុំអាចជៀសវាងបាន អ្នកមានអំណាចមេបា អាចលាឈប់ពីសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើមូលហេតុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បានបញ្ចប់ហើយ អ្នកមានអំណាចមេបាដែលបានលាឈប់ពីសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ អាចទទួលបដិទាននូវសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិនោះវិញបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

**មាត្រា ១០៦៤.–** ករណីដែលពុំមានអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ

បើពុំមានអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ តាមបញ្ញត្តិនៃមាត្រា ១០៦១ (ការប្រកាសការល្បួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ឬ កថាខណ្ឌទី ១ នៃមាត្រា ១០៦៣ (ការលាឈប់ និង បដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ខាងលើនេះទេ តុលាការត្រូវសម្រេចសេចក្តីជ្រើសតាំងអ្នកតំណាងពិសេស ឱ្យកូន ។

**មាត្រា ១០៦៥.–** ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និង កូនមានភាពផ្ទុយគ្នា

១-ចំពោះសកម្មភាពដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និង កូនមានភាពផ្ទុយគ្នា អ្នកមានអំណាចមេបា ត្រូវទាមទារឱ្យតុលាការជ្រើសតាំងអ្នកតំណាងពិសេស សម្រាប់កូន ។

២-ក្នុងករណីដែលអ្នកមានអំណាចមេបា អនុវត្តអំណាចមេបាចំពោះកូនច្រើននាក់ ចំពោះសកម្មភាពដែលផលប្រយោជន៍របស់កូនម្នាក់នោះ និង កូនផ្សេងទៀត មានភាពផ្ទុយគ្នា អ្នកមានអំណាចមេបា ត្រូវទាមទារឱ្យតុលាការជ្រើសតាំងអ្នកតំណាងពិសេស

សម្រាប់កូនណាម្ខាង ។

## ផ្នែកទី ៧
## ការយកមកអនុវត្តដូចគ្នានៃជំពូកនេះ

**មាត្រា ១០៦៦.–** អ្នកជំនួសអំណាចមេបា

ចំពោះកូនរបស់អនីតិជនដែលមិនទាន់បានរៀបអាពាហ៍ពិពាហ៍ អ្នកមានអំណាចមេបារបស់អនីតិជននោះ ត្រូវអនុវត្តអំណាចមេបាជំនួស ។ ក្នុងករណីនេះ បញ្ញត្តិនៃជំពូកទី ៥ (អំណាចមេបា) នេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះអ្នកដែលអនុវត្តអំណាចមេបាជំនួស ។

## ជំពូកទី ៦
## អាណាព្យាបាល

## ផ្នែកទី ១
## អាណាព្យាបាលសម្រាប់អនីតិជន

## កថាភាគទី ១
## ការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៦៧.–** មូលហេតុនៃការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើគ្មានអ្នកអនុវត្តអំណាចមេបាចំពោះអនីតិជនទេ អាណាព្យាបាលសម្រាប់អនីតិជន ត្រូវចាប់ផ្ដើម ។

## កថាភាគទី ២
## អ្នកអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៦៨.–** អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នក

អាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និង មូល-
ដ្ឋាននៃការជ្រើសតាំង

១-អ្នកដែលអនុវត្តអំណាចមេបាចុងក្រោយបង្អស់ចំពោះអនីតិជន អាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមមតកសាសន៍បាន ។

២-ប្រសិនបើគ្មានអ្នកត្រូវធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះទេ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជន មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជន នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

៣-ដើម្បីជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការត្រូវគិតពិចារណាអំពីស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត និង ស្ថានភាពជីវភាព និង ទ្រព្យសម្បត្តិរបស់អនីតិជន វិជ្ជាជីវៈ និង ប្រវត្តិរូបរបស់អ្នកដែលត្រូវធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អត្ថិភាព ឬ នត្ថិភាព នៃទំនាក់ទំនងទៅនឹងផលប្រយោជន៍ រវាងអ្នកធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជន យោបល់របស់អនីតិជន និង ស្ថានភាពផ្សេងទៀតទាំងស្រុង ។

**មាត្រា ១០៦៩.–** ករណីយកិច្ចជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ១០៥២ (ការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន) នៃក្រមនេះ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មីទៀត ឱ្យបានឆាប់រហ័ស ។

**មាត្រា ១០៧០.–** ចំនួននៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានតែម្នាក់ ។ ប៉ុន្តែ ចំពោះអនីតិជននៅក្រោមអាណាព្យាបាលដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការ

យល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី បើត្រូវចាប់ផ្ដើមអាណាព្យាបាលទូទៅ តាមមាត្រា ២៤ (ការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ អ្នកអាណាព្យាបាលទូទៅម្នាក់អាចត្រូវបានជ្រើសតាំងបាន ក្រៅពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

២-បញ្ញត្តិស្ដីពីអាណាព្យាបាលទូទៅ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះអាណាព្យាបាលទូទៅសម្រាប់អនីតិជន លើកលែងតែមាត្រា ១១២០ (ករណីដែលអ្នកអាណាព្យាបាលទូទៅ មានច្រើននាក់) ។

**មាត្រា ១០៧១.–** ការលាឈប់នៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើមានមូលហេតុត្រឹមត្រូវ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលាឈប់បាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

**មាត្រា ១០៧២.–** ករណីយកិច្ចជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានលាឈប់ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មីទៀត ឱ្យបានឆាប់រហ័ស ។

**មាត្រា ១០៧៣.–** ការបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានធ្វើអំពើពុំត្រឹមត្រូវ ឬ មានហេតុផ្សេងទៀតដែលមិនសមរម្យនឹងភារកិច្ចជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការអាចបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះបាន តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននៅក្រោមអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការ ឬ អាចបញ្ឈប់ដោយឆន្ទានុសិទ្ធិបាន ។

**មាត្រា ១០៧៤.–** បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន

បុគ្គលដែលកំណត់ក្នុងចំណុចខាងក្រោមនេះ ពុំអាចធ្វើជាអ្នកអាណាព្យាបាល

សម្រាប់អនីតិជនបានឡើយ ៖

ក-អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

ខ-អ្នកតំណាងដែលច្បាប់បានកំណត់ និង ហិតូបត្ថម្ភកៈ ព្រមទាំងអ្នកត្រួតពិនិត្យជនទាំងនោះ ដែលធ្លាប់ត្រូវបានតុលាការដកចេញ ។

គ-ជនដែលក្ស័យធន ។

ឃ-ជនដែលគ្មានដំណឹងអំពីទីរស់នៅ ។

## កថាភាគទី ៣
## អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៧៥.-** អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ និង អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង

១-អ្នកមានអំណាចមេបាដែលអាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចកំណត់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមមតកសាសន៍បាន ។

២-ប្រសិនបើទទួលស្គាល់ថាចាំបាច់ នៅក្នុងករណីដែលគ្មានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលត្រូវបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះទេ តុលាការអាចជ្រើសតាំងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់របស់អនីតិជននៅក្រោមអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការ ឬ ដោយឆន្ទានុសិទ្ធិបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលខ្វះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

**មាត្រា ១០៧៦.–** បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

~~សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននៅក្រោមអាណាព្យាបាល~~ ពុំអាចធ្វើជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានឡើយ ។

**មាត្រា ១០៧៧.–** តួនាទីរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន មានតួនាទីដូចកំណត់ខាងក្រោមនេះ :

ក-ត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

ខ-ទាមទារឱ្យតុលាការជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មីទៀត ដោយគ្មានការយឺតយ៉ាវ ក្នុងករណីដែលខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

គ-ធ្វើការចាត់ចែងចាំបាច់ ចំពោះការគ្រប់គ្រងថែរក្សាអនីតិជននៅក្រោមអាណាព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ ក្នុងករណីដែលមានស្ថានភាពបន្ទាន់ ។

ឃ-តំណាងឱ្យអនីតិជននៅក្រោមអាណាព្យាបាល ចំពោះសកម្មភាពដែលផលប្រយោជន៍របស់អនីតិជននៅក្រោមអាណាព្យាបាល និង អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានភាពផ្ទុយគ្នា ។

**មាត្រា ១០៧៨.–** បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា

បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ១០៦៨ (អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និង មូលដ្ឋាននៃការជ្រើសតាំង) មាត្រា ១០៧១ (ការលាឈប់នៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១០៧៣ (ការបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១០៧៤ (បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន) កថាខណ្ឌទី ២ នៃមាត្រា ១០៨៧ (គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១០៨៨ (កម្រៃរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១០៩៣

(ករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១១០០ (ករណីយកិច្ចសង្គ្រោះបន្ទាន់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាអាទិ៍ នៅក្រោយពេលបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន) និង មាត្រា ១១០១ (ល័ក្ខខ័ណ្ឌតតាំងនៃការបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

## កថាភាគទី ៤
## តួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៧៩.–** សិទ្ធិ និង ករណីយកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងអ្នកមានអំណាចមេបា ចំពោះចំណុចដែលបានកំណត់នៅក្នុងផ្នែកទី ៣ (សិទ្ធិ និង ករណីយកិច្ចរបស់អ្នកដែលមានអំណាចមេបា) ជំពូកទី ៥ នៃគន្ថីទី ៧ នេះ ។ ប៉ុន្តែ ដើម្បីផ្លាស់ប្តូរវិធីអប់រំ និង ទីសំណាក់ដែលត្រូវបានកំណត់ដោយអ្នកមានអំណាចមេបា ដាក់ទណ្ឌកម្មលើអនីតិជននៅក្រោមអាណាព្យាបាល អនុញ្ញាតឱ្យប្រកបអាជីវកម្ម លុបចោលការអនុញ្ញាតឱ្យប្រកបអាជីវកម្ម ឬ កម្រិតអាជីវកម្ម បើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។

២-ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវពិភាក្សាជាមួយនឹងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ចំពោះចំណុចដែលបានកំណត់នៅក្នុងមាត្រា ១០៤២ (ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងនឹងកូន) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានភាពចាំបាច់បន្ទាន់ ។

**មាត្រា ១០៨០.-** ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ហើយត្រូវធ្វើជាតំណាងឱ្យអនីតិជននៅក្រោមអាណាព្យាបាល ចំពោះសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់អនីតិជននោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃមាត្រា ១០៥៣ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០៨១.-** ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌ

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវចាប់ផ្តើមស្រាវជ្រាវទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលបានកាន់តំណែង ហើយត្រូវបញ្ចប់ការស្រាវជ្រាវនោះ នៅក្នុងអំឡុងពេល ៣ (បី) ខែ និងត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារបាននៅតុលាការ ។

២-ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ការស្រាវ-ជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះ ពុំមានអានុភាពឡើយ បើគ្មានវត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះទេ ។

**មាត្រា ១០៨២.-** សិទ្ធិអំណាចនៅមុនពេលធ្វើបញ្ជីសារពើភ័ណ្ឌ

រហូតដល់ពេលបញ្ចប់ការធ្វើបញ្ជីសារពើភ័ណ្ឌ អ្នកអាណាព្យាបាលសម្រាប់អនីតិជនមានសិទ្ធិអំណាច ចំពោះតែសកម្មភាពដែលមានភាពចាំបាច់បន្ទាន់ប៉ុណ្ណោះ ។ ប៉ុន្តែសកម្មភាពនេះមិនអាចតតាំងនឹងតតិយជនដែលសុចរិតបានឡើយ ។

**មាត្រា ១០៨៣.–** ការរាយការណ៍អំពីសិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលមានចំពោះអនីតិជននៅក្រោមអាណាព្យាបាល

១-ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន មានសិទ្ធិលើបំណុល ឬ កាតព្វកិច្ច ចំពោះអនីតិជននៅក្រោមអាណាព្យាបាល ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវរាយការណ៍ជូនអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនអំពីសិទ្ធិលើបំណុល ឬ កាតព្វកិច្ចនោះ នៅមុនពេលចាប់ផ្ដើមការស្រាវជ្រាវទ្រព្យសម្បត្តិ ។

២-ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានដឹងថាមានសិទ្ធិលើបំណុលចំពោះអនីតិជននៅក្រោមអាណាព្យាបាល តែបើមិនបានរាយការណ៍ទេ អ្នកអាណាព្យាបាលនោះ ត្រូវបាត់បង់សិទ្ធិលើបំណុលនោះ ។

**មាត្រា ១០៨៤.–** ការយកមកអនុវត្តដូចគ្នា ចំពោះករណីដែលអនីតិជននៅក្រោមអាណាព្យាបាល បានធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិសកល

បញ្ញត្តិនៃមាត្រា ១០៨១ (ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌ) មាត្រា ១០៨២ (សិទ្ធិអំណាចនៅមុនពេលធ្វើបញ្ជីសារពើភ័ណ្ឌ) និង មាត្រា ១០៨៣ (ការរាយការណ៍អំពីសិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលមានចំពោះអនីតិជននៅក្រោមអាណាព្យាបាល) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអនីតិជននៅក្រោមអាណាព្យាបាល បានធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិសកល នៅក្រោយពេលដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានកាន់តំណែង ។

**មាត្រា ១០៨៥.–** ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ

ដើម្បីលក់ ជួល រំលាយភតិសន្យា បង្កើតហ៊ីប៉ូតែក ឬ ធ្វើការចាត់ចែងផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា នូវអចលនវត្ថុដែលប្រើជាលំនៅឋានរបស់អនីតិជន

នៅក្រោមអាណាព្យាបាល ជំនួសអនីតិជននៅក្រោមអាណាព្យាបាល អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវទទួលការអនុញ្ញាតពីតុលាការ ។

**មាត្រា ១០៨៦.-** សកម្មភាពដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជននៅក្រោមអាណាព្យាបាល មានភាពផ្ទុយគ្នា

បញ្ញត្តិនៃមាត្រា ១០៦៥ (ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និង កូន មានភាពផ្ទុយគ្នា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

**មាត្រា ១០៨៧.-** គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវធ្វើគម្រោងចំនួនប្រាក់ដែលត្រូវចំណាយជារៀងរាល់ឆ្នាំ ដើម្បីគ្រប់គ្រងថែរក្សាអនីតិជននៅក្រោមអាណាព្យាបាល និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ នៅជំហានដំបូងនៃពេលដែលបានចាប់ផ្ដើមកាន់តំណែង ។

២-សោហ៊ុយចាំបាច់ ដើម្បីអ្នកអាណាព្យាបាលសម្រាប់អនីតិជនបំពេញតួនាទីអាណាព្យាបាលសម្រាប់អនីតិជន ត្រូវចំណាយចេញពីទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ។

**មាត្រា ១០៨៨.-** កម្រៃរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

តុលាការ អាចផ្ដល់កម្រៃសមរម្យ ពីក្នុងចំណោមទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ឱ្យទៅអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយគិតពិចារណាទៅលើលទ្ធភាពទ្រព្យធនរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជននៅក្រោមអាណាព្យាបាល ព្រមទាំងស្ថានភាពផ្សេងទៀតបាន ។

**មាត្រា ១០៨៩.–** ការត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ តុលាការ អាចទាមទារឱ្យអ្នកអាណាព្យាបាលនោះ រាយការណ៍អំពីតួនាទីរបស់ខ្លួន ឬ ដាក់បញ្ជីសារពើភ័ណ្ឌ ឬ អាចស្រាវជ្រាវអំពីអនីតិជននៅក្រោមអាណាព្យាបាល ឬ ស្ថានភាពទ្រព្យសម្បត្តិរបស់អនីតិជននោះ នៅពេលណាក៏បាន ។

២-តុលាការ អាចបង្គាប់ឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ធ្វើការចាត់ចែងចាំបាច់ ដែលទាក់ទងនឹងការគ្រប់គ្រងថែរក្សាអនីតិជននៅក្រោមអាណាព្យាបាល ឬ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ ឬ ការចាត់ចែងចាំបាច់ផ្សេងទៀតដែលទាក់ទងទៅនឹងអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណា-ព្យាបាលសម្រាប់អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននោះ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជននោះ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការ ឬ ដោយឆន្ទានុសិទ្ធិបាន ។

**មាត្រា ១០៩០.–** ការកម្រិតសិទ្ធិតំណាងដែលច្បាប់បានកំណត់ និង សិទ្ធិយល់ព្រម

ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដើម្បីធ្វើអាជីវ-កម្ម ឬ ធ្វើសកម្មភាពដែលបានកំណត់នៅក្នុងមាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមនេះ ជំនួសអនីតិជននៅក្រោមអាណាព្យាបាល ឬ ដើម្បីយល់ព្រមឱ្យអនីតិជននៅក្រោមអាណាព្យាបាល ប្រកបអាជីវកម្ម ឬ ធ្វើសកម្មភាពនោះ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការទទួលប្រាក់ដើម ។

**មាត្រា ១០៩១.–** អានុភាពនៃការអនុវត្តផ្ទុយនឹងមាត្រា ១០៩០

១-សកម្មភាពដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានធ្វើ ឬ សកម្មភាពដែលបានផ្តល់ការយល់ព្រម ដោយផ្ទុយនឹងបញ្ញត្តិនៃមាត្រា ១០៩០ (ការកម្រិតសិទ្ធិតំណាងដែលច្បាប់បានកំណត់ និង សិទ្ធិយល់ព្រម) ខាងលើនេះ មានតែអនីតិជននៅក្រោមអាណាព្យាបាល ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ ដែលអាចលុបចោល

បាន ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ៣២ (សិទ្ធិដាស់តឿន) នៃក្រមនេះ ត្រូវយកមក អនុវត្តដូចគ្នាផងដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងក្នុងការអនុវត្តបញ្ញត្តិនៃមាត្រា ៣៥៨ (សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពីមាត្រា ៣៦០ (វិធីនៃការ លុបចោល ឬ សច្ចានុមតិ) រហូតដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុប ចោល) នៃក្រមនេះឡើយ ។

**មាត្រា ១០៩២.–** ការទទួលអនុប្បទាននូវទ្រព្យសម្បត្តិ ជាអាទិ៍ ពីអនីតិជននៅក្រោម អាណាព្យាបាល

១-ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានទទួលអនុប្បទាននូវទ្រព្យ សម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ឬ សិទ្ធិរបស់តតិយជនចំពោះអនីតិជន នៅក្រោមអាណាព្យាបាល អនីតិជននៅក្រោមអាណាព្យាបាលនោះ អាចលុបចោលនូវ អនុប្បទាននោះបាន ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ៣២ (សិទ្ធិដាស់តឿន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងនូវការអនុវត្តបញ្ញត្តិនៃមាត្រា ៣៥៨ (សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពីមាត្រា ៣៦០ (វិធីនៃការ លុបចោល ឬ សច្ចានុមតិ) រហូតដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុប ចោល) នៃក្រមនេះឡើយ ។

**មាត្រា ១០៩៣.–** ករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានករណីយកិច្ចបំពេញតួនាទីអាណា-ព្យាបាលសម្រាប់អនីតិជន ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានធ្វើឱ្យមានការខូច ខាតដល់អនីតិជននៅក្រោមអាណាព្យាបាល ដោយធ្វើផ្ទុយនឹងករណីយកិច្ចប្រុងប្រយ័ត្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អនីតិជននៅក្រោមអាណាព្យាបាល អាចទាមទារសំណងនៃការខូចខាតនោះ ពីអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះបាន ។

# ឧបសម្ព័ន្ធទី៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្ដីពី

## - អាពាហ៍ពិពាហ៍ និង គ្រួសារ

## - ឯកពន្ធភាព

www.elibraryofcambodia.org

# ព្រះរាជក្រម

នស/រកម/១០០៦/០២៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ឯកពន្ធភាព ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ឯកពន្ធភាព

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងការពារសេចក្ដីថ្លៃថ្នូរ និងពង្រឹងសុខដុមរមនា សុភមង្គលក្នុងគ្រួសារ និងការគោរពសិទ្ធិគ្នាទៅវិញទៅមករវាងប្ដីនិងប្រពន្ធ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា ២.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវគោរពគោលការណ៍ឯកពន្ធភាពដោយស្ម័គ្រចិត្ត ប្ដីមួយប្រពន្ធមួយ ដោយមានចុះបញ្ជីអាពាហ៍ពិពាហ៍ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ។

## ជំពូកទី ២

## និយមន័យ ពិរុទ្ធភាព និងនីតិវិធី

**មាត្រា ៣.-**

ឯកពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ ដែលបុរសមានប្រពន្ធតែមួយ ឯស្ត្រីមានប្ដីតែមួយ ។ ដែលហៅថាចំណងអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្ដេជ្ញាថារួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន ។

ចំណងអាពាហ៍ពិពាហ៍ត្រូវរលាយក្នុងករណីណាមួយដូចខាងក្រោម :

-សហព័ទ្ធណាមួយស្លាប់ ។

-មានសេចក្ដីសម្រេចរំលាយចំណងអាពាហ៍ពិពាហ៍ជាស្ថាពររបស់តុលាការ ។

-សហព័ទ្ធណាម្នាក់បាត់ខ្លួនហួសពីមួយឆ្នាំដោយគ្មានដំណឹងអ្វីសោះ មិនដឹងថាស្លាប់ ឬរស់ ។

**មាត្រា ៤.-**

ទ្វេពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ដែលបុរសមានប្រពន្ធពីរ ឬស្ត្រីមានប្តីពីរ ។

ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទទ្វេពន្ធភាព បុរស ឬ ស្ត្រីណាដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយនៅឡើយ ហើយទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត ។

អ្នកសមគំនិតត្រូវមានទោសដូចគ្នា ។

**មាត្រា ៥.-**

ត្រូវចាត់ទុកថាសហ្ចន់ បុរស និងស្ត្រីណាដែលជាប់ចំណងជាញាតិលោហិត ឬ ញាតិពន្ធនឹងគ្នា ហើយរួមសេវនកិច្ចជាមួយគ្នា ។

**មាត្រា ៦.-**

ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទសហ្ចន់ :

-បុរស និងស្ត្រីដែលជាប់ចំណងជាញាតិលោហិត ឬ ញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះចំណងនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ឬ ជាសាច់ចិញ្ចឹមក្តី បានរួមសេវនកិច្ចជាមួយគ្នា ។

-បុរស និងស្ត្រីដែលជាប់ចំណងសាខាញាតិនឹងគ្នា ទោះសាខាញាតិនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ចិញ្ចឹមក្តី រួមម្តាយក្តី រួមឪពុកក្តី រួមម្តាយឪពុកក្តី ជាញាតិលោហិតក្តី ឬ ជាញាតិពន្ធក្តី រហូតដល់ថ្នាក់ទី ៣ រាប់ទាំងថ្នាក់នេះ ផងបានរួមសេវនកិច្ចជាមួយគ្នា ។

មិនចាត់ទុកថាមានពិរុទ្ធពីបទសហ្ចន់ទេ ប្រសិនបើសហព័ទ្ធណាម្នាក់ស្លាប់ ហើយសហព័ទ្ធដែលនៅរស់រួមសេវនកិច្ចជាមួយសាខាញាតិពន្ធថ្នាក់ទី ២ ឬ ថ្នាក់ទី ៣ ។

**មាត្រា ៧.-**

ត្រូវចាត់ទុកថាផិត គឺការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន ។

# ច្បាប់

# ស្តីពី

# អាពាហ៍ពិពាហ៍ និងគ្រួសារ

# រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រុមប្រឹក្សារដ្ឋ

លេខ : ៥៦ ក្រ.

# ក្រឹត្យ

# ក្រុមប្រឹក្សារដ្ឋ

# នៃ

# រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជាដែល ប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ក្រ. ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

## សំរេច

ប្រកាសអោយប្រើច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលរដ្ឋសភានៃរដ្ឋកម្ពុជា បានអនុម័តនៅ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៨៩ នាសម័យប្រជុំសាមញ្ញលើកទី ១៧ នីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា : **ហេង សំរិន**

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

រដ្ឋសភា

# ច្បាប់

## ស្តីពី

## អាពាហ៍ពិពាហ៍ និង គ្រួសារ

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.** ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដោយផ្អែកលើមាត្រា ៧ និងមាត្រា ៨ នៃរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា មានគោលដៅ ដាក់បទបញ្ញា និង ការរៀបអាពាហ៍ពិពាហ៍ និងគ្រួសារ ធានាសមភាពរវាងសហព័ទ្ធ ក្នុងអាពាហ៍ពិពាហ៍ និង ក្នុងជីវភាពគ្រួសារ ពង្រឹងការទទួលខុសត្រូវរបស់ឪពុកម្តាយ ក្នុងការចិញ្ចឹមថែរក្សាកូន និង ជំរុញការបណ្តុះបណ្តាលសីលធម៌ និងការអប់រំ ដើម្បីឱ្យទៅជាពលរដ្ឋល្អ មានមនសិការស្នេហាជាតិ ស្រឡាញ់ការងារ មានសម្បជញ្ញៈទទួលខុសត្រូវចំពោះសង្គម ។

**មាត្រា ២.** ហាមឃាត់ដាច់ខាត នូវអាពាហ៍ពិពាហ៍ដែលគូស្រករនៅក្មេងពេក អាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំ អំពើដែលមានឧបសគ្គដល់សេរីភាពនៃអាពាហ៍ពិពាហ៍ ។

## ជំពូកទី ២

## អំពីអាពាហ៍ពិពាហ៍

### ផ្នែកទី ១

### អំពីលក្ខខណ្ឌដែលត្រូវមានដើម្បីរៀបអាពាហ៍ពិពាហ៍

**មាត្រា ៣.** អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និង ស្ត្រីម្នាក់ដែលប្តេជ្ញាថា ខ្លួននិងរួម សមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្ត របស់ខ្លួន ។

អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.** បុរស និង នារី ដែលមានអាយុពេញលក្ខណៈច្បាប់ មានសិទ្ធិពេញលេញក្នុងការសំរេចអាពាហ៍ពិពាហ៍ ។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតបានឡើយ ។

គ្មាននរណាមួយអាចបង្ខំបុគ្គលម្នាក់ឱ្យរៀប ឬ រារាំងមិនឱ្យរៀបអាពាហ៍ពិពាហ៍បានឡើយ បើ អាពាហ៍ពិពាហ៍នោះរៀបតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៥**~ អាចរៀបអាពាហ៍ពិពាហ៍បាន បុរសចាប់ពីអាយុ ២០ឆ្នាំឡើង នារីចាប់ពីអាយុ ១៨ ឆ្នាំឡើង ។

ក្នុងករណីពិសេស បុរសដែលមានអាយុមិនទាន់ដល់ ២០ ឆ្នាំ និង នារីដែលមានអាយុមិនទាន់ដល់ ១៨ ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន ប្រសិនបើនារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុកម្តាយ ឬ អ្នកអាណាព្យាបាល ។

**មាត្រា ៦**~ មិនអាចរៀបអាពាហ៍ពិពាហ៍បាន :

-បុគ្គលមានភេទដូចគ្នា

- បុគ្គលគ្មានពលានុភាពនៃលិង្គ

- បុគ្គលមានជម្ងឺឃ្លង់ របេង មហារីក កាមរោគ ដែលមិនទាន់ព្យាបាលបានជាដាច់

- ជនវិកលចរិត ជនមិនដឹងខុសត្រូវ

- បុគ្គលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ។

**មាត្រា ៧**~ អាពាហ៍ពិពាហ៍ត្រូវហាមឃាត់ រវាងបុគ្គលដែលជាប់ចំណងញាតិលោហិត ឬ ញាតិពន្ធក្នុងខ្សែផ្ទាល់ គ្រប់ថ្នាក់ទោះចំណងនោះមានខាន់ស្លាក្តី ឥតមានខាន់ស្លាក្តី ឬ សាច់ចិញ្ចឹមក្តី ។

**មាត្រា ៨**~ អាពាហ៍ពិពាហ៍ត្រូវហាមឃាត់ រវាងសាខាញាតិ ទោះសាខាញាតិនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី សាច់ចិញ្ចឹមក្តី រួមម្តាយក្តី រួមឪពុកក្តី ជាញាតិលោហិតក្តី ឬ ជាញាតិពន្ធក្តី រហូតដល់ថ្នាក់ទី ៣ រាប់ទាំងថ្នាក់ទី ៣ នេះផង ។

ក្នុងករណីពិសេស ប្រសិនបើសហព័ទ្ធណាមួយស្លាប់ សហព័ទ្ធដែលនៅរស់អាចរៀប អាពាហ៍ពិពាហ៍ ជាមួយ សាខាញាតិពន្ធ ថ្នាក់ទី ២ ឬ ថ្នាក់ទី ៣ បាន ។

**មាត្រា ៩**~ ក្រោយពីអាពាហ៍ពិពាហ៍រលាយដោយមូលហេតុ ប្តីស្លាប់ មោឃភាពនៃអាពាហ៍ពិពាហ៍ ឬ លែងលះគ្នា នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតបាន ប៉ុន្តែត្រូវស្ថិតនៅក្នុងវិធវភាព " ភាពមេម៉ាយ " ចំនួន ៣០០ថ្ងៃ គិតពីថ្ងៃដែលប្តីស្លាប់ ឬ ពីថ្ងៃប្រកាសសាលក្រមដែលសំរេចពីមោឃភាព នៃអាពាហ៍ពិពាហ៍ ឬ ពីថ្ងៃប្រកាសសាលក្រមស្ថាពរនៃការលែងលះ ។ ក្នុងករណីដែលតុលាការប្រជាជនបានចេញដីកាសំរេច ឱ្យប្តីប្រពន្ធនៅបែកគ្នា នោះសាលក្រមនៃការលែងលះត្រូវគិតវិធវភាពតាំងពីថ្ងៃដែលចេញដីកានេះ ។

ប៉ុន្តែ បើនារីរៀបអាពាហ៍ពិពាហ៍មុនផុត រយៈពេល ៣០០ ថ្ងៃ ប្តីដែលរៀបអាពាហ៍ពិពាហ៍ថ្មីនេះ ត្រូវចាត់ទុកជា ឪពុករបស់កូនដែលកើតក្នុងអាពាហ៍ពិពាហ៍ថ្មីនេះ លើកលែងតែមានការជំទាស់ពីប្តី មុន ដោយមានភស្តុតាងច្បាស់លាស់ ។

**មាត្រា ២៨.** តុលាការប្រជាជន ត្រូវចាត់ចែងឱ្យចម្លងសេចក្ដីវិនិច្ឆ័យ នៃសាលក្រមស្ថាពរដែលប្រកាស មោឃភាពអាពាហ៍ពិពាហ៍ ចុះនៅរឹមទំព័រ នៃសំបុត្រអាពាហ៍ពិពាហ៍ដែលត្រូវទុកជាមោឃៈ ។

## ផ្នែកទី ៤
## សិទ្ធិ និង ករណីយកិច្ចរបស់សហព័ន្ធ

**មាត្រា ២៩.** ក្នុងគ្រួសារ ប្ដី ប្រពន្ធ ត្រូវមានភាពស្មើគ្នាលើគ្រប់ទស្សនៈ ។

**មាត្រា ៣០.** ប្ដី ប្រពន្ធ មានករណីយកិច្ចស្រឡាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នា និង ជួយគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាពព្រមទាំងកសាងគ្រួសារមួយ មានសាមគ្គីភាព និង ប្រកបដោយសុភមង្គល ។

**មាត្រា ៣១.** ប្រពន្ធ ប្ដី មានសិទ្ធិជ្រើសដោយសេរីនូវវិជ្ជាជីវៈរបស់ខ្លួន មានសិទ្ធិចូលរួមប្រាស្រ័យដោយសេរី ក្នុងសកម្មភាពនយោបាយ វប្បធម៌ និង សង្គម ។

**មាត្រា ៣២.** ប្រពន្ធនិងប្ដី មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ការអាស្រ័យផល ការចាត់ចែងទ្រព្យសម្បត្តិរួម ។

សហព័ន្ធម្នាក់ៗ មានសិទ្ធិពេញលេញក្នុងការប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងទ្រព្យផ្ទាល់ របស់ខ្លួន ។

**មាត្រា ៣៣.** ទ្រព្យសម្បត្តិរួម គឺជាអ្វីៗ ទាំងអស់ដែលសហព័ន្ធទាំងពីរ រកបានជាមួយគ្នា ឬ សហព័ន្ធណាម្នាក់រកបានក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍ ។

**មាត្រា ៣៤.** ត្រូវចាត់ទុកជាទ្រព្យសម្បត្តិផ្ទាល់របស់សហព័ន្ធ :

១- ទ្រព្យសម្បត្តិដែលសហព័ន្ធមានមុនរៀបអាពាហ៍ពិពាហ៍ ។

២- ទ្រព្យសម្បត្តិដែលសហព័ន្ធបានទទួលជាអំណោយជាមតិក ឬ ជាបច្ច័យទានក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍ ។

**មាត្រា ៣៥.** ត្រូវធ្លាក់លើបន្ទុកទ្រព្យសម្បត្តិរួម :

១- ការផ្គត់ផ្គង់គ្រួសារ និង ចំណាយដើម្បីអប់រំ និង បណ្ដុះបណ្ដាលកូន ។

២- បំណុល និង កាតព្វកិច្ចទាំងឡាយ ដែលសហព័ន្ធទាំងពីរបានព្រមព្រៀងគ្នាសំរេច ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ឬ ដែលសហព័ន្ធណាម្នាក់សំរេចក្នុងរយៈពេលមានចំណង អាពាហ៍ពិពាហ៍ដោយមានការយល់ព្រមពីសហព័ន្ធម្នាក់ទៀត ។

៣- ការថែទាំ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរួម ។

**មាត្រា ៣៦.** សហព័ន្ធម្នាក់ៗ អាចប្រើប្រាស់សម្ភារៈដែលជាទ្រព្យសម្បត្តិរួម តាមការតម្រូវនៃសម្ភារៈនោះ ។

សហព័ន្ធទាំងពីរនាក់ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួមជាមួយគ្នា ។ សហព័ន្ធម្នាក់អាចទាមទារឱ្យសហព័ន្ធម្នាក់ទៀតយល់ព្រមលើវិធានការចាំបាច់ដើម្បីថែទាំទ្រព្យសម្បត្តិរួម ឬ រក្សាទុកតម្លៃរបស់ទ្រព្យសម្បត្តិនោះ ។

**មាត្រា ៣៧.** ទ្រព្យសម្បត្តិរួមអាចលក់ដូរឬធ្វើអំណោយបាន លុះត្រាតែមានការព្រមព្រៀងពីសហព័ន្ធទាំងពីរ ។

## ជំពូកទី ៣
## អំពីការលែងលះគ្នា
### ផ្នែកទី ១
### អំពីមូលហេតុនៃការលែងលះគ្នា

**មាត្រា ៣៨.** ការលែងលះគ្នា គឺការផ្ដាច់ចំណងអាពាហ៍ពិពាហ៍របស់ប្ដីប្រពន្ធ ដែលបានរៀបការពេញច្បាប់ ក្នុងពេលរស់នៅទាំងពីរនាក់ ។

**មាត្រា ៣៩.** ប្ដី ឬ ប្រពន្ធ អាចប្ដឹងសុំលែងលះគ្នាបាន កាលបើមានមូលហេតុគ្រប់គ្រាន់ បញ្ជាក់ថា ខ្លួនពុំអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ។

មូលហេតុជាអាទិមានដូចខាងក្រោមនេះ :

១- ការចុះចោលលំនៅសង្វាស ដោយឥតមូលហេតុត្រឹមត្រូវ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និង ទំនុកបំរុងកូនសោះ ។

២- វាយដំឃោរឃៅ ធ្វើទុក្ខបុកម្នេញប្រមាថមើលងាយធ្ងន់ធ្ងរ ចំពោះសហព័ន្ធ ឬ ចំពោះបុព្វញាតិរបស់សហព័ន្ធនេះ ។

៣- មានចរិយាផ្ទុយពីសីលធម៌ ឬ ប្រព្រឹត្តអនាចារ ។

៤- អពលានុភាពនៃលិង្គ ។

៥- បែកគ្នាអស់រយៈពេលជាង ១ ឆ្នាំ

**មាត្រា ៤០.** ប្ដីប្រពន្ធ អាចលែងលះគ្នាដោយស្ម័គ្រចិត្តបាន ។

### ផ្នែកទី ២
### អំពីនីតិវិធី នៃ ការលែងលះគ្នា

**មាត្រា ៤១.** ការសំរេចអំពីការលែងលះគ្នា ជាសមត្ថកិច្ចរបស់តុលាការប្រជាជនខេត្ត-ក្រុង ខាងលំនៅរបស់ចុងចម្លើយ ។

**មាត្រា ៤២.** បណ្ដឹងលែងលះគ្នា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចុះមូលហេតុនាំឱ្យលែងលះគ្នា ។

បណ្ដឹងនោះត្រូវដើមចោទយកទៅជូនតុលាការប្រជាជនខេត្ត-ក្រុងផ្ទាល់ក៏បាន ឬជូនគណៈកម្មាធិការប្រជាជន ឃុំ ឬសង្កាត់ខាងលំនៅរបស់ចុងចម្លើយ ដោយខ្លួនឯងផ្ទាល់ក៏បាន ។

ក្នុងករណីខាងក្រោមនេះ គណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ត្រូវធ្វើការផ្សះផ្សាក្នុងរយៈ១៥ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្ដឹង ។ បើផ្សះផ្សាពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅតុលាការប្រជាជនខេត្ត-ក្រុង ។

**មាត្រា ៤៣**~ តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញអ្នកប្តឹងឱ្យចូលមក ហើយសំរួលយ៉ាណោតាមដែលខ្លួនយល់ឃើញ ដើម្បីបញ្ចូលចិត្តអ្នកនោះឱ្យឈប់ប្តឹង លើកលែងតែតុលាការប្រជាជនខេត្ត-ក្រុងយល់ឃើញថា ពាក្យសុំលែងលះគ្នានេះមានអាចហេតុធ្ងន់ធ្ងរណាស់ ។

**មាត្រា ៤៤**~ ក្រោយពីពេលបានទទួលបណ្តឹងសុំលែងលះ បើយល់ឃើញថា ការចាំបាច់ តុលាការប្រជាជនខេត្ត-ក្រុងអាចចាត់វិធានការបណ្តោះអាសន្នបាន ដូចជាការបំបែកលំនៅប្តី ប្រពន្ធ ការឱ្យថែរក្សា ថែរក្សាទ្រព្យសម្បត្តិ ការផ្តល់អាហារកិច្ច ។ ក្នុងករណីនេះ មេធាវីនៃគូភាគីអាចចូលរួមស្តាប់បាន ។

**មាត្រា ៤៥**~ ប្រសិនបើដើមចោទនៅតែទទូចសុំលែង តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញប្តី ប្រពន្ធអោយមកកាន់តុលាការជាប្រញាប់ ដើម្បីធ្វើការផ្សះផ្សា ។ ក្នុងករណីនេះ មេធាវីមិនត្រូវចូលរួមស្តាប់ទេ ។

**មាត្រា ៤៦**~ប្រសិនបើផ្សះផ្សាចំពោះមុខដើមចោទ និងចុងចម្លើយហើយនៅតែពុំបានសំរេច តុលាការប្រជាជនខេត្ត-ក្រុង អាចធ្វើការផ្សះផ្សាជាលើកទី ២ បាន ។

**មាត្រា ៤៧**~ ប្រសិនបើនៅពេលផ្សះផ្សាលើកទី ១ ដើមចោទ ឬ ចុងចម្លើយ ដែលបានទទួលដីកាអញ្ជើញដោយត្រឹមត្រូវ ហើយមិនមកបង្ហាញខ្លួនតាមការអញ្ជើញនោះ តុលាការប្រជាជនខេត្ត-ក្រុងត្រូវអញ្ជើញភាគីទាំងពីរនោះជាលើកទី ២ ដើម្បីធ្វើការផ្សះផ្សា ។

**មាត្រា ៤៨**~ ប្រសិនបើដើមចោទ ដែលបានទទួលដីកាអញ្ជើញដោយត្រឹមត្រូវ ហើយមិនបានមកកាន់តុលាការ ប្រជាជនខេត្ត-ក្រុង ទាំងលើកទី ១ ទាំងលើកទី ២ ដោយគ្មានមូលហេតុនោះត្រូវចាត់ទុកថា សុខចិត្តឈប់ប្តឹង ។

**មាត្រា ៤៩**~ ប្រសិនបើចុងចម្លើយ បានទទួលដីកាអញ្ជើញត្រឹមត្រូវ ហើយនៅតែមិនព្រមចូលមកកាន់តុលាការប្រជាជនខេត្ត-ក្រុង ទាំងលើកទី ១ ទាំងលើកទី ២ ដោយគ្មានមូលហេតុ នោះត្រូវចាត់ទុកថា មិនព្រមសះជានឹងគ្នា ។

**មាត្រា ៥០**~ ប្រសិនបើអ្នកមិនបានមកតាមដីកាអញ្ជើញលើកទី ១ មិនមែនជាអ្នកមិនបានមកលើកទី ២ ទេ តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញភាគីនោះមកផ្សះផ្សាយជាលើកទី ៣ ។

**មាត្រា ៥១**~ ការផ្សះផ្សាម្តងៗ ត្រូវឱ្យឃ្លាតពីគ្នា ១ ខែ យ៉ាងឆាប់ និង ២ ខែយ៉ាងយូរ ។

**មាត្រា ៥២**~ ក្នុងការផ្សះផ្សាម្តងៗ ទោះបីបានលទ្ធផលយ៉ាងណាក្តី ត្រូវចុះក្នុងកំណត់ហេតុបញ្ជាក់អំពីការផ្សះផ្សាបានសំរេច មិនបានសំរេច ឬ ភាគីមិនបានចូល ហើយចៅក្រមទទួលបន្ទុកការផ្សះផ្សាត្រូវ ចុះហត្ថលេខា លើកំណត់ហេតុនោះជាមួយភាគីវត្តមាន និង លេខាធិការក្រឡាបញ្ជី ។

មាត្រា ៥៣- បើការផ្សះផ្សាមិនបានសំរេច តុលារការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញប្តី ប្រពន្ធឱ្យចូលមកកាន់តុលាការប្រជាជន ដើម្បីជំនុំជំរះ ។

មាត្រា ៥៤- ប្រសិនបើដើមចោទ ត្រូវបានតុលាការប្រជាជនអញ្ជើញដោយត្រឹមត្រូវ ហើយមិនបានមកបង្ហាញខ្លួន ចំពោះតុលាការប្រជាជន និងមិនបានជូនសេចក្តីដោះសា ឬ មិនបានសុំឱ្យបង្អង់កាត់សេចក្តីទៅថ្ងៃក្រោយទេនោះ ត្រូវចាត់ទុកថា សុខចិត្តឈប់ប្តឹងវិញហើយ ។

ក្នុងករណីនេះ ត្រូវចេញសាលក្រមចំណាយរឿងក្តីនោះចោល ។

មាត្រា ៥៥- ប្រសិនបើចុងចម្លើយ មិនបានចូលមកកាន់តុលាការប្រជាជន ក្នុងល័ក្ខខ័ណ្ឌដូចខាងលើនេះដែរ ហើយបើយល់ឃើញថាហេតុដែលដើមចោទប្តឹងនោះមានភស្តុតាងពិតប្រាកដហើយ តុលាការប្រជាជនអាចសំរេចសេចក្តីឱ្យលែងលះគ្នាបាន។ បើបណ្តឹងនោះមិនទាន់មានភស្តុតាងគ្រប់គ្រាន់ ទេ តុលាការប្រជាជនត្រូវធ្វើការអង្កេតស៊ើបសួរអំពីរឿងនោះ ។

មាត្រា ៥៦- បើចុងចម្លើយប្រកែកថា សេចក្តីដែលប្តឹងពីខ្លួននោះមិនពិតទេ តុលាការប្រជាជនត្រូវបញ្ជាឱ្យធ្វើការអង្កេតស៊ើបសួរ ។

មាត្រា ៥៧- ក្នុងរឿងលែងលះគ្នា បើមានការត្រូវអង្កេតស៊ើបសួរ តុលាការប្រជាជនត្រូវធ្វើការអង្កេតស៊ើបសួរជាបន្ទាន់ ត្រូវបង្គាប់ឱ្យគូភាគី ជូនភស្តុតាងចាំបាច់នានាអញ្ជើញសាក្សីដែលមានប្រយោជន៍ក្នុងរឿងនេះ និង ចាត់វិធានការទូទៅ បើយល់ឃើញថា គួរចាត់ ។

មាត្រា ៥៨- ក្នុងករណីសុំលែងលះដោយព្រមព្រៀងគ្នា បើក្រោយពីការអង្កេតស៊ើបសួរឃើញថា ការសុំលែងលះគ្នានោះធ្វើដោយគ្មានការបង្ខិតបង្ខំ និង ដោយស្ម័គ្រចិត្តពិតប្រាកដ តុលាការប្រជាជនត្រូវសំរេចអោយលែងលះគ្នា ។

មាត្រា ៥៩- ក្នុងករណីសុំលែងលះដោយឯកតោភាគី បើក្រោយពីការអង្កេតស៊ើបសួរឃើញថា ស្ថានភាពរវាងប្តី ប្រពន្ធ មានភាពធ្ងន់ធ្ងរ ការរួមរស់ជាមួយគ្នាមិនអាចពន្យាយូរបាន គោលបំណងអាពាហ៍ពិពាហ៍លែងបានសំរេច តុលាការប្រជាជនត្រូវសំរេចឱ្យលែងលះគ្នា ។

មាត្រា ៦០- តុលាការប្រជាជនអាចធ្វើការស៊ើបសួរ និង ធ្វើការជំនុំជំរះដោយសម្ងាត់បាន ។

មាត្រា ៦១- ការវិនិច្ឆ័យដល់អង្គសេចក្តី ត្រូវតែធ្វើក្នុងរយៈ ១៥ ថ្ងៃ គិតពីថ្ងៃអង្កេតស៊ើបសួររួចមក ។

មាត្រា ៦២- តាមគោលការណ៍ សាលក្រមលែងលះគ្នាត្រូវសំរេចចំពោះមុខគូក្តី ។ ប្រសិនបើសាលក្រមនោះជាសាលក្រមកំបាំងមុខ គូក្តីអាចប្តឹងទាស់បាន ក្នុងរយៈ ១៥ ថ្ងៃ ។ រយៈពេលនេះគិតពីថ្ងៃដែលឱ្យដំណឹងពីសាលក្រមកំបាំងមុខដល់គូក្តីផ្ទាល់ ឬ ដល់លំនៅរបស់គូក្តី ។

មាត្រា ៦៣- បណ្តឹងទាស់និងសាលក្រមកំបាំងមុខ ត្រូវធ្វើដោយសាមីខ្លួន ជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់នៅតុលាការប្រជាជនខេត្ត ក្រុង ។ បណ្តឹងទាស់នាំឱ្យផ្អាកការអនុវត្តន៍សាលក្រម ។

**មាត្រា ៦៤.** ប្រសិនបើផុតរយៈពេលប្តឹងទាស់ សាលក្រមកំបាំងមុខនឹងទៅជាសាលក្រមស្ថាពរ ។

**មាត្រា ៦៥.** ប្រសិនបើអ្នកប្តឹងទាស់ បានប្តឹងក្នុងរយៈពេលកំណត់ ប៉ុន្តែមិនបានចូលខ្លួនមកក្នុងពេលជំនុំជំរះដោយគ្មានមូលហេតុ នោះសាលក្រមកំបាំងមុខត្រូវតំកល់ជាបានការ និង ទៅជាសាលក្រមស្ថាពរ ។

**មាត្រា ៦៦.** ប្រសិនបើបណ្តឹងជំទាស់ត្រឹមត្រូវតាមទម្រង់ច្បាប់តុលាការប្រជាជនខេត្ត-ក្រុង ត្រូវពិនិត្យ និង ជំនុំជំរះសាជាថ្មីលើអង្គសេចក្តី ។

តុលាការប្រជាជនអាចតំកល់ កែប្រែ ឬ បដិសេធសាលក្រមកំបាំងមុខ ដែលបានសំរេចសេចក្តី លើកមុនបាន កុំឱ្យតែបំពានលើច្បាប់ ឬ គោលការណ៍នៃច្បាប់ ។

**មាត្រា ៦៧.** កាលបើសាលក្រមលែងលះជាសាលក្រមស្ថាពរ តុលាការប្រជាជនខេត្ត-ក្រុង ត្រូវចាត់ចែងឱ្យចម្លងសេចក្តីនៃសាលក្រមស្ថាពរនោះ ចុះនៅរឹមទំព័រនៃសំបុត្រអាពាហ៍ពិពាហ៍ដែលត្រូវរលាយ ។

**មាត្រា ៦៨.** ប្រសិនបើប្រពន្ធមានផ្ទៃពោះ ប្តីងអាចនឹងសុំលែងលះបាន លុះត្រាតែប្រពន្ធនោះសំរាលកូនរួចបាន ១ឆ្នាំសិន ។

ការបន្ថយសិទ្ធិខាងលើមិនត្រូវអនុវត្តលើនារីទេ ។ នារីអាចសុំលែងលះបាននៅពេលមានផ្ទៃពោះ ។

## ផ្នែកទី ៣

## អំពីអនុភាពនៃការលែងលះគ្នា

**មាត្រា ៦៩.** ការលែងលះគ្នារំសាយអនុភាពអាពាហ៍ពិពាហ៍ ចាប់តាំងពីថ្ងៃដែលការលែងលះគ្នានោះ ទៅជាស្ថាពរ ។

**មាត្រា ៧០.** ក្នុងករណីនៃការលែងលះគ្នា ទ្រព្យសម្បត្តិត្រូវបែងចែកទៅតាមការព្រមព្រៀងនៃភាគីទាំងសងខាង ។ បើគ្មានការព្រមព្រៀង សហព័ទ្ធម្នាក់ៗត្រូវយកតែទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលមានមុនរៀបអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិដែលខ្លួនបានទទួលជាមតិកក្តី ជាអំណោយក្តី ជាអច្ច័យទានក្តី ក្នុងរយៈមានចំណងអាពាហ៍ពិពាហ៍ប៉ុណ្ណោះ ។

ក្រៅពីនេះ សហព័ទ្ធម្នាក់ៗ មានសិទ្ធិត្រូវបានទ្រព្យសម្បត្តិរួមពាក់កណ្តាលម្នាក់ ។

ប៉ុន្តែក្នុងករណីពិសេស និង តាមសំណើរបស់សហព័ទ្ធណាមួយ តុលាការប្រជាជនអាចសំរេចសេចក្តីចែកទ្រព្យសម្បត្តិរួម ផ្សេងពីគោលការណ៍ខាងលើបាន ដោយគិតទៅដល់ផលប្រយោជន៍របស់កូន និង ផលិតកម្ម ។

ការងារនៃគេហកិច្ច ត្រូវចាត់ទុកជាមានតម្លៃស្មើនឹងការងារផលិតកម្ម ។

**មាត្រា ៧១.** ប្រសិនបើទ្រព្យសម្បត្តិផ្ទាល់របស់សហព័ន្ធម្នាក់ត្រូវសហព័ន្ធម្នាក់ទៀតបំផ្លាញ សហព័ន្ធនេះត្រូវតែសងតម្លៃ ទ្រព្យនោះវិញ ។

**មាត្រា ៧២.** សាលក្រមដែលកាត់ឱ្យប្ដីប្រពន្ធលែងលះគ្នានោះ ត្រូវសំរេចអំពីអំណាចមេបា ដែលត្រូវប្រគល់ឱ្យទៅឪពុក ឬ ទៅម្ដាយ ហើយនិងត្រូវសំរេចអំពីការប្រាស្រ័យទាក់ទងរវាងឪពុក ម្ដាយ និង កូននោះផង ។

**មាត្រា ៧៣.** ដើម្បីផលប្រយោជន៍របស់កូន ការឱ្យភាគីណាមួយរក្សាកូន ត្រូវសំរេចតាមការយល់ព្រមនៃប្ដីប្រពន្ធដែលលែងលះគ្នានោះ ។ តាមគោលការណ៍កូនដែលនៅបៅដោះត្រូវឱ្យទៅម្ដាយរក្សា ។

ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នាលើការរក្សាកូន តុលាការប្រជាជនត្រូវសំរេច ។

**មាត្រា ៧៤.** ឪពុក ឬ ម្ដាយដែលលែងលះគ្នា ត្រូវជួយផ្គត់ផ្គង់ ជួយបីបាច់រក្សា ជួយផ្ដល់សោហ៊ុយ អប់រំ និងរៀនសូត្រដល់កូន តាមលទ្ធភាពរបស់ខ្លួន ។

កម្រិតអាហារកិច្ចដែលត្រូវឱ្យទៅកូន ត្រូវសំរេចតាមការព្រមព្រៀងនៃសហព័ន្ធដែលលែងលះគ្នា ។

ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នា តុលាការប្រជាជនត្រូវសំរេច ដោយផ្អែកទៅតាមលទ្ធភាពរបស់សហព័ន្ធម្នាក់ៗ ។

អាហារកិច្ចត្រូវផ្ដល់ឱ្យកូនរហូត ដល់កូនមាននីតិភាព ។

**មាត្រា ៧៥.** ភាគីដែលមិនបានរក្សាកូន មានសិទ្ធិទៅសួរសុខទុក្ខកូន ។ ភាគីដែលទទួលសិទ្ធិរក្សាកូនត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីម្ខាងទៀត ។

ភាគីដែលមិនបានរក្សាកូន មានសិទ្ធិប្ដឹងទៅតុលាការប្រជាជនគ្រប់ពេលវេលា ឱ្យដកសិទ្ធិរក្សាកូនពីភាគីម្ខាងនោះបាន បើមានការប៉ះពាល់ដល់ផលប្រយោជន៍របស់កូន ។

**មាត្រា ៧៦.** ក្នុងករណីលែងលះគ្នា ភាគីដែលគ្មានកំហុសហើយខ្វះខាត អាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន ។ ភាគីខាងក្រោយនេះ ត្រូវតែជួយឧត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួន ។

កំរិតអាហារកិច្ចត្រូវសំរេចតាមការយល់ព្រមរបស់គូភាគីទាំងសងខាង ។

ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នា តុលាការប្រជាជនត្រូវសំរេចសេចក្ដី ។

បើជនដែលទទួលអាហារកិច្ចរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ជននោះឈប់មានសិទ្ធិទទួលអាហារកិច្ចទៀតហើយ ។

**មាត្រា ៧៧.-** តុលាការប្រជាជនខេត្ត-ក្រុង អាចកែប្រែដោយបង្កើន ឬ បន្ថយកំរិតអាហារកិច្ចបាន បើមានសំណូមពររបស់ភាគីម្ខាង ។ ការបង្កើន ឬ បន្ថយកកម្រិតអាហារកិច្ចនោះ ត្រូវធ្វើឡើងតាមលទ្ធភាពនៃភាគីដែលផ្តល់អាហារកិច្ច និង តាមសេចក្តីត្រូវការនៃភាគីដែលទទួលអាហារកិច្ច ។

អាហារកិច្ចអាចផ្តល់ឱ្យជាទឹកប្រាក់ ឬ ជារបស់ ។

**មាត្រា ៧៨.-** ការមិនព្រមបង់អាហារកិច្ចដូចបានចែងខាងលើនេះ ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ដែលនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន បើកាលណាមានភស្តុតាង បញ្ជាក់ថា ជនដែលត្រូវផ្តល់អាហារកិច្ចនោះ មិនស្មោះត្រង់ ។

# តារាងនៃថ្នាក់ញាតិភាព
## (TABLEAU DES DEGRÉS DE LA PARENTÉ)

ខ្សែផ្ទាល់
( Ligne directe )

ខ្សែខាងឪពុក ខ្សែខាងម្តាយ




សាខាញាតិ
(Ligne collatérale)



មាត្រា ១១៣. កិច្ចសន្យាសុំកូន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយបញ្ជាក់ដោយគណៈកម្មាធិការប្រជាជនឃុំ ឬ សង្កាត់ខាងលំនៅនៃអ្នកសុំ ឬ ខាងលំនៅនៃកូនចិញ្ចឹម ។ សេចក្តីនៃកិច្ចសន្យាសុំកូននោះ ត្រូវចុះក្នុងបញ្ជីអាត្រានុកូលដ្ឋាន ។

តុលាការប្រជាជន អាចបដិសេធកិច្ចសន្យាខាងលើនេះបាន តាមពាក្យប្តឹងសុំរបស់កូនចិញ្ចឹមរបស់ជនទាំងឡាយ ឬ របស់អង្គការផ្សេងៗ ដែលធ្វើឡើងដើម្បីផលប្រយោជន៍របស់កូនចិញ្ចឹមនោះ ។

មាត្រា ១១៤. កូនចិញ្ចឹមត្រូវយកនាមត្រកូលនៃអ្នកសុំហើយមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងកូនបង្កើត ។

## ផ្នែកទី ៥

## អំពីទំនាក់ទំនងរវាងឪពុក ម្តាយ និង កូន

មាត្រា ១១៥. ឪពុកម្តាយមានករណីយកិច្ចត្រូវស្រឡាញ់កូន ចិញ្ចឹមបីបាច់រក្សាកូន និង យកចិត្តទុកដាក់អប់រំកូន គឺបណ្តុះគំនិតកូនអោយស្រឡាញ់ការរៀនសូត្រ ស្នេហាមាតុភូមិ មានស្មារតី សាមគ្គីអន្តរជាតិ ស្រឡាញ់ពលកម្ម គោរពទ្រព្យសម្បត្តិរដ្ឋ គោរពសិទ្ធិ និង ទ្រព្យសម្បត្តិ របស់អ្នកដទៃ ។

កូនមានករណីយកិច្ចត្រូវស្រឡាញ់ និង គោរពឪពុកម្តាយ ថែទាំរក្សា ឪពុក ម្តាយ និង ផ្គត់ផ្គង់ សេចក្តីត្រូវការរបស់ឪពុក ម្តាយ ។

មាត្រា ១១៦. ឪពុក ម្តាយ មិនត្រូវធ្វើបាបកូនរបស់ខ្លួន កូនប្រសា កូនចិញ្ចឹម ឬ កូនរបស់ប្តី ឬ របស់ប្រពន្ធមុនឡើយ ។

មាត្រា ១១៧. កូនប្រសា និង កូនស្រីមានសិទ្ធិ និង ករណីយកិច្ចដូចគ្នាក្នុងគ្រួសារ ។

មាត្រា ១១៨. កូនមាននីតិភាព ដែលរស់នៅជាមួយ ឪពុកម្តាយ មានសេរីភាពក្នុងការជ្រើសរើសមុខរបររបស់ខ្លួន មានសេរីភាពក្នុងការចូលរួមសកម្មភាពនយោបាយ និង សកម្មភាពសង្គម មានសេរីភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ម្យ៉ាងវិញទៀត ក៏ត្រូវមានករណីយកិច្ចត្រូវមើលខុសត្រូវដោះស្រាយជីវភាពរួម របស់គ្រួសារ ។

## ផ្នែកទី ៦

## អំពីការដកហូតអំណាចមេបា

មាត្រា ១១៩. អាចនឹងដកហូតអំណាចមេបា ហើយប្រគល់ទៅអង្គការណាមួយ ឬញាតិលោហិតណាមួយចំពោះ ឪពុក ម្តាយ ដែល មានកំហុសដូចខាងក្រោម :

- ឪពុក ម្តាយ មានការខ្វះខាតក្នុងការអប់រំ
- ឪពុក ម្តាយ ប្រើអំណាចដោយរំលោភទៅលើកូនដោយប្រើឧបាយផ្សេងៗ ដើម្បីបង្ខំកូនឱ្យប្រព្រឹត្តបទល្មើស ឬ អំពើណាមួយប៉ះពាល់ដល់សង្គម ។

- ឪពុក ម្ដាយ ប្រព្រឹត្តផ្ទុយពីសីលធម៌បណ្ដាលឱ្យមានឥទ្ធិពលអាក្រក់ដល់កូន ។

**មាត្រា ១២០.** តុលាការប្រជាជន អាចវិនិច្ឆ័យសំរេចដកហូតអំណាចមេបាពីឪពុកម្ដាយ ដែលមានកំហុសបាន លុះត្រាតែមានពាក្យប្ដឹងសុំរបស់អង្គការរដ្ឋ អង្គការមហាជន រដ្ឋអាជ្ញាអមតុលាការប្រជាជន ឬ ញាតិលោហិតណាមួយនៃឪពុកម្ដាយនោះ ។

**មាត្រា ១២១.** ការហូតអំណាចមេបា បណ្ដាលឱ្យឪពុកម្ដាយ លែងមានសិទ្ធិ ដែលខ្លួនធ្លាប់មានពីមុនចំពោះកូនរបស់ខ្លួន ប៉ុន្តែនៅមានកាតព្វកិច្ចចិញ្ចឹមកូនតទៅទៀត រហូតដល់កូននេះចូលនីតិភាព ។ ក្នុងករណីនេះ តុលាការប្រជាជនត្រូវកំណត់ការឧបត្ថម្ភអាហារកិច្ច ដែលឪពុកម្ដាយត្រូវផ្ដល់ទៅឱ្យអង្គការ ឬ ញាតិលោហិតដែលទទួលបន្ទុកចិញ្ចឹមកូននោះ ។

**មាត្រា ១២២.** ដើម្បីផលប្រយោជន៍របស់កូន ច្បាប់អនុញ្ញាតឱ្យតុលាការប្រជាជនប្រគល់ ទៅឪពុកម្ដាយដែលត្រូវបានដកហូតអំណាចមេបានូវអំណាចមេបានេះឡើងវិញប្រសិនបើឪពុកម្ដាយនោះបានកែប្រែគំនិតមារយាទរបស់ខ្លួនបានល្អឡើងវិញគួរឱ្យទទួលបន្ទុកអប់រំកូនបានលើកលែងតែចំពោះកូនចិញ្ចឹម ។

ច្បាប់នេះ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័ត នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៨៩ នា សម័យប្រជុំសាមញ្ញលើកទី ១៧ នីតិកាលទី ១ ។

ភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩

ជ. រដ្ឋសភា

ប្រធាន

ហត្ថលេខា និង ត្រា : ជា ស៊ីម

# ឧបសម្ព័នទី៥

# ច្បាប់

# ស្តីពី

# នីតិវិធីនៃរឿងក្តី

# រដ្ឋប្បវេណីដែល

# មិនមែនជាបណ្តឹង

# ព្រះរាជក្រម

នស/រកម/០៧១០/០១៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

# ច្បាប់

# ស្តីពី

# នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី

# ដែលមិនមែនជាបណ្តឹង

អ្នកតំណាងដោយផ្អែកលើការអនុញ្ញាតរបស់តុលាការដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៩ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) ខាងលើនេះ ។

### មាត្រា ២១.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីសិទ្ធិតំណាងដោយអាណត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី

បញ្ញត្តិនៃមាត្រា ៥៥ (ករណីដែលសិទ្ធិតំណាងដោយអាណត្តិមិនរលត់) មាត្រា ៥៦ (ហេតុនៃការរលត់នូវសិទ្ធិតំណាងដោយអាណត្តិ) និង មាត្រា ៥៧ (វិធានការក្នុងករណីនៃការខ្វះសិទ្ធិតំណាង) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងដោយអាណត្តិ ។

## ជំពូកទី ៤
## ប្រាក់ប្រដាប់ក្តី

### មាត្រា ២២.- បន្ទុកនៃប្រាក់ប្រដាប់ក្តី

១- ដើម្បីដាក់ពាក្យសុំតាមនីតិវិធីនៃរឿងក្តីដែលកំណត់ក្នុងច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។

២- បញ្ញត្តិនៃមាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ) និង មាត្រា ៦៣ (ប្រាក់ប្រដាប់ក្តីភាគី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាក់ប្រដាប់ក្តីក្រៅពីពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

៣- ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ
គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ
លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសអំពីអ្នកទទួលបន្ទុកនោះក្នុងច្បាប់នេះ ។

៤- ចំពោះរឿងក្តីដែលតំណាងអយ្យការបានដាក់ពាក្យសុំ ឬ រឿងក្តីដែលតុលាការបានចាប់ផ្តើមដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ជាបន្ទុករបស់រដ្ឋ ។

៥- បញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានជនច្រើននាក់ដែលត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តីដោយរួមគ្នា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៦- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ ត្រូវបង់ពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យបង់ពន្ធនោះ។ ក្នុងករណីនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវលើកលិខិតពាក្យសុំចោលដោយដីកាសម្រេច ។

៧- ចំពោះដីកាសម្រេចលើកចោលលិខិតពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ៦ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៨- ដើម្បីប្តឹងជំទាស់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៩ (បណ្តឹងជំទាស់) នៃច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។ បញ្ញត្តិនៃកថាខណ្ឌទី ៦ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដាក់ពាក្យបណ្តឹងជំទាស់មិនបានបង់ពន្ធនោះ ។

## មាត្រា ២៣.- ដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី

១- ប្រសិនបើយល់ឃើញថាចាំបាច់សម្រេចអំពីអ្នកទទួលបន្ទុក ឬ ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងមាត្រា ២២ (បន្ទុកនៃប្រាក់ប្រដាប់ក្តី)ខាងលើនេះ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីនោះ និង ត្រូវចេញដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីនោះ ព្រមជាមួយគ្នានឹងដីកាសម្រេចអំពីរឿងក្តីនោះ ។

២- ក្នុងករណីដែលមានស្ថានភាពពិសេស តុលាការអាចបង្គាប់ឱ្យជនពាក់ព័ន្ធដែលមិនមែនជាជនដែលត្រូវទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីតាមបញ្ញត្តិនៃច្បាប់នេះ ទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីទាំងស្រុង ឬ មួយភាគបាន ។

៣- ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី មានតែជនដែលត្រូវបានបង្គាប់ឱ្យទទួលបន្ទុកប្រាក់ប្រដាប់ក្តីនេះទេ ដែលអាចប្តឹងជំទាស់បាន ប៉ុន្តែមិនអាចប្តឹងជំទាស់ដោយឯករាជ្យបានឡើយ ។

## មាត្រា ២៤.- ការអនុវត្តដោយបង្ខំអំពីប្រាក់ប្រដាប់ក្តី

១- ម្ចាស់បំណុលលើប្រាក់ប្រដាប់ក្តី អាចអនុវត្តដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីបាន ។

២- បញ្ញត្តិនៃគន្ថីទី ៦ (ការអនុវត្តដោយបង្ខំ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប៉ុន្តែមិនចាំបាច់ធ្វើការបញ្ជូនដីកាសម្រេចមុនពេលអនុវត្តទេ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣- បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣០៥ (ការផ្អាកអានុភាពនៃដីកាសម្រេចដើម) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានបណ្តឹងជំទាស់ ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី ។

**មាត្រា ២៥.- ការបង់ប្រាក់ប្រដាប់ក្តីជំនួសជាមុន**

ចំពោះប្រាក់ប្រដាប់ក្តីសម្រាប់ការពិនិត្យភស្តុតាង ការកោះហៅ ការជូនដំណឹង និង ការចាត់ចែងចាំបាច់ផ្សេងទៀត ដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ រដ្ឋត្រូវបង់ជំនួសជាមុន ប៉ុន្តែចំពោះសកម្មភាពដែលត្រូវការប្រាក់ប្រដាប់ក្តី តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធបង់ប្រាក់ប្រដាប់ក្តីនោះជាមុនបាន ។

## ជំពូកទី ៥
## ការវិនិច្ឆ័យ

**មាត្រា ២៦.- របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ**

១- ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ។

២- នៅក្នុងលិខិតនៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ ៖

ក- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ- ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ។

៣- ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី ។ ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និង ចុះហត្ថលេខា ។ កំណត់ហេតុនោះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ ។

៤- ក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដើម ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬ ត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## មាត្រា ២៧.– ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និង ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ

១- តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយអ្នកដាក់ពាក្យសុំ ឬ ដោយភាគីម្ខាងទៀតមកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន ។

២- ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការត្រូវធ្វើការស្រាវជ្រាវអង្គហេតុ និង ធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ ។

## មាត្រា ២៨.– ការទាញហេតុផលដោយផ្ទាល់មាត់ និងការសួរដោយឆន្ទានុសិទ្ធិ

១- ដើម្បីចេញដីកាសម្រេចអំពីរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ តុលាការពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។

២- ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់បាន ។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឲ្យអ្នកដែលតុលាការយល់ថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បាន ។

## មាត្រា ២៩.–ករណីយកិច្ចបង្ហាញខ្លួនរបស់សាមីខ្លួន

១- តុលាការអាចកោះហៅអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀត ដែលតុលាការយល់ឃើញថាចាំបាច់បាន ដោយកំណត់កាលបរិច្ឆេទ ។

២-ក្នុងករណីជនដែលត្រូវបានកោះហៅដោយតុលាការ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានបង្ហាញខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល បាន ។

## មាត្រា ៣០.– ការចូលរួមរបស់តំណាងអយ្យការ និង ការជូនដំណឹង

១- ប្រសិនបើយល់ឃើញថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការអំពីរឿងក្តី និង កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្នុងកាលបរិច្ឆេទនៃការសួរ ។

២- ប្រសិនបើយល់ឃើញថាចាំបាច់ការពារផលប្រយោជន៍សាធារណៈ តំណាងអយ្យការអាចបញ្ចេញមតិចំពោះរឿងក្តី និង ចូលរួមក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្នុងកាលបរិច្ឆេទនៃការសួរបាន ។

៣- ក្នុងករណីដែលបានដឹងតាមមុខនាទីរបស់ខ្លួនថា ករណីដែលតំណាងអយ្យការអាចដាក់ពាក្យសុំ ឬ ទាមទារបានកើតឡើង តុលាការ ស្ថាប័នរដ្ឋផ្សេងទៀត និង មន្ត្រីស្ថាប័នទាំងនោះ និង តំណាងអយ្យការ ត្រូវជូនដំណឹងអំពីករណីនោះទៅតំណាងអយ្យការអមតុលាការដែលមានសមត្ថកិច្ច ។

## មាត្រា ៣១.- ការចូលរួមក្នុងនីតិវិធីរបស់ជនពាក់ព័ន្ធនឹងផលប្រយោជន៍

១- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចឲ្យជនក្រៅពីអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត ក្នុងចំណោមជនពាក់ព័ន្ធដែលកំណត់ក្នុងមាត្រា ១៥ (ជនពាក់ព័ន្ធ) នៃច្បាប់នេះ ចូលរួមក្នុងនីតិវិធីបាន ។

២- ជនដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចចូលរួមក្នុងនីតិវិធីបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

## មាត្រា ៣២.- ការទទួលបន្តនូវនីតិវិធី

១- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត មិនអាចបន្តនីតិវិធីដោយសារមរណភាព ការបាត់បង់លក្ខណសម្បត្តិ ឬមូលហេតុផ្សេងទៀត ជនដែលមានលក្ខណសម្បត្តិក្នុងការដាក់ពាក្យសុំឲ្យដំណើរការនីតិវិធីនោះ តាមច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត អាចដាក់ពាក្យសុំទទួលបន្តនូវនីតិវិធីនោះបាន ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឲ្យជនដែលមានលក្ខណសម្បត្តិក្នុងការដាក់ពាក្យសុំឲ្យដំណើរការនីតិវិធីនោះតាមច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ទទួលបន្តនូវនីតិវិធីនោះបាន ។

## មាត្រា ៣៣.- ការមើលសំណុំរឿង ជាអាទិ៍

១- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចអនុញ្ញាតឲ្យមើល ឬឲ្យថតចម្លងសំណុំរឿង ឬ អាចបង្គាប់ឲ្យក្រឡាបញ្ជីប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឯកសារដកស្រង់នៃសំណុំរឿង ឬ លិខិតបញ្ជាក់អំពីចំណុចទាក់ទងនឹងរឿងក្តីបាន តាមពាក្យសុំរបស់ជនពាក់ព័ន្ធនឹងរឿងក្តីនោះ ដោយឲ្យបង់សោហ៊ុយ ។

២- ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត ទាមទារឲ្យប្រគល់នូវឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃលិខិតដីកាសម្រេច ឬ ទាមទារឲ្យប្រគល់នូវលិខិតបញ្ជាក់អំពីចំណុចទាក់ទងនឹងរឿងក្តី ក្រឡាបញ្ជីត្រូវប្រគល់ឯកសារ ឬ លិខិតនោះ ។

## មាត្រា ៣៤.- ការអនុវត្តដូចគ្នាតាមក្រមនីតិវិធីរដ្ឋប្បវេណី

១- បញ្ញត្តិស្តីពីកាលបរិច្ឆេទ អំឡុងពេល វិធីធ្វើសេចក្តីបញ្ជាក់ដំបូង នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីដែលកំណត់ក្នុងច្បាប់នេះ លើកលែងតែមានភាពផ្ទុយគ្នានឹងលក្ខណៈនៃនីតិវិធីនេះ ។

២- បញ្ញត្តិស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ការសាកសួរសាក្សី ការសាកសួរភាគីកោសលវិច័យ ការត្រួតពិនិត្យ និងភស្តុតាងជាឯកសារ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវអនុវត្តដូចគ្នាផងដែរចំពោះករណីដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងនីតិវិធីដែលកំណត់ក្នុងច្បាប់នេះ លើកលែងតែមានភាពផ្ទុយគ្នានឹងលក្ខណៈនៃនីតិវិធីនេះ ។

# ជំពូកទី ៦
# ការសម្រេចសេចក្តី

## មាត្រា ៣៥.- វិធីសម្រេចសេចក្តី

ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ត្រូវសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចនេះ ។

## មាត្រា ៣៦.- ការជូនដំណឹងអំពីដីកាសម្រេច

ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ត្រូវជូនដំណឹងទៅជនដែលត្រូវទទួលដីកាសម្រេចនេះ ។ ការជូនដំណឹងអំពីដីកាសម្រេចនេះត្រូវធ្វើឡើងតាមរយៈការបញ្ជូន ឬ ការផ្ញើជូនឯកសារចម្លងយថាភូតនៃដីកាសម្រេចនោះ ។

### មាត្រា ៣៧.- ការចូលជាស្ថាពរ និង ការបង្កើតអានុភាពនៃដីកាសម្រេច

១- ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ មិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ដែលកំណត់ក្នុងមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) នៃច្បាប់នេះ ។

២- ការចូលជាស្ថាពរនៃដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានបង្អាក់ដោយការប្តឹងជំទាស់ ដែលត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ នោះ ។

៣- ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

### មាត្រា ៣៨.- អានុភាពអនុវត្តនៃដីកាសម្រេច

ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ ប្រគល់វត្ថុ អនុវត្តករណីយកិច្ចចុះបញ្ជី ឬ ផ្តល់គាវកាលិកផ្សេងទៀតដែលចូលជាស្ថាពរ ត្រូវក្លាយជាលិខិតអនុវត្តដែលកំណត់ក្នុងមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ជំពូកទី ៧
## បណ្តឹងឧបាស្រ័យ

### មាត្រា ៣៩.- បណ្តឹងជំទាស់

១- បុគ្គលទទួលឥទ្ធិពលដែលខូចប្រយោជន៍ដល់សិទ្ធិ ឬ ឋានៈគតិយុត្តរបស់ខ្លួនដោយសារដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ អំពីរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ អាចប្តឹងជំទាស់ចំពោះដីកាសម្រេចនោះបាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

២- ក្នុងករណីដែលត្រូវចេញដីកាសម្រេចតាមតែពាក្យសុំប៉ុណ្ណោះ មានតែជនដែលបានដាក់ពាក្យសុំទេ ដែលអាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំបាន ។

### មាត្រា ៤០.- អំឡុងពេលសម្រាប់ប្តឹងជំទាស់

១- ប្រសិនបើជនដែលអាចប្តឹងជំទាស់ បានទទួលនូវការជូនដំណឹងអំពីដីកាសម្រេច បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ ។

២- ប្រសិនបើជនដែលអាចប្តឹងជំទាស់ មិនមែនជាជនដែលត្រូវទទួលនូវការជូនដំណឹងអំពីដីកាសម្រេច ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៦ (ការជូនដំណឹងអំពីដីកាសម្រេច) នៃច្បាប់នេះទេ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលជនដាក់ពាក្យសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ ។

៣- ចំពោះរឿងក្តីដែលបានចាប់ផ្តើមឡើងដោយឆន្ទានុសិទ្ធិ អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវគណនាពីថ្ងៃដែលជនបានទទួលក្រោយគេនូវការជូនដំណឹង បានទទួលដំណឹងនោះ ។

៤- អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ពុំអាចពន្យារបានឡើយ ។

## មាត្រា ៤១.- ការបំពេញនូវសកម្មភាពប្តឹងជំទាស់ ក្រោយពីអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត

១- ក្នុងករណីដែលជនដែលអាចប្តឹងជំទាស់ មិនបានគោរពតាមអំឡុងពេលសម្រាប់ប្តឹងជំទាស់ ដោយគ្មានកំហុសរបស់ខ្លួន ជននោះអាចប្តឹងជំទាស់បានក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ ក្រោយពេលមូលហេតុនោះបានរលត់ហើយ ចំពោះជនដែលនៅបរទេសវិញ អំឡុងពេលនោះមានចំនួន ២ (ពីរ) ខែ។

២- អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំអាចពន្យារបានឡើយ ។

## មាត្រា ៤២.- នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់

ក្រៅពីបញ្ញត្តិនៃជំពូកទី ៥ (ការវិនិច្ឆ័យ) នៃច្បាប់នេះ បញ្ញត្តិនៃជំពូកទី ៤ (បណ្តឹងជំទាស់) គន្ថីទី ៣ (បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងជំពូកទី ៧ នេះ ។

# ជំពូកទី ៨
# ការចាត់ចែងរក្សាការពារ

## មាត្រា ៤៣.- នីតិវិធីនៃការចាត់ចែងរក្សាការពារ

១-ក្នុងករណីមានពាក្យសុំអំពីរឿងក្តីដែលកំណត់ក្នុងច្បាប់នេះ តុលាការអាចបង្គាប់ឲ្យធ្វើការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្ន ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL

ឬ ការចាត់ចែងរក្សាការពារចាំបាច់ផ្សេងទៀត ដោយដីកាសម្រេចតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ដោយឲ្យដាក់ប្រាតិភោគ ឬ មិនឲ្យដាក់ប្រាតិភោគ ដោយយោងតាមបញ្ញត្តិនៃច្បាប់នេះ ។

២- តុលាការត្រូវបង្គាប់ឲ្យធ្វើការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយផ្អែកលើសេចក្តីបញ្ជាក់ដំបូង ។

៣-ក្នុងករណីបានដាក់ពាក្យសុំឲ្យចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកដាក់ពាក្យសុំ ត្រូវបញ្ជាក់ឲ្យច្បាស់លាស់នូវការចាត់ចែងរក្សាការពារដែលខ្លួនទាមទារ និង មូលហេតុនៃការទាមទារការចាត់ចែងរក្សាការពារនោះ ។

៤- អ្នកដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុនៃការទាមទារការចាត់ចែងរក្សាការពារ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ២៧ (ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និង ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ) នៃច្បាប់នេះ ក៏ដោយ ។

៥- ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចស្រាវជ្រាវអំពីអង្គហេតុ និង ពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន ។

៦- ដីកាសម្រេចអំពីការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវជូនដំណឹងទៅអ្នកទទួលដីកាសម្រេចនោះ ។ ដីកាសម្រេចអំពីការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានអានុភាពភ្លាមដោយការជូនដំណឹង ។

៧- អានុភាព និងការអនុវត្តនៃការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវអនុលោមតាមបញ្ញត្តិស្តីពីអានុភាព និង ការអនុវត្តនូវការរឹបអូសជាបណ្តោះអាសន្ន និង ការចាត់ចែងជាបណ្តោះអាសន្ន នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។

៨- បញ្ញត្តិនៃមាត្រា ៥៤៥ (ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន) មាត្រា ៥៤៦ (កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន) មាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន) មាត្រា ៥៤៨ (ភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ជាអាទិ៍) និង មាត្រា ៥៤៩ (វិធីចាត់ចែងជាបណ្តោះអាសន្ន) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ហើយបញ្ញត្តិនៃមាត្រា ៧១ (វិធីដាក់ប្រាតិភោគ និង ការប្តូរប្រាតិភោគ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាតិភោគដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

ROYAUME DU CAMBODGE * SECRETARIAT DU PALAIS ROYAL *

**មាត្រា ៤៤.- បណ្តឹងឧបាស្រ័យ**

១- ជនដែលបានដាក់ពាក្យសុំឲ្យចាត់ចែងរក្សាការពារ ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤៣ ( នីតិវិធីនៃការចាត់ចែងរក្សាការពារ ) ខាងលើនេះ អាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលនូវពាក្យសុំនោះបាន ។

២- ជនដែលអាចប្តឹងជំទាស់ ចំពោះដីកាសម្រេចទទួលស្គាល់ពាក្យសុំអំពីអង្គសេចក្តី អាចប្តឹងជំទាស់ចំពោះការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤៣ ( នីតិវិធីនៃការចាត់ចែងរក្សាការពារ ) ខាងលើនេះបាន ។

៣- ក្នុងករណីដែលបណ្តឹងជំទាស់ត្រូវបានធ្វើឡើងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ប្រសិនបើមានសេចក្តីបញ្ជាក់ជំបូងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលការចាត់ចែងរក្សាការពារ និងអំពីការណ៍ដែលមានការបារម្ភថា ការខូចខាតដែលមានការពិបាកនឹងធ្វើបដិទានឡើងវិញ នឹងកើតឡើងដោយសារការអនុវត្តការចាត់ចែងរក្សាការពារនោះ តុលាការនៃបណ្តឹងជំទាស់ អាចបង្គាប់ឲ្យធ្វើការចាត់ចែងដូចខាងក្រោមនេះ តាមពាក្យសុំ ៖

ក- ផ្អាកការអនុវត្តការចាត់ចែងរក្សាការពារ ដោយឲ្យដាក់ប្រាតិភោគ ឬ មិនឲ្យដាក់ប្រាតិភោគរហូតដល់ពេលដែលដីកាសម្រេចអំពីបណ្តឹងជំទាស់នោះបង្កើតអានុភាព ។

ខ- លុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ ដោយឲ្យដាក់ប្រាតិភោគរហូតដល់ពេលដែលដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ បង្កើតអានុភាព ។

៤- ក្នុងអំឡុងពេលដែលសំណុំរឿងក្តី នៅតែមាននៅតុលាការដើម តុលាការដើមនោះក៏អាចបង្គាប់ឲ្យធ្វើការចាត់ចែងដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះបានដែរ ។

៥- បញ្ញត្តិនៃមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) និង មាត្រា ៤១ (ការបំពេញសកម្មភាពប្តឹងជំទាស់ ក្រោយពីអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់ដែលកំណត់ក្នុងមាត្រានេះ ។ បញ្ញត្តិនៃកថាខណ្ឌទី ៤ និង ទី ៥ នៃមាត្រា ៤៣ ( នីតិវិធីនៃការចាត់ចែងរក្សាការពារ ) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសេចក្តីបញ្ជាក់ជំបូងដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ហើយបញ្ញត្តិនៃមាត្រា ៧១ (វិធីដាក់ប្រាតិភោគ និង ការប្តូរប្រាតិភោគ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាតិភោគដែលកំណត់ក្នុងកថាខណ្ឌទី ៣ នោះ ។

៦- បញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឲ្យធ្វើបដិទាន) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចលុបចោលនូវដីកាសម្រេចចាត់ចែងរក្សាការពារដែល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ឧបសម្ព័នទី៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងលែងលះតាមការព្រមព្រៀង

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..........ខែតុលា ឆ្នាំ២០២០

**រវាង ៖**

លោកស្រី កើតនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៨៣ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១០៣៧៨៩៥៥(១) មានអាសយដ្ឋានផ្ទះលេខ ៣សេ ផ្លូវលេខ ៩៩ ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ហៅថា**ភាគី"ក"** ត្រូវជាភរិយា ។

**និង**

លោក កើតនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៩ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ១០០៧៩៩៧០៣ មានអាសយដ្ឋានផ្ទះលេខ ១៥៤ZE0 ផ្លូវព្រះនរោត្តម ភូមិ៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ហៅថា**ភាគី"ខ"** ត្រូវជាស្វាមី ។

## ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម

## ប្រការ១៖ កម្មវត្ថុនៃកិច្ចព្រមព្រៀង

**ភាគី"ក"** និង**ភាគី"ខ"** មានឆន្ទៈពិតប្រាកដក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ តាមសំបុត្រអាពាហ៍ពិពាហ៍លេខ ៣៦ សៀវភៅអាពាហ៍ពិពាហ៍លេខ០១/២០០៨ នៅសាលាសង្កាត់ទួលទំពូងទី២ ដោយស្មគ្រ័ចិត្ត និងគ្មានការបង្ខិតបង្ខំ។

## ប្រការ២៖ សិទ្ធិលើអំណាចមេបាលើកូន និងអាហារកិច្ចចិញ្ចឹមកូន

២.១ **ភាគី"ខ"** យល់ព្រមប្រគល់សិទ្ធិឲ្យ**ភាគី"ក"** មានសិទ្ធិលើអំណាចមេបាលើកូនប្រុសឈ្មោះ កើតថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ ដែលមានសំបុត្រកំណើតលេខ ២៦ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ។

២.២ **ភាគី"ក"** ដែលមានអំណាចមេបា និង**ភាគី"ខ"** ដែលពុំមានអំណាចមេបា ត្រូវបំពេញកាតព្វកិច្ចបង់សោហ៊ុយចាំបាច់ និងអាហារកិច្ច ដល់កូនប្រុសរហូតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ ប៉ុន្តែ

ប្រសិនបើកូនចង់បន្តការសិក្សា**ភាគី"ខ"** និងជួយជ្រោមជ្រែងបន្ថែម ទៅតាមលទ្ធភាពដែលខ្លួនមាន ។

**២.៣ ភាគី"ខ"** ដែលពុំមានអំណាចមេបា មានសិទ្ធិទទួលយកកូនប្រុសទៅដើរលេងកំសាន្ត និងសម្រាកជាមួយនៅរៀងរាល់ថ្ងៃចុងសប្តាហ៍ថ្ងៃសៅរ៍ អាទិត្យ និងបុណ្យជាតិធំៗដូចជា ពិធីបុណ្យភ្ជុំបិណ្ឌ ពិធីបុណ្យអុំទូកអកអំបុក និងពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរជាដើម (ដោយពុំចាំបាច់មានការព្រមព្រៀងពី**ភាគី"ក"**) ។ **ភាគី"ខ"** អាចទទួលយកកូនទៅលេងជាមួយនៅថ្ងៃផ្សេងៗទៀត ដោយមានការព្រមព្រៀងជាមុនពី**ភាគី"ក"** ។

**ប្រការ៣៖ ដើម្បីផលប្រយោជន៍របស់កូន**

**៣.១** ទៅថ្ងៃក្រោយ**ភាគី"ក"** ត្រូវប្រគល់សិទ្ធិផ្តាច់មុខក្នុងការសម្រេចចិត្តដល់កូនប្រុសឈ្មោះ មករស់នៅជាមួយ**ភាគី"ខ"** ស្របច្បាប់ទោះបីជាកូនស្ថិតនៅជាអនីតិជនក៏ដោយ ក្នុងករណីបើកូនយល់ឃើញថាពុំមានភាពកក់ក្តៅក្នុងការរស់នៅជាមួយ**ភាគី"ក"** ឬត្រូវទទួលរងការប្រមាថ ឬធ្វើបាបដោយបុគ្គលដទៃណាមួយ ។

**៣.២** ក្នុងករណី**ភាគី"ក"** មិនបានចិញ្ចឹមបីបាច់ថែរក្សាកូនបានល្អ ឬឃាត់ឃាំងបិទសិទ្ធិសេរីភាពកូននោះ **ភាគី"ខ"** អាចទាមទារអោយតុលាការប្រគល់សិទ្ធិអំណាចមេបាលើកូនប្រុសឈ្មោះ មកឱ្យ**ភាគី"ខ"** ជាអ្នកគ្រប់គ្រងកូនវិញ ដូចដែលមានចែងក្នុងច្បាប់ ។

**៣.៣ ភាគី"ក"** សំណូមពរ ទៅ**ភាគី"ខ"** សុំថារាល់ការឧបត្ថម្ភរបស់**ភាគី"ខ"** ទៅអោយកូនប្រុសឈ្មោះ ទោះដោយផ្ទាល់ដៃ ឬដោយការផ្ញើវិធីផ្សេងៗជាសាច់ប្រាក់សុទ្ធ ឬជាប្រដាប់ប្រដាប្រើប្រាស់អ្វីផ្សេងៗ សូម**ភាគី"ខ"** មេត្តាពិគ្រោះពិភាក្សា ឬជូនជាដំណឹងដល់**ភាគី"ក"** ជាមុនផង ព្រោះដើម្បីការពារផលប្រយោជន៍កូនប្រុស បញ្ចៀសពីហានិភ័យណាមួយដែលអាចជំរុញអោយកូនប្រុសប្រើប្រាស់ថវិកា ឬរបស់របរទាំងនោះខុសគោលដៅ ជាមូលហេតុជំរុញអោយកូនប្រុសដើរផ្លូវខុសណាមួយដោយឥតគ្រោងទុករបស់ឪពុកម្តាយ ។

**ប្រការ៤៖ ចំពោះទ្រព្យសម្បត្តិ និងបំណុលរួម**

**ភាគី"ក"** និង**ភាគី"ខ"** ពុំមានទ្រព្យសម្បត្តិរួម និងបំណុលរួមទេ ។ ចំពោះរាល់ការទាមទារលើសពីនេះ**ភាគី"ក"** និង**ភាគី"ខ"** មិនទទួលខុសត្រូវឡើយ ។

**ប្រការ៥៖ អានុភាពនៃកិច្ចសន្យា**

**៥.១** កិច្ចព្រមព្រៀងនេះធ្វើឡើងដោយការស្ម័គ្រចិត្ត ពុំមានការបង្ខិតបង្ខំពីអ្នកដទៃឡើយ ។

**៥.២** គូភាគីនៃកិច្ចព្រមព្រៀងនេះបានអាន និងព្រមព្រៀងទាំងស្រុងលើខ្លឹមសារ ដែលបានចែងខាងលើ និងយល់ព្រមផ្តិតមេដៃនៅចំពោះមុខមេធាវី ។

**៥.៣** កិច្ចព្រមព្រៀងនេះធ្វើឡើងជាភាសាខ្មែរចំនួន ០៤(បួន)ច្បាប់ដើម ដោយរក្សាទុកនៅភាគីទាំងពីរម្នាក់ៗចំនួន ០១(មួយ)ច្បាប់ មេធាវី ០១(មួយ)ច្បាប់ និងតម្កល់នៅក្នុងសំណុំរឿងមួយច្បាប់ ។

**៥.៤** កិច្ចព្រមព្រៀងនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់តាំងពីថ្ងៃចុះហត្ថលេខា ឬផ្តិតមេដៃរបស់គូភាគីតទៅ ។

ស្នាមមេដៃស្តាំ**ភាគី"ខ"** ស្នាមមេដៃស្តាំ**ភាគី"ក"**

លោក លោកស្រី

**បានឃើញ**

គូភាគីពិតជាបានផ្តិតមេដៃចំពោះមុខមេធាវីប្រាកដមែន

**ហត្ថលេខា និងត្រា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**ដីកាសម្រេច**
-លេខ: ........ "ផ"
-ចុះថ្ងៃទី...ខែវិច្ឆិកា ឆ្នាំ២០២១
-សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្ដឹងលេខ:១០៧៦
ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១

# ដីកាសម្រេចរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹង

យើង ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខនស/ រកម/០៧០៦/ ០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦ ។

-បានឃើញ បានឃើញមាត្រា៣ និងមាត្រា ពាក់ព័ន្ធ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៧១០/ ០១៣ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១០ ។

-បានឃើញ ច្បាប់ស្ដីពីការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី ។

-បានឃើញ មាត្រា៩៥០ មាត្រា ៩៧៩ មាត្រា ៩៨០ មាត្រា ១០៣៧ មាត្រា ១០៤០ និង មាត្រា ១១៤១ នៃក្រមរដ្ឋប្បវេណី ។

-បានឃើញ លិខិតលេខ ១០ ក.យស.ជ.ណ/២០១១ ចុះថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០១១ របស់ទីស្ដីការក្រសួងយុត្តិធម៌ ស្ដីពីច្បាប់អនុវត្តក្រមរដ្ឋប្បវេណី ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទង នឹងឋានៈបុគ្គល និងច្បាប់ស្ដីពីនីតិវិធី រឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងដែលត្រូវអនុវត្តទូទាំងប្រទេស នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១ ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ១០៧៦ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ ២០២១ ។

-អ្នកដាក់ពាក្យសុំ៖ឈ្មោះ ភេទស្រី កើតថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៨៣ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ៣សេ ផ្លូវលេខ៩៩ ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

-មេធាវីតំណាងដោយអាណត្តិឈ្មោះ ។

-និងភាគីម្ខាងទៀត៖ឈ្មោះ ភេទប្រុស កើតថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៩ សញ្ជាតិខ្មែរ មានអាសយដ្ឋាន ស្ថិតនៅផ្ទះលេខ១៥៤ZEo ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

## I.អង្គហេតុ និងចំណុចវិវាទ

១.ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំឱ្យតុលាការចេញ

-សុំឱ្យតុលាការចេញដីកាសម្រេចលែងលះតាមការព្រមព្រៀងរវាងអ្នកដាក់ពាក្យសុំឈ្មោះ និង ភាគីម្ខាងទៀតឈ្មោះ

-សុំឱ្យអ្នកដាក់ពាក្យសុំឈ្មោះ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ ភេទប្រុស កើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ ។

២.ការពន្យល់ត្រួសៗអំពីរឿងក្ដី៖

ក្នុងរឿងនេះឃើញថា កាលពីរវាងឆ្នាំ២០០៨ អ្នកដាក់ពាក្យសុំឈ្មោះ និង ភាគីម្ខាងទៀតឈ្មោះ លី បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវតាមប្រពៃណីខ្មែរ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ៣៦ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៨ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ទួលទំពូងទី២។ក្នុងជីវិត អាពាហ៍ពិពាហ៍ ភាគីទាំងពីរមានរឿងរកាំរកូសក្នុងគ្រួសារ ដោយបានបែកលំនៅដ្ឋានគ្នាតាំងពីឆ្នាំ២០១៧ រហូតមកដល់បច្ចុប្បន្ន មានរយៈ

ពេល៣ឆ្នាំហើយ។ភាគីទាំងពីរមានកូនចំនួន០១នាក់ឈ្មោះ កើតថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ ។ចំពោះទ្រព្យសម្បត្តិរួមនិង បំណុលរួម គឺពុំមានទេ ។

៣.អង្គហេតុដែលអះអាងដោយភាគីអ្នកដាក់ពាក្យសុំ

-មេធាវីតំណាងដោយអាណត្តិឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថា:កាលពីអំឡុងឆ្នាំ២០០៨ កូនក្តីខ្លួន និងប្តីឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយបានចុះសុំបុត្រអាពាហ៍ ពិពាហ៍លេខ៣៦ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៨ នៅចំពោះមុខមន្ត្រីអាត្រានុកូលដ្ឋានសង្កាត់ទួលទំពូង២ ។ក្នុងអំឡុងជីវិតអាពាហ៍ពិពាហ៍ តែងតែមានរឿងរកាំរកូសក្នុងគ្រួសារ កូនក្តីខ្លួនបានបែកលំនៅដ្ឋានគ្នាតាំងពីឆ្នាំ២០១៧ រហូតមកដល់បច្ចុប្បន្ន គឺមានរយៈពេល៣ឆ្នាំហើយ។ ដោយការរស់នៅមិនចុះសម្រុងគ្នានេះ ទើបនៅថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ២០២១ កូនក្តីខ្លួន និងប្តីឈ្មោះ បានឯកភាពគ្នាធ្វើកិច្ចព្រមព្រៀងលែងលះដោយការព្រមព្រៀង ហើយនៅក្នុងកិច្ចព្រមព្រៀងនេះពុំមានភាគីណាបង្ខំភាគីណាឡើយ ។ ហេតុនេះក្នុងខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យភាគីអ្នកដាក់ពាក្យសុំនោះ គឺសុំឱ្យតុលាការសម្រេចតាមការទាមទាររបស់កូនក្តីខ្លួនដោយក្តីអនុគ្រោះ ។

៤.អង្គហេតុដែលអះអាងដោយដោយភាគីម្ខាងទៀត

-ភាគីម្ខាងទៀតឈ្មោះ (អវត្តមាន) ប៉ុន្តែនៅក្នុងកិច្ចព្រមព្រៀងលែងលះដោយការព្រមព្រៀងចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ នោះគឺភាគីម្ខាងទៀតបានឯកភាពគ្រប់ចំណុចអស់ហើយ។

៥.អង្គហេតុដែលគ្មានវិវាទ

៦.ចំណុចវិវាទ គ្មាន

## II.ការពិនិត្យភស្តុតាង

១. ភស្តុតាងជាឯកសាររបស់អ្នកដាក់ពាក្យសុំ៖

១.១.កិច្ចព្រមព្រៀងលែងលះដោយការព្រមព្រៀងចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ។

១.២. សំបុត្រអាពាហ៍ពិពាហ៍លេខ៣៦ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៨ ។

១.៣. សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ៣៣៩៥ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៤ ។

១.៤. សំបុត្របញ្ជាក់កំណើតលេខ២៧៣៥ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៥ ។

១.៥. សេចក្តីចម្លងសំបុត្រកំណើតលេខ២៦ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ។

១.៦.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ (ច្បាប់ចម្លង០១ច្បាប់)។

១.៧.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ (ច្បាប់ចម្លង០១ច្បាប់)។

២.ភស្តុតាងជាឯកសាររបស់ភាគីម្ខាងទៀត៖ គ្មាន

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់/សាកសួរ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា ៖

១.អ្នកដាក់ពាក្យសុំឈ្មោះ និង ភាគីម្ខាងទៀតឈ្មោះ ពិតជាបានរៀបអាពាហ៍ ពិពាហ៍ជាប្តី-ប្រពន្ធ តាមទំនៀមទំលាប់ប្រពៃណីក្នុងអំឡុងឆ្នាំ២០០៨ និង បានចុះសំបុត្រអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុ កូលដ្ឋានសង្កាត់ទួលទំពូងទី២ តាមសំបុត្រអាពាហ៍ពិពាហ៍លេខ:៣៦ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០០៨ ត្រឹមត្រូវតាមច្បាប់ពិតប្រាកដមែន ។

២.នៅក្នុងដំណាក់កាលនីតិវិធីសាកសួរអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត គឺពិតជាបានព្រមព្រៀងគ្នាដូច នៅក្នុងកិច្ចព្រមព្រៀងលែងលះដោយការព្រមព្រៀងចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ប្រាកដមែន ។ ដោយក្នុងការលែងលះនេះគឺភាគីទាំងពីរ បានបញ្ជាក់ថាគ្មាន អ្នកណាបង្ខំអ្នកណាឡើយ ហើយក្នុងកិច្ចព្រមព្រៀងនោះ គឺពិតជាស្នាមមេដៃរបស់ខ្លួនទាំងពីរដោយពិតប្រាកដ ។

៣.តាមកិច្ចព្រមព្រៀងលែងលះដោយការព្រមព្រៀងចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ តុលាការពិនិត្យឃើញថា: គូភាគីបានព្រមព្រៀងនិង ឯកភាពគ្នាគ្រប់ចំណុចរស់ហើយ ។

៤.យោងទៅតាមកិច្ចព្រមព្រៀងលែងលះដោយការព្រមព្រៀងនេះតុលាការគប្បីសម្រេច៖

-ឱ្យគូភាគីលែងលះគ្នា ទៅតាមការព្រមព្រៀងលែងលះដោយការព្រមព្រៀងចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ដោយយោងតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

-អំពីអំណាចមេបា ទៅតាមកិច្ចព្រមព្រៀងលែងលះដោយការព្រមព្រៀងចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ដោយយោងតាមមាត្រា១០៣៧ និងមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។

-អំពីរាបហារកាតព្វកិច្ច ទៅតាមកិច្ចព្រមព្រៀងលែងលះដោយស្ម័គ្រចិត្តចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ ដោយយោងតាមមាត្រា១១៤១ នៃក្រមរដ្ឋប្បវេណី ។

៥.នៅក្នុងរឿងក្តីនេះ គូភាគីបានឯកភាពគ្នាគ្រប់ចំណុច ដោយពុំមានចំណុចវិវាទ នោះទេ ហេតុនេះយោងតាមមាត្រា៩៧៩ មាត្រា ១០៣៧ មាត្រា ១០៤០ និងមាត្រា១១៤១ នៃក្រមរដ្ឋប្បវេណី និងមាត្រា ៣ ក្នុងតារាងឧបសម្ព័ន្ធទី៤ ចំណុចទី៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងតុលាការត្រូវសម្រេចសេចក្តីដោយដីកាសម្រេច ។

៦.អ្នកដាក់ពាក្យសុំឈ្មោះ ជាអ្នកដាក់ពាក្យបណ្តឹងសុំលែងលះ ដូចនេះត្រូវទទួលបន្ទុកលើប្រាក់ប្រដាប់ក្តីដោយយោងតាមមាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

## សេចក្តីសម្រេចបញ្ចប់

១.ឱ្យឈ្មោះ និង ឈ្មោះ ផ្តាច់សមគ្គសង្វាស់ពីគ្នាតាមការព្រមព្រៀង របស់គូភាគី យោងតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

២.ឱ្យឈ្មោះ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ ភេទប្រុស កើតថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ ។

តាមការព្រមព្រៀងរបស់គូភាគី( យោងតាមមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី )។

-ភាគីដែលពុំមានអំណាចមេបាក្រោយពេលលែងលះគ្នា មានសិទ្ធិចូលទៅជួប និង ប្រាស្រ័យទាក់ទងជាមួយកូនបាន រីឯភាគីដែលទទួលបានសិទ្ធិរក្សាកូន ត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីម្ខាងទៀត(យោងតាមមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី )។

៣.ឱ្យឈ្មោះ បង់រាបហារកាតព្វកិច្ចចិញ្ចឹមកូនទៅឱ្យអ្នកដាក់ពាក្យសុំឈ្មោះ ទៅតាមលទ្ធភាព តាមការព្រមព្រៀងរបស់គូភាគី(យោងតាមមាត្រា១១៤១ នៃក្រមរដ្ឋប្បវេណី) ។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ ។

ចៅក្រម

ហត្ថលេខានិងត្រា

---

បានឃើញ

ចៅក្រម

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ… ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី… ខែវិច្ឆិកា ឆ្នាំ២០២១

ក្រឡាបញ្ជី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

លេខ...៧០៤...ល.រ.អ

## រូបមន្តអនុវត្តដីកាសម្រេច

យើង ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា ៣៥៤ មាត្រា ៣៥៥ និងមាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៧ ។

-បានឃើញ ដីកាសម្រេចលេខ:៨៩៦ "ផ" ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ពាក្យសុំរូបមន្តអនុវត្តដីកាសម្រេច ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ឈ្មោះ ។

__សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្តមានដូចខាងក្រោមនេះ__

ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ , ភេទស្រី កើតថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៨៣ ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ៣សេ ផ្លូវលេខ៩៩ ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

អនុវត្តដោយបង្ខំនូវដីកាសម្រេចលេខ:៨៩៦ "ផ" ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេច។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ននៃការអនុវត្តដោយបង្ខំ ឱ្យសម្រេចតាមដីកាសម្រេចនេះ និងឱ្យអាជ្ញាធរសាធារណៈ ជួយអនុវត្តដីកាសម្រេចនេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

ថ្ងៃចន្ទ ០៣រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១

ក្រឡាបញ្ជី